ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ខ្សែអាត់វីដេអូរបស់ក្រុម អាយស៊ីល មិនមានយថាភាព
- ការរងគ្រោះនៃវត្ថុបុរាណ ក្នុងពេលសង្គ្រាម និង អសន្តិសុខ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧៥ ខែកក្កដា ឆ្នាំ២០១៤

# ស្វែងរកការពិត

លេខ១៧៥ ខែកក្កដា ឆ្នាំ២០១៤

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ខ្សែអាត់វីដេអូរបស់ អាយស៊ីស មិនមានយថាភាព ....................... ១

**ផ្នែកឯកសារ**

◆ វិទ្យាស្ថានស៊ីករីត ....................... ៣

◆ ភូ សំអាង : អ្នកទោសអង្គការ ....................... ៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ប៊ុន ពិន : “សូមតែរស់នៅជុំគ្រួសារ” ....................... ១៦

◆ ការរង់គ្រោះនៃវត្ថុបុរាណ ក្នុងពេលសង្គ្រាម ....................... ១៩

◆ ជនជាតិចាមក្នុងរបបខ្មែរក្រហម ....................... ២១

◆ ការអប់រំ ក្នុង និងក្រោយរបបខ្មែរក្រហម ....................... ២២

**ផ្នែកច្បាប់**

◆ សំណុំរឿង០០៣ និង ០០៤ : និយមន័យ ....................... ២៨

**វេទិកាពិភាក្សាសាធារណៈ**

◆ តើអាចជួយព្យាបាលរបួសនៅក្នុងសង្គមកម្ពុជាឲ្យជា ....................... ៣៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតក្នុងព្យុះមរណា ....................... ៣៩

◆ រឿងរ៉ាវដែលខ្ញុំចាំមិនភ្លេច ....................... ៤៧

◆ ម្តាយមីងរបស់ខ្ញុំ នាង គី : អាហារគឺជាជីវិត ....................... ៥២

◆ ឪពុករបស់ខ្ញុំ គ្មានឱកាសធ្វើនូវអ្វីដែលគាត់និយាយ ....................... ៥៥

◆ ខ្មែរក្រហមសម្លាប់បងប្រុសខ្ញុំ ....................... ៥៧

◆ ការបាត់បង់របស់ឪពុកខ្ញុំ បានត្រឹមតែចងចាំ ....................... ៥៩



ជនរងគ្រោះចូលរួមស្តាប់សវនាការបឋមបន្ថែមក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ ដែលមានជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅសាលាក្តីខ្មែរក្រហម

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ :*** *អៀង ណារី, ឆាយ ដាវីន, វង់ ស៊ីវនាថ, លន់ ដាលីន, រ៉េនឌល ដឺហ្វាលកូ, ចាយ៉ា រ៉ាមជី, សៀវ សុផុន, ឈុន ឡៃហេង, សុភ័ក្រ្ត ភាណា, លីហ្គូតេង និង អេង សុជាតា* ***អ្នកនិពន្ធនិងស្រាវជ្រាវ :*** *ទាវ សារៈមុនិន្ទ និង ស៊ិន សុធីតា* ***អ្នកបកប្រែ :*** *ភួង ច័ន្ទប្រណិត* ***និពន្ធនាយកទូទៅ :*** *ឆាំង យុ និង ញាណ សុជាតិ* ***ជំនួយការនិពន្ធនាយក :*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ :*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ :*** *ឆេង វើង និង សន ល័ក្ខ* Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ខ្សែអាត់វីដេអូរបស់ក្រុម អាយស៊ីល មិនមាន យថាភាព និងមិនមានលក្ខណៈត្រឹមត្រូវ

នៅក្នុងអត្ថបទមួយមានចំណងជើងថា "ប្រទេសកម្ពុជាបានចូលរួមជាមួយនឹងក្រុមជីវពល អាយស៊ីល (ISIL) នៅក្នុងប្រទេសអ៊ីរ៉ាក់" ចុះនៅថ្ងៃទី២៣ ខែមិថុនា ទំព័រ២៥ ដែលអ្នកបានដកស្រង់សម្តីរបស់កងជីវពលម្នាក់នៅក្នុងខ្សែវីដេអូ យូធូប ។ នៅក្នុងខ្សែវីដេអូនោះ ជនសកម្មប្រយុទ្ធម្នាក់មកពីក្រុមជីវពលនិកាយស៊ុននី ស្គាល់ថា ជាក្រុមជីវពលអាយស៊ីល បានអះអាងអំពីមិត្តរួមអាវុធមកពីប្រទេសកម្ពុជា, បង់ក្លាដេស, អូស្ត្រាលី និង អ៊ីរ៉ាក់ ។

ខ្សែអាត់វីដេអូនោះ គឺជាការឃោសនាអំពាវនាវជនម៉ូស្លីមកម្ពុជា ។ ដោយសារមានការពោលអះអាងបែបនេះ វាមានសារសំខាន់សម្រាប់ការស៊ើបអង្កេតលើយថាភាពនៃខ្សែអាត់វីដេអូដើម្បីជៀសវាងការនិយាយបន្លាច់ជនម៉ូស្លីមកម្ពុជា ។

យើងគួរតែពិចារណាឲ្យបានស៊ីជម្រៅលើសំណួរមួយចំនួន និងការនិយាយលើកឡើងនោះ ។ ហេតុអ្វីបានជាកងជីវពលអំពាវនាវជនម៉ូស្លីមកម្ពុជា និងជនម៉ូស្លីមដទៃ? តើជនម៉ូស្លីមកម្ពុជាមានការឈឺចាប់ និងមានការលើកទឹកចិត្តគ្រប់គ្រាន់ ដើម្បីចូលរួមជាមួយនឹងក្រុមជីវពលអាយស៊ីល ឬទេ? តើអ្វីជាគោលដៅរបស់អាយស៊ីល?

ចាប់តាំងពីឆ្នាំ១៩៩៣ នៅពេលដែលលទ្ធិប្រជាធិបតេយ្យត្រូវបាននាំយកមកប្រទេសកម្ពុជា សហគមន៍ជនម៉ូស្លីមកម្ពុជាបានបោះជំហានចូលឆាកអន្តរជាតិ ជាពិសេសមានទំនាក់ទំនងជាមួយប្រទេសកាន់សាសនាអ៊ីស្លាមដទៃ ។ ប្រជាធិបតេយ្យនិយកម្ម និងសេដ្ឋកិច្ចទីផ្សារសេរីនៅក្នុងប្រទេសកម្ពុជា បានធ្វើឲ្យសហគមន៍ជនម៉ូស្លីមកម្ពុជាត្រូវបានស្គាល់លើឆាកអន្តរជាតិ តាមរយៈការទំនាក់ទំនង ការផ្លាស់ប្តូរយោបល់ ព័ត៌មាន និងវប្បធម៌ ។ ដោយសារតែការកេងប្រវ័ញ្ចលើជនម៉ូស្លីមកម្ពុជា ក្រុមជីវពលអាយស៊ីល បានធ្វើការអំពាវនាវដោយមិនសមហេតុសមផល ។ មកដល់ពេលបច្ចុប្បន្ន យើងមិនបានទទួលដំណឹងអំពីក្រុមជីវពល ឬជនជ្រុលនិយមម៉ូស្លីមនៅក្នុងប្រទេសកម្ពុជា ឬនៅកន្លែងដទៃ ក្រៅតែពីសេចក្តីថ្លែងការណ៍របស់មន្ត្រីថៃ ដែលអះអាងពីជនសកម្មប្រយុទ្ធម៉ូស្លីម ស្ថិតក្នុងតំបន់ភាគខាងត្បូងប្រទេសថៃដ៏ជ្រួលច្របល់មួយទេ ។ ប៉ុន្តែការចោទប្រកាន់នោះត្រូវបានបដិសេធដោយមេដឹកនាំជនម៉ូស្លីមកម្ពុជា ដោយសារតែមិនមានភ័ស្តុតាងដើម្បីគាំទ្រអំណះអំណាង ។

សម្តីរបស់ក្រុមជីវពលអាយស៊ីល គឺស្ថិតនៅឆ្ងាយពីយថាភាពដែលលើកឡើងដោយមន្ត្រីថៃ ។ ទី១) កាលបរិច្ឆេទ និងទីតាំងនៃការនិយាយអះអាងក្នុងខ្សែអាត់វីដេអូ ពុំត្រូវបានស្គាល់ ។ ទី២) វាទំនងជាថាក្រុមជីវពលនោះ បានរួមបញ្ចូលជនម៉ូស្លីមកម្ពុជា និងជនម៉ូស្លីមដទៃ ក្នុងការអំពាវនាវដល់ជនម៉ូស្លីមនៅទូទាំងពិភពលោក ដើម្បីចូលរួមជាមួយក្រុមរបស់ខ្លួន ។

ក្រុមជីវពលនេះ បានសន្មតថា ជនម៉ូស្លីមវ័យក្មេងនឹងត្រូវបានអូសទាញដោយសារ សាររបស់ខ្លួន "ជីវិតដែលគ្មានជីហាដនឹងជួបផលវិបាក" ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ពាក្យ ជីហាដ នៅជាបញ្ហានៅក្នុងសង្គមជនម៉ូស្លីមជាច្រើន និងត្រូវបានបកស្រាយផ្សេងគ្នាតាមរយៈជនម៉ូស្លីម ។ ជីហាដ ត្រូវបែងចែកជាពីរ ដូចជា ជីហាដធំ និងជីហាដតូច ។ ទន្ទឹមពេលដែលជីហាដធំ សំដៅទៅរកការតស៊ូតាមបែបសាសនាប្រឆាំងនឹងភាពអាត្មានិយម និងអំពើបាបរបស់បុគ្គល ដែលនាំទៅរកជីវិតមួយប្រកបដោយគុណធម៌ និងវិន័យ ។ ជីហាដតូច សំដៅទៅរកការតស៊ូដោយកម្លាំងកាយប្រឆាំងនឹងការជិះជាន់ និងអំពើអយុត្តិធម៌ និងការការពារសាសនា ។ ជីហាដធំត្រូវបានប្រកាន់ខ្ជាប់ដោយសហគមន៍ជនម៉ូស្លីមកម្ពុជា រីឯជីហាដតូច ត្រូវបានប្រកាន់ខ្ជាប់ដោយជនម៉ូស្លីមមួយភាគតូចនៅមជ្ឈិមបូព៌ា និងប្រទេសមួយចំនួននៅតំបន់អាស៊ីអាគ្នេយ៍ ដែលបានរងទុក្ខដោយសាររដ្ឋាភិបាលមជ្ឈិម ជាពិសេស ដូចជា ប្រទេសថៃ, ឥណ្ឌូនេស៊ី និង ហ្វីលីពីន ។

សម្រាប់ប្រជាជនម៉ូស្លីមភាគច្រើន ជនម៉ូស្លីមទាំងនោះយល់ឃើញថា ការរងទុក្ខ ជាការតស៊ូដើម្បីរស់នៅដ៏ថ្លៃថ្នូរ ។

យោងតាមសាស្ត្រាចារ្យ សាអាដ អេដឌីន អ៊ីប្រាហ៊ីម ជាស្ថាបនិកមជ្ឈមណ្ឌល អែប ខាដុន សម្រាប់ការសិក្សាស្តីពីការអភិវឌ្ឍនៅក្នុងទីក្រុងគែរ និងអង្គការទទួលបន្ទុកសិទ្ធិមនុស្សរបស់អារ៉ាប់ គោលដៅរបស់ក្រុមជីវពលអាយស៊ីល គឺដើម្បីធ្វើឲ្យរស់ឡើងវិញនូវព្រះចៅម៉ូស្លីម និងបង្កើតរដ្ឋអ៊ីស្លាមនៅប្រទេសអ៊ីរ៉ាក់ ប្រទេសស៊ីរី និងប្រទេសដទៃទៀត ។ ក្រុមនេះដែលមានគោលដៅស្រដៀងគ្នាទៅនឹងក្រុមជីវពលដទៃ ដូចជា ក្រុមតាលីបង់ និងក្រុមអាល់កៃដា នៅតែមានមោទកភាពចំពោះសម័យកាលដ៏រុងរឿងរបស់ជនម៉ូស្លីម ជាពេលវេលាដែលព្រះចៅម៉ូស្លីមគ្រប់គ្រងតំបន់មួយចំនួននៅលើពិភពលោក ចាប់តាំងពីប្រទេសចិន រហូតដល់ប្រទេសអាហ្វ្រិក និងប្រទេសអ៊ឺរ៉ុបភាគខាងត្បូង ។

មោទកភាពនេះ កើតឡើងដោយសារការឈឺចាប់ និងឱកាស ។ ទន្ទឹមពេលនោះ មានតួលេខបង្ហាញថា មានជនម៉ូស្លីមប្រមាណ៨៥ភាគរយ ក្នុងចំណោមជនម៉ូស្លីម១.២ពាន់លាននាក់នៅលើពិភពលោក គឺជាជនម៉ូស្លីមកាន់និកាយស៊ុននី ជាពិសេសរស់នៅក្នុងប្រទេសជាប់ឈូងសមុទ្រដូចជា នៅតំបន់អាហ្វ្រិក អ៊ឺរ៉ុប និងអាស៊ី ។ ភាគច្រើននៃជនម៉ូស្លីម នៅតំបន់មជ្ឈិមបូព៌ា គឺជាជនម៉ូស្លីម កាន់និកាយស៊ីអ៊ីដ រស់នៅក្នុងប្រទេសអ៊ីរ៉ង់, ស៊ីរី, បារ៉ែន និងលីបង់ ដែលមានចំនួនប្រមាណ១០០លាននាក់ ។ ជនម៉ូស្លីមស៊ុននីដែលរស់នៅក្នុងនាមជាជនជាតិភាគតិចនៅក្នុងប្រទេសទាំងនោះ បានចាត់ទុកជនម៉ូស្លីមស៊ីអ៊ីដ ថា ជាការគំរាមកំហែង ដែលបណ្តាលមកពីការបែងចែកផ្នែកទីតាំងភូមិសាស្ត្រ ជម្លោះខាងនិកាយ និងភាពអយុត្តិធម៌ក្នុងសង្គម ។ ដោយត្រូវជំរុញលើកទឹកចិត្ត និងបំពាក់បំប៉នស្មារតីពីមេដឹកនាំសាសនា និងមេដឹកនាំនយោបាយ និងទទួលបានការគាំទ្រពីប្រទេសមួយចំនួន មិនស្ថិតនៅប្រទេសជាប់ឈូងសមុទ្រនោះ ក្រុមជីវពលម៉ូស្លីមមួយភាគតូចនេះបានសម្រេចចិត្តតស៊ូដោយសព្វាវុធដើម្បីបង្កើតរដ្ឋអ៊ីស្លាម ។ ជារឿយៗ សារបែបសាសនា ដូចជាពាក្យ "សាហ៊ីដ" ឬ "ទុក្ករកិរិយា" ដែលមានន័យថា ការស្លាប់ក្នុងនាមសាសនាត្រូវទទួលពរជ័យពីព្រះជាម្ចាស់ ត្រូវបានប្រើប្រាស់ដើម្បីជំរុញលើកទឹកចិត្តដល់ក្រុមនោះធ្វើការតស៊ូប្រយុទ្ធ ។

គ្មានអ្វីមួយដែលអាចធ្វើឲ្យយើងជឿថា ជនម៉ូស្លីមកម្ពុជាវ័យក្មេងបានចូលរួមជាមួយក្រុមនេះ ដោយសារខ្លួនមិនរងការឈឺចាប់ដោយសាររដ្ឋាភិបាល ឬក្រុមដទៃ ឬក៏មិនមានហេតុផលពិតប្រាកដណា ដែលជនម៉ូស្លីមកម្ពុជាវ័យក្មេងទាំងនោះត្រូវប្រព្រឹត្តទង្វើបែបនោះទេ ។

បច្ចុប្បន្ន ដោយរស់នៅពាសពេញសហគមន៍នៅទូទាំងប្រទេស ជនម៉ូស្លីមកម្ពុជាបានទទួលរងទុក្ខរួមជាមួយជនជាតិកម្ពុជាដទៃក្រោមរបបខ្មែរក្រហម ហើយបានរួមចំណែកកសាងប្រទេសជាតិបន្ទាប់ពីឆ្នាំ១៩៧៩ ។ អ្វីដែលជាសារសំខាន់សម្រាប់សហគមន៍ម៉ូស្លីម គឺរស់នៅក្នុងសន្តិភាព និងសុខដុមរមនា ដោយមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ។

**សូ ហ្វារីណា**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: truthsocheat@dccam.org
Home page: www.dccam.org

# វិទ្យាស្ថានស្លឹករឹត

វិទ្យាស្ថានស្លឹករឹត គឺជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ ដែលនាំមុខក្នុងការយល់ដឹងពីអំពើប្រល័យពូជសាសន៍ក្នុងតំបន់អាស៊ី ដោយលើកស្ទួយការចងចាំ យុត្តិធម៌ និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ទាំងមូល ។

ស្លឹករឹត គឺជាប្រភេទស្លឹកឈើស្ងួត ដែលព្រះសង្ឃ និងអ្នកប្រាជ្ញនៅក្នុងប្រទេសកម្ពុជាបានប្រើប្រាស់ដើម្បីកត់ត្រាប្រវត្តិសាស្ត្រ ចែករំលែកចំណេះដឹង និងរក្សាវប្បធម៌ ក្នុងសម័យកាលនៃការគ្រប់គ្រងដ៏ឃោរឃៅអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ។ ស្លឹករឹតតំណាងឲ្យទាំងសោភ័ណភាពនៃចំណេះវិជ្ជា និងអំណាចនៃសេចក្ដីព្យាយាមរបស់មនុស្សក្នុងសម័យកាលដ៏រឹករវរ ។

ដូចគ្នានៅនឹងស្លឹកឈើដែលវិទ្យាស្ថាននេះត្រូវបានដាក់ឈ្មោះវិទ្យាស្ថានស្លឹករឹត គឺជាកន្លែងដែលកសាងអនាគតរបស់ប្រទេសកម្ពុជាតាមរយៈការថែរក្សាការយល់ដឹងអំពីអតីតកាលរបស់ខ្លួន ។ តាមរយៈខ្លឹមសារនៃការចងចាំ យុត្តិធម៌ និងការផ្សះផ្សា វិទ្យាស្ថានស្លឹករឹត នឹងក្លាយជាពន្លឺនាំមុខក្នុងការយល់ដឹងពីអំពើប្រល័យពូជសាសន៍ក្នុងតំបន់ ដោយមានបណ្ណាញសារមន្ទីរ និងគំនិតផ្ដួចផ្ដើមការអប់រំ វិទ្យាស្ថានស្រាវជ្រាវដែលផ្ដោតក្នុងតំបន់ និងសាលារៀនដែលទទួលស្គាល់ជាអន្តរជាតិ ។

ការស្វែងរកការពិតនៃការចងចាំ និងយុត្តិធម៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្ដោតលើការកសាងអនាគតរបស់ប្រទេសកម្ពុជាតាមរយៈមធ្យោបាយនៃការចងចាំ និងការផ្សះផ្សា ។ ប្រការនេះ ស្ដីអំពីការតស៊ូស្វែងរកយុត្តិធម៌ដែលកំពុងប្រឈមទៅនឹងអំណាចពោរពាសនឹងស្ទើរតែបំផ្លាញសង្គមរបស់យើង ដែលជាអំណាចមួយបន្តទៅមុខកាន់តែគឃ្លើនដើម្បីគំរាមកំហែងដល់សេចក្ដីប៉ងប្រាថ្នាចង់បានអនាគតថ្កើងថ្កាន ។ តាមរយៈការងារនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានកសាងមូលដ្ឋានលើអ្វីដែលប្រជាជនកម្ពុជាទាំងអស់អាចស្វែងរកជំហររឹងមាំក្នុងការឆ្ពោះទៅរកអនាគតដ៏ប្រសើរ ។ ដោយឈរលើមូលដ្ឋាននេះ យើងនឹងកសាងវិទ្យាស្ថានស្លឹករឹត ។

បច្ចុប្បន្នភាព ជាពេលវេលាដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជា ។ ដោយសារប្រជាជនប្រមាណ៧០ភាគរយបានកើតក្រោយរបបខ្មែរក្រហម ប្រជាជនកម្ពុជាគឺមានភាពប្រថុយប្រថានក្នុងការបាត់បង់ឱកាសយល់ដឹង ចងចាំ និងរៀនសូត្រពីប្រវត្តិសាស្ត្រដ៏លំបាករបស់ខ្លួន ។ ស្របពេលជាមួយគ្នានេះ ប្រទេសកម្ពុជាដែលកំពុងបោះជំហានទៅមុខយ៉ាងលឿន ប្រឈមមុខនឹងបញ្ហាប្រឈមថ្មីៗក្នុងការអភិវឌ្ឍរីកចម្រើនប្រកបដោយនិរន្តរភាព លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។ ដោយវិវឌ្ឍន៍ចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា វិទ្យាស្ថាននេះ គឺជាស្ថានដែលតភ្ជាប់ការចងចាំអំពីអតីតកាល យុត្តិធម៌ នាពេលបច្ចុប្បន្ន និង អនាគតនៃការផ្សះផ្សា ។

ក្នុងឆ្នាំ២០០៨ រាជរដ្ឋាភិបាលប្រទេសកម្ពុជា បានបរិច្ចាគផ្ទៃដីមួយកន្លែងសម្រាប់វិទ្យាស្ថានស្លឹករឹត ។ ផ្ទៃដីនោះមានទីតាំងនៅក្បែរបណ្ណាល័យសាធារណៈថ្មីមួយ និងសកលវិទ្យាល័យនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ផ្ទៃដីនោះក៏ជិតទៅនឹងចំណុចកណ្ដាលនៃរាជធានីភ្នំពេញដែលងាយស្រួលសម្រាប់អ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ ។

យើងគ្រោងសាងសង់វិទ្យាស្ថាននេះក្នុងឆ្នាំ២០១៤ និងបញ្ចប់គម្រោងនេះត្រឹមឆ្នាំ២០១៦ ។ យើងមានអ្នកស្ថាបនិក ដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ល្បីល្បាញ ដើម្បីកសាងបរិវេណរបស់វិទ្យាស្ថាននេះ ។ សិស្សមកពីសកលវិទ្យាល័យកូឡុំប៊ី និងសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានរួមចំណែកស្រាវជ្រាវដល់គម្រោងរបស់យើង ។ យើងបានរំពឹងមើលនូវបរិវេណតូចមួយដែលមានអគារតភ្ជាប់គ្នាជាច្រើន ។ ការបង្កើតវិទ្យាស្ថាននេះ នឹងផ្ដោតលើការស្វែងយល់អំពីសិល្បៈរបស់ប្រទេសកម្ពុជា និង បរិស្ថានជុំវិញ ។ យើងនឹងកសាងបូជនីយដ្ឋានមួយដើម្បីគោរពដល់ជនរងគ្រោះនៃអំពើឃោរឃៅក្នុងប្រទេសកម្ពុជា ។ បរិវេណនេះ នឹងមានកន្លែងធំទូលាយដែលមានសួនច្បារធំមួយ និងត្រពាំងតូចមួយដែលបង្កើតនូវបរិស្ថានស្ងប់ស្ងាត់សម្រាប់សិស្សានុសិស្ស និងអ្នកទស្សនា ព្រមទាំងជាកន្លែងព្យាបាលស្នាមរបួសអតីតកាលសម្រាប់ជនរងគ្រោះនៃការធ្វើទារុណកម្ម និងការរំលោភបំពានផ្សេងៗ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧១៥...អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតវិទ្យាស្ថានស្លឹករឹត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

១ / ៣

# សម្រេច

**មាត្រា១ ..**

ត្រូវបានបង្កើតគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយដែលមានឈ្មោះថា វិទ្យាស្ថានស្លឹករឹត SLEUK RITH INSTITUTE សរសេរជាអក្សរកាត់ជាភាសាខ្មែរ វ.ស.រ. និងជាភាសាអង់គ្លេស S.R.I.។

**មាត្រា២ ..**

វិទ្យាស្ថានស្លឹករឹត មានទីតាំងស្ថិតនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែក មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ វិទ្យាស្ថាននេះស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ទៅអនាគត វិទ្យាស្ថាននេះអាចសុំប្តូរឈ្មោះថ្មីឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ ..**

វិទ្យាស្ថានស្លឹករឹតមានផ្នែកសំខាន់ៗដូចខាងក្រោម៖

- សារមន្ទីរ
- មជ្ឈមណ្ឌលស្រាវជ្រាវ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវលើមុខជំនាញឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ វិវាទកម្ម និងសិទ្ធិមនុស្ស ដោយធ្វើការបណ្តុះបណ្តាលគ្រប់កម្រិតឧត្តមសិក្សាលើមុខជំនាញទាំងនេះ
- មជ្ឈមណ្ឌលសារព័ត៌មាន។

**មាត្រា៤ ..**

វិទ្យាស្ថានស្លឹករឹត ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

**មាត្រា៥ ..**

នាយកវិទ្យាស្ថានស្លឹករឹតមានភារកិច្ច៖

- អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំផ្ទៃក្នុងនៅឧត្តមសិក្សា
- រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន និងវិធានផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងការសិក្សាឱ្យបានច្បាស់លាស់
- ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមមុខជំនាញ ដើម្បីស្នើសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ដំណើរការបណ្តុះបណ្តាល
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំមកអគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា
- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានស្លឹករឹត។/.

២ / ៣

**មាត្រា៦ .-**

និស្សិតឬអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ ដែលបានរៀនចប់តាមកម្មវិធីសិក្សា និងស្រាវជ្រាវ ហើយទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រឬវិញ្ញាបនបត្រ តាមមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឱ្យដោយវិទ្យាស្ថានស្លឹករឹត ក្នុងករណីវិទ្យាស្ថានស្លឹករឹតបំពេញនិងអនុវត្តបានតាមគោលការណ៍និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៣ / ៣

# ភូ សំអាង : អ្នកទោសអង្គការ

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៥៩៦៦២***

*ភូ សំអាង មានអាយុ២៣ឆ្នាំ មានស្រុកកំណើតនៅភូមិទួលស្រង៉ាំ ឃុំភ្នំលាវ ស្រុកកំពង់ត្រាច តំបន់៣៥ ភូមិភាគនិរតី ។ មុនអង្គការចាប់ខ្លួន សំអាង មានតួនាទីជាអនុប្រធានកងហានៅវរសេនាតូច៣២១ វរសេនាធំ៣២ កងពល៧០៣ ។ ខាងក្រោមនេះជាចម្លើយសារភាពរបស់ ភូ សំអាង មានចំនួន៣៧ទំព័រ ដែលគាត់រៀបរាប់ពីប្រវត្តិក្បត់របស់ខ្លួនៈ*

*អាយុបាន១២ឆ្នាំ ខ្ញុំបានចូលរៀននៅសាលាវត្តព្រៃតាកុយ ក្នុងឃុំភ្នំលាវ សិក្សាដល់ថ្នាក់ទី១០ ខ្ញុំក៏ឈប់រៀនដើម្បីជួយធ្វើការឪពុកម្តាយវិញ ។ ឪពុកម្តាយរបស់ សំអាង ជាអ្នកនេសាទត្រី តែក្រោយមកគាត់បានចូលធ្វើការបម្រើខ្មាំង ដោយធ្វើជាគិញឲ្យមេឃុំនៅឃុំភ្នំលាវ ។ នៅឆ្នាំ១៩៧០ ពេលអាយុ១៥ឆ្នាំ ខ្ញុំបានឈប់រៀន ហើយឪពុករបស់ខ្ញុំបានណែនាំខ្ញុំឲ្យចូលធ្វើជាខ្សែរយៈគិញរបស់មេឃុំ និងទាហានបន្តពីគាត់ ។ ដោយសារតែឪពុករបស់ខ្ញុំមានវ័យចំណាស់ ដូចនេះហើយទើបគាត់ឲ្យខ្ញុំ មកធ្វើការជំនួសគាត់ ។ ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំថា «បើកូនឃើញកងឈ្លប កងរំដោះមកភូមិយើង ឬផ្ទះយើងកូនត្រូវរត់ទៅប្រាប់លោកតា រ៉ិត ជាសង្ឃរាជវត្តព្រៃតាកុយ ដើម្បីឲ្យលោកតារាយការណ៍ទៅប្រាប់មេឃុំ និងទាហាននៅបន្ទាយវាលវង់» ។ ឪពុករបស់ខ្ញុំ បានប្រាប់ខ្ញុំពីខ្សែរយៈរបស់គាត់មានដូចជា ង៉ែត អតីតដើរស៊ីឈ្នួលជាមួយឪពុករបស់(សំអាង) , ឌុច (ប្រជាជននៅភូមិអំបែងឃុំភ្នំលាវ) , ង៉ែត (ជាប្រជាជន*



*សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ឬអតីតមន្ទីរសន្តិសុខស-២១ ក្រោយពេលរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩*

នៅភូមិអង្កោល ឃុំភ្នំលាវ) ,ទុយ (អាចារ្យវត្តព្រៃតាកុយ) ។ ឪពុករបស់ខ្ញុំ បានអប់រំខ្ញុំឲ្យស្អប់បដិវត្តន៍ ដែលគាត់បានប្រាប់ថា បដិវត្តន៍គ្មានស៊ីស៊ីទេ មានការលំបាកណាស់ដើរទៅណាក៏មិនបានដែរ ។

នៅឆ្នាំ១៩៧២ ឪពុកខ្ញុំ បានប្រាប់ថា បើឃើញមានអ្នកណាម្នាក់ឲ្យបាយខ្មែរក្រហម ត្រូវរាយការណ៍ប្រាប់ទាហានតាមរយៈលោកតា រ៉ិត ។ ក្រោយពេលនោះ បានប្រហែលពីរខែ ខ្ញុំក៏បានឃើញខ្មែរក្រហមចូលមកសុំបាយផ្ទះខ្ញុំហូប ហើយឪពុកម្តាយរបស់ខ្ញុំក៏បានដាំបាយឲ្យហូប ហើយកងឈ្លបទាំងនោះបានប្រាប់ថា ជួយលាក់ការណ៍ដើម្បីកុំឲ្យទាហានដឹង ហើយក៏ដើរចេញទៅ ។ តែព្រឹកឡើង ឪពុករបស់ខ្ញុំបានទៅប្រាប់តា រ៉ិត ទៅរាយការណ៍ប្រាប់ទាហានឲ្យចាំស្ទាក់ខ្មែរក្រហម ដល់ពេលទាហានទៅចាំស្ទាក់បែរជាមិនបានឃើញខ្មែរក្រហមមកតាមនេះទេ ។ លុះក្រោយមកទៀត ទាហានបានប្រកាសតាមមេក្រូថា បើសិនអ្នកណាចាប់ខ្មែរក្រហមបានគេនឹងឲ្យប្រាក់ចំនួន៥.០០០រៀល និងអង្ករ១០បាវ ។ គ្រាន់តែឮដូចនេះប្រជាជនខ្លះ ចង់បានក៏ខំធ្វើតាមការឃោសនានេះ តែចាប់មិនបានខ្មែរក្រហមណាម្នាក់ឡើយ ។ នៅក្នុងឆ្នាំ១៩៧២ដដែលនេះ មានប្រជាជនបីនាក់ឈ្មោះ សែម, ធូ និង ទុយ ចាប់បានកងឈ្លបម្នាក់ឈ្មោះ កប ពេលចាប់បានហើយគាត់ទាំងបីក៏នាំខ្លួនទៅឲ្យទាហានបន្ទាយកែប ស្រុកកំពត ។ ក្រោយពេលអង្គការចាប់ឈ្មោះ សែម និង ធូ បាត់ទៅ ចំពោះឈ្មោះ ទុយ ដែលជាអ្នកប្រាប់ឲ្យគេចាប់ អង្គការគ្រាន់តែយកទៅអប់រំហើយដោះលែងមកវិញ ។ ឪពុកខ្ញុំបានដឹងរឿងទាំងអស់នេះ ហើយគាត់និងខ្ញុំមិនដែលធ្វើសកម្មភាពអ្វីទៀតទេប្រហែលជា ៤ទៅ៥ខែ ។

ដល់ខែធ្នូ ឆ្នាំ១៩៧២ អង្គការបានដើរប្រមូលប្រជាជននៅក្នុងស្រុកទាំងអស់ ។ នៅពេលនោះ គ្រួសាររបស់ខ្ញុំត្រូវបានអង្គការជម្លៀសទៅនៅស្រុកលើ គឺនៅភូមិអង្ក្រងទី១ ឃុំស្រែយា ស្រុកកំពង់ត្រាច ។ ពេលនោះឪពុកខ្ញុំដាច់ខ្សែរយៈ ហើយគាត់និងខ្ញុំក៏មិនបានធ្វើសកម្មភាពអ្វីដែរ ។ មកដល់ឆ្នាំ១៩៧៣ អង្គការបានរើសខ្ញុំឲ្យចូលជាកងទ័ព ដំបូងខ្ញុំចូលមកនៅឈ្លបនៅភ្នំលាវ តែមិនបានធ្វើសកម្មភាពអ្វីទេ ព្រោះតែគ្មានខ្សែរយៈសម្រាប់ទាក់ទងគ្នា ។ បីខែក្រោយមក អង្គការបានបញ្ជូនខ្ញុំឲ្យមកធ្វើកងទ័ពនៅស្រុកកំពង់ត្រាច តែមិនឲ្យទៅកងទ័ពភ្លាមទេគឺឲ្យនៅមន្ទីរស្រុកមួយរយៈសិនគឺនៅជាមួយ តាសៀន គណៈស្រុកកំពង់ត្រាច ។ លុះបានកន្លះខែ តាសៀន បានឲ្យខ្ញុំចូលក្នុងក្រុម សេ. អ៊ី. អា. របស់គាត់ ។ គាត់បានហៅខ្ញុំ និងពីរនាក់ទៀតឈ្មោះ ផែន និង សាត ទៅមុជទឹកជាមួយគាត់ ។ លុះស្អែកឡើង គាត់បានហៅយើងទាំងបីនាក់ទៅសួរពីដំណើរក្នុងការធ្វើបដិវត្តន៍ ហើយគាត់បានអប់រំខ្ញុំទាំងបីនាក់ឲ្យស្អប់ប្រឆាំងនឹងបដិវត្តន៍ដោយធ្វើការប្រៀបធៀបទៅនឹងសង្គមចាស់ ។ តាសៀន ចេះតែបញ្ចុះបញ្ចូលខ្ញុំទាំងបីដើម្បីឲ្យជួយធ្វើការងារគាត់ ។ ពេលនោះខ្ញុំទាំងបីបានស្តាប់តាមសម្តីរបស់ តាសៀន ហើយគាត់ក៏ចាត់តាំងយើងទាំងបីធ្វើការជាភ្នាក់ងារសម្ងាត់របស់គាត់ ។ គាត់សួរខ្ញុំទាំងបីថា តើហ៊ានធ្វើការងារនេះជាមួយគាត់ទេ? ហើយខ្ញុំទាំងបីនាក់ក៏បានឆ្លើយថា អ្វីក៏ហ៊ានធ្វើដែរឲ្យតែមានការរស់នៅស្រួល ។ តាសៀន បានឲ្យយើងទាំងបីនាក់រស់នៅមន្ទីរនេះសិនចុះ ចាំគាត់ជាអ្នកទៅទាក់ទងគ្នាបាន ចាំយើងធ្វើសកម្មភាពទាំងអស់គ្នា ។ នៅទីនេះខ្ញុំមិនមានធ្វើសកម្មភាពអ្វីទេ តែក្រោយមកទៀតខ្ញុំត្រូវឡើងមកយោធាស្រុកកំពង់ត្រាច ។ ពេលនោះ តាសៀន បានប្រាប់ខ្ញុំថា ទៅយោធាស្រុក មិត្តកុំអស់សង្ឃឹមថាអត់មានខ្សែរបស់យើង ព្រោះគាត់បានចាត់តាំងខ្សែនៅទីនោះរួចជាស្រេចហើយ ។ ក្រោយពី តាសៀន ណែនាំហើយ ខ្ញុំត្រូវឡើងមកយោធាស្រុកកំពង់ត្រាច តែ សាត អត់មកជាមួយទេនៅធ្វើនីរសារស្រុកកំពង់ត្រាច ។ ពេលខ្ញុំទៅដល់ បងសោ ដែល តាសៀន បានទាក់ទងនោះ បានឲ្យខ្ញុំទៅនៅកងអនុសេនាតូចទី១ កងអនុសេនាធំទី២ ។ ឯឈ្មោះ ផែន ហៅ រិន ទៅកងពលតូចទី២ កងពលធំទី២ ហើយពេលនោះខ្ញុំ និង ផែន ទាក់ទងគ្នាជាប់រហូត ។ កន្លងផុតជាងកន្លះខែ អ៊ឹម ដែលជាប្រធានកងអនុសេនាធំរបស់ខ្ញុំ បានហៅខ្ញុំ និង ផែន ទៅប្រជុំជាមួយ បងសោ ។ ពេលនោះមាន ខ្ញុំ, អ៊ឹម, ផែន, បងសោ, សង់, ឡាញ់ និង សួស ។ ការប្រជុំនោះ បងសោ បានណែនាំថា ឥឡូវខ្សែរបស់យើងមានទាំងអស់៧នាក់ ដោយ តាសៀន បានប្រាប់ខ្ញុំហៅមិត្តមកប្រជុំនេះ ដើម្បីដាក់ផែនការឲ្យយើងបំពេញរៀង១ខ្លួន ។

**ផែនការទី១** គឺត្រូវបំពាក់បំប៉នយោបាយរបស់យើងដល់យុទ្ធជនណាដែលយើងទុកចិត្ត ដើម្បីពង្រីកកម្លាំងរបស់យើង ។

**ផែនការទី២** គឺត្រូវធ្វើសកម្មភាពនៅខាងក្នុងកងរបស់យើងឲ្យបានជាបន្តបន្ទាប់ ។

**ផែនការទី៣** គឺធ្វើសកម្មភាពអុកឡុកនៅក្នុងអង្គភាពរបស់យើង ។ ចុងបញ្ចប់ គាត់ណែនាំរឿងលាក់ការណ៍សម្ងាត់ និងប្រាប់ឲ្យ មឿន ទៅដេកពេទ្យ ។ ក្រោយមកទៀត បងអ៊ីម បានឲ្យខ្ញុំ បងសួស និងបងឡាញ់ ទៅធ្វើការពិនិត្យ និងការពារខ្មាំងនៅតាមព្រំដែន ។ គាត់បានប្រាប់ទៀតថា បើយើងទៅធ្វើការហើយឃើញខ្មាំងមិនបាច់បាញ់ទេ ។ សកម្មភាពនេះក្រោយពីទទួលបានការណែនាំហើយ គឺបានធ្វើជាបន្តបន្ទាប់រហូតដល់អង្គការហៅខ្ញុំទៅកសាងអប់រំ រួចហើយលែងឲ្យខ្ញុំទៅសមរភូមិមុខទៀត គឺឲ្យនៅដាំបាយឲ្យមិត្តយើងវិញ ។ នៅពេលដាំបាយនោះ បងអ៊ីម បានទៅណែនាំឲ្យខ្ញុំបំផ្លាញដោយដាំបាយឲ្យខ្លោច ។ បើទៅបើកអង្ករពីថ្នាក់លើត្រូវដាក់ឲ្យច្រើនលើសពីចំនួនមនុស្សដែលនៅក្នុងអង្គភាព ខ្ញុំបានធ្វើសកម្មភាពនេះរហូតដល់ខែមេសា ឆ្នាំ១៩៧៤ ។ បន្ទាប់មកខ្ញុំក៏ធ្លាក់ខ្លួនឈឺដេកនៅពេទ្យស្រុកកំពង់ត្រាចរយៈពេលមួយខែ ។ នៅក្នុងពេទ្យនោះខ្ញុំក៏បានធ្វើសកម្មភាពខ្លះៗដែរ ដោយបំផ្លាញថ្នាំពេទ្យ មិនគោរពវិន័យពេទ្យ និងលួចថ្នាំយកទៅបោះចោល ។ នៅចុងខែឧសភា ឆ្នាំ១៩៧៤ បងអ៊ីម បានទៅសម្រាកនៅពេទ្យដែរ ស្របពេលដែលខ្ញុំជាសះស្បើយជិតនឹងត្រឡប់មកកាន់អង្គភាពវិញ ។ បងអ៊ីម បានណែនាំខ្ញុំថាឲ្យខ្ញុំទៅទាក់ទងខ្មែរសង្វាក់ឡើងវិញដើម្បីធ្វើសកម្មភាពបន្តទៀត ។ លុះខ្ញុំមកពីពេទ្យបាន៧ថ្ងៃ បងអ៊ីម ក៏ត្រឡប់មកវិញដែរ ហើយបានហៅខ្ញុំទៅប្រជុំជាមួយ បងសោ និងមានបងអ៊ីម, បងសួស, បងឡាញ់, ផែន និង មឿន ។ ពេលប្រជុំនោះ បងសោ បានសួរទាំងអស់គ្នាថាកសាងកម្លាំងបានប៉ុន្មានហើយ ។ បងអ៊ីម បានឆ្លើយថា ពង្រឹងបានពីរនាក់គឺ ឈ្មោះ ទូច និង ហាន ។ បន្ទាប់មក បងសោ ក៏បានរៀបចំផែនការតទៀតគឺការធ្វើការបំផ្លិចបំផ្លាញផ្សេងៗ ។ បងសោ បានប្រាប់ថា ខ្មែររបស់យើងមិនមែនមានតែនៅស្រុកយើងនេះទេ នៅតំបន់ណាក៏មានខ្មែររបស់យើងដែរ ដូច្នេះហើយយើងត្រូវធ្វើសកម្មភាពឲ្យខ្លាំងក្លាបំផុត ។ ប្រជុំហើយបានមួយសប្តាហ៍ កងទ័ពស្រុកត្រូវរៀបចំកម្លាំងទៅវាយកងស៊ុយត្រាណ និងអាធីវ នៅតាមព្រំដែន ។ ពេលនោះ ខ្ញុំមិនបានទៅទេ ហើយពេលដែលនៅនឹងកន្លែង ខ្ញុំបានធ្វើសកម្មភាពយកអង្ករកន្លះបាវទៅចាក់ចោលក្នុងទឹក និងចាប់ក្អែបឲ្យខាំជ្រូកងាប់អស់មួយក្បាល ។ ខ្ញុំត្រូវបានអង្គការហៅទៅកសាងពីរឿងងាប់ជ្រូក បន្ទាប់ពីនោះខ្ញុំក៏លែងសូវហ៊ានធ្វើសកម្មភាពទៀតដែរ ។

នៅខែកក្កដា ឆ្នាំ១៩៧៤ អង្គការតម្រូវឲ្យកងទ័ពស្រុកឡើងមកកងទ័ពតំបន់ចំនួនពីរកងហ ហើយខ្ញុំក៏ត្រូវឡើងមកដែរ ។ គ្រាន់តែដឹងថាខ្ញុំទៅទីនោះ បងអ៊ីម បានហៅខ្ញុំឲ្យទៅជួប បងសោ ហើយគាត់ បានណែនាំខ្ញុំថា ឲ្យទាក់ទងខ្មែរនៅតំបន់នោះ ។ បងសោ បានឲ្យខ្ញុំទៅទាក់ទងជាមួយឈ្មោះ សារ៉ុម ជាកងវរៈនៅតំបន់នោះ ដោយគាត់បានទាក់ទងជាមុនរួចស្រេចហើយ ។ គាត់បានប្រាប់ខ្ញុំថា ពេលទៅដល់ទីនោះខំធ្វើសកម្មភាពតាមផែនការរបស់យើង និងខំធ្វើការបម្រើបដិវត្តន៍តាមធម្មតា ដើម្បីកុំឲ្យមិត្តយើងចាប់អារម្មណ៍ ។ លុះណែនាំចប់រំលងបានរយៈពេលបីថ្ងៃ ខ្ញុំក៏ឡើងមកកងទ័ពតំបន់ដែលមាន បងអ៊ីម ជាអ្នកជូនខ្ញុំមកតែមិនបានជួបនឹង សារ៉ុម ទេ ។ ខ្ញុំទៅហាត់បច្ចេកទេសបានរយៈពេលមួយខែ ខ្ញុំមិនទាន់បានទាក់ទងជាមួយអ្នកណានៅឡើយទេ ។ តែខ្ញុំបានធ្វើសកម្មភាពដោយយកគ្រាប់បែកទៅបោកត្រី តែអង្គការមិនបានហៅទៅកសាង ឬស្តីបន្ទោសឡើយ ។ ហាត់បច្ចេកទេសរួច ខ្ញុំបានមកនៅកងទ័ពតំបន់៣៥ និងមានការបែងចែកខ្ញុំមកនៅក្នុងកងអនុសេនាធំ១១៧ នៅកាន់ក្រុម៦១ ប្រចាំកងអនុសេនាធំ ក្នុងវរសេនាតូច៥៧ វរសេនាធំ៤០៣ របស់តំបន់កំពត ។ នៅបានរយៈពេលកន្លះខែ ខ្ញុំក៏ទាក់ទងជាមួយឈ្មោះ សារ៉ុម គាត់បានហៅខ្ញុំទៅជួប ហើយក៏ទទួលខ្ញុំជាខ្មែររយៈ ។ សារ៉ុម បានប្រាប់ខ្ញុំថា ឥឡូវយើងដឹងខ្មែររយៈយើងហើយ តែគាត់មិនបានឲ្យខ្ញុំធ្វើសកម្មភាពអ្វីទេ ព្រោះគាត់ថា សភាពការណ៍របស់អង្គការពេលនេះកំពុងដើររកចាប់អ្នកដែលប្រឆាំងនឹងអង្គការ ។ បន្ទាប់ពីគាត់ប្រាប់ដូចនេះហើយ ខ្ញុំមិនដែលបានធ្វើសកម្មភាពទេរហូតដល់ខែធ្នូ ឆ្នាំ១៩៧៤ សារ៉ុម បានហៅខ្ញុំទៅជួប និងប្រាប់ពីខ្មែរសង្វាក់ចំនួនប្រាំបីនាក់ទៀតដែលមានឈ្មោះដូចជា ពៅ, ជន, អេង, វ៉ឺន, ឆាយ, ខេង, ម៉ុញ និង អាន ។ សារ៉ុម មិនឲ្យយើងធ្វើអ្វីទេ ចាំដល់ពេលអង្គការដាប់ដៃវាយខ្មាំង ចាំយើងចេញធ្វើសកម្មភាពតាមក្រោយ ។

ចូលដល់ខែមករា ឆ្នាំ១៩៧៥ សារ៉ុម បានហៅខ្ញុំ និងខ្មែរដែលគាត់បានទាក់ទងទាំងប៉ុន្មានមកប្រជុំ ដោយប្រាប់ថាពួកយើងអាចធ្វើសកម្មភាពបានហើយ ព្រោះពេលនេះអង្គការកំពុងជាប់ដៃវាយខ្មាំង ។ គាត់បានឲ្យខ្ញុំធ្វើសកម្មភាពជាមួយ អាន ដោយគាត់

ត្រូវដើរកាត់ខ្សែតេអូរ ។ ធ្វើសកម្មភាពបានជាងមួយខែ បងសារ៉ុម បានដកខ្ញុំចេញឲ្យទៅនៅតាមកងដើម្បីធ្វើសកម្មភាពផ្ទៃក្នុងវិញ ។ ការធ្វើសកម្មភាពខាងក្នុងនោះមាន ការបោកគ្រាប់បែក យកឆ្នាំង ដែលមានបាយទៅចាក់ចោល ។ សារ៉ុម ថាឲ្យតែផលប្រយោជន៍ របស់អង្គការត្រូវតែបំផ្លាញទាំងអស់ ។ ខ្ញុំក៏បានធ្វើសកម្មភាព ទាំងនេះតាមដែល សារ៉ុម ប្រាប់ ។

ខែកុម្ភៈ ឆ្នាំ១៩៧៥ បងសារ៉ុម បងជន និងបងពៅ បានឲ្យខ្ញុំធ្វើសកម្មភាពខ្លាំងៗ ដើម្បីធ្វើឲ្យបែកការណ៍ឲ្យទាហានបាញ់ហើយយើងរត់មកក្រោយវិញ ។ ដំបូងខ្ញុំមិនហ៊ានធ្វើទេ ព្រោះខ្លាចទាហានបាញ់ត្រូវខ្លួនឯង តែដល់វាយលើកក្រោយទៀតខ្ញុំក៏ធ្វើឲ្យបែកការណ៍ ។ ពេលនោះខ្ញុំក៏ត្រូវរបួស ហើយ បងឆាយ និងវ៉ែន ជាខ្សែរបស់ខ្ញុំក៏ត្រូវរបួសដេកពេទ្យដែរ ។ គាត់ទាំងអស់នេះហើយដែលជាអ្នកដឹកនាំខ្ញុំធ្វើសកម្មភាពទាំងអស់នេះ ។ ក្រោយជាសះស្បើយខ្ញុំសម្រាកនៅកងចំនួន១០ថ្ងៃ ហើយក៏ទៅជួបបង សារ៉ុម និងសួរថាតើគ្នាយើងទៅណាអស់ហើយ? គាត់ក៏បានឆ្លើយថា គ្នាយើងស្លាប់អស់ម្នាក់គឺ ម៉ុញ និងត្រូវរបួសមាន ឆាយ និង វ៉ែន ។ សារ៉ុម បានប្រាប់ថាគាត់បានពង្រីកបានខ្សែម្នាក់ទៀតឈ្មោះ កេន ។ រហូតដល់ខែមេសា បងសារ៉ុម បានប្រាប់ខ្ញុំឲ្យទៅវាយខ្សាំងផ្តាច់ព្រ័ត្រជាមួយនឹងគេ ពេលនោះខ្ញុំបានទាក់ទងជាមួយ កេន ជាប់រហូត ។ នៅពេលជួប កេនខ្ញុំក៏បបួលរត់ តែមិនទាន់បានរត់ផងខ្ញុំក៏ត្រូវរបួសហើយក៏ទៅដេកពេទ្យដល់ខែកក្កដា ឆ្នាំ១៩៧៥ ទើបជាសះស្បើយហើយអង្គការបានឲ្យខ្ញុំនៅចាំផ្ទះ ។ ក្រោយពី បងសារ៉ុម បានឡើងជាវរសេនាធំហើយ គាត់បានមកណែនាំខ្ញុំថា ពេលដែលខ្ញុំត្រូវរបួសនោះ គឺមិត្តរបស់យើងធ្វើសកម្មភាពជាបន្តបន្ទាប់ ។ បងសារ៉ុម បានប្រាប់ពីខ្សែដែលគាត់ទើបនឹងទាក់ទងមានពីរនាក់ដូចជាវួន និង បើន ។ មិត្តទាំងពីរនេះ បងសារ៉ុម បានឲ្យទៅនៅជាមួយមិត្តជន ហើយ ជន ជាអ្នកដឹកនាំអ្នកទាំងនោះ ។ បន្ទាប់មកអង្គការបានដក អង្គភាពខ្ញុំមួយកងរយទៅការពារតាមឆ្នេរសមុទ្រខាងលិចកំពត ។ បងសារ៉ុម បានប្រាប់ខ្ញុំថាទោះជា យើងទៅទីនោះក៏ដោយក៏នៅតែទាក់ទងគ្នាដែរ ។ គាត់បានប្រាប់ថា បើជួបការលំបាកអីឲ្យរាយការណ៍ទៅឲ្យគាត់តាមរយៈនីរសារ ដើម្បីឲ្យគាត់ជួយដោះស្រាយ ។ ទៅទីនោះមានមិត្ត ខេង ដែលជាអ្នកទទួលខុសត្រូវដូចនេះហើយ យើងត្រូវទាក់ទងគ្នាឲ្យជាប់ ។ បន្ទាប់ពីទទួលការណែនាំពីបងសារ៉ុម ហើយ ខ្ញុំ និង ខេង ក៏បានអនុវត្តសកម្មភាពជាបន្តបន្ទាប់ និងបានណែនាំយុទ្ធជនពីរនាក់ទៀត ដែលមានការស្មុគស្មាញនឹងរឿងហូបចុក ។ ខេង បាននាំអ្នកទាំងពីរលួចអង្ករ លួចដកដំឡូង និង



ជនរងគ្រោះដែលខ្មែរក្រហមចាប់ឃុំឃាំង នៅមន្ទីរសន្តិសុខស-២១ ។ អ្នកទាំងអស់ត្រូវ

បេះដូងហូប ។ ដល់ខែកញ្ញា ឆ្នាំ១៩៧៥ អាន នីរសារបស់ សារ៉ុម បានមកសួរ ខេង ថាពង្រីងកម្លាំងបានប៉ុន្មាននាក់ហើយ? ខេង ប្រាប់ថា បានពីរនាក់ ។ អាន បានប្រាប់ ខេង ថា បងសារ៉ុម ឲ្យមកយកកម្លាំងដែលកសាង បានទៅអប់រំ ។ និយាយហើយ អាន ក៏វិលទៅវិញ ។ យុទ្ធជនដែល ខេង បានដឹកនាំនោះមាន ឆេ, ខុន, និង យឿន ។

ខែតុលា ឆ្នាំ១៩៧៥ អង្គការបានដកកម្លាំងពីកងខ្ញុំអស់ចំនួន៣០នាក់ ទៅច្រូតស្រូវ ប៉ុន្តែខ្ញុំអត់ទៅទេ គឺនៅកន្លែង និងធ្វើសកម្មភាពតទៅទៀត ។ ពីមួយថ្ងៃទៅមួយថ្ងៃ បក្សពួករបស់ខ្ញុំចេះតែធ្វើសកម្មភាពបំផ្លាញជារៀងរាល់ថ្ងៃ លុះធ្វើញឹកញាប់ពេកទៅកងហាខ្ញុំបានហៅខ្ញុំ




បានសម្លាប់ ក្រោយពេលឆ្មាំគុកសួរចម្លើយរួច ។

ទៅអប់រំកសាងដោយឈប់ឲ្យធ្វើទៀត ។ សកម្មភាពក៏ចេះតែធ្វើជារៀងរាល់ថ្ងៃ ប្រហែលជាមួយខែ អង្គការក៏បានដកមួយក្រុមទៀតទៅធ្វើស្រែអំបិលក្នុងនោះក៏មានខ្ញុំដែរ ។ ទៅទីនោះខ្ញុំក៏បានជួបនឹងខ្សែរបស់ខ្ញុំឈ្មោះ បើន និង បងពៅ បានទាក់ទងគ្នាធ្វើសកម្មភាពជាបន្តបន្ទាប់ទៀត ។ បងពៅ បានប្រាប់ថា គាត់ទាក់ទងបានខ្សែថ្មីដែលមានឈ្មោះ នារីសារ៉េត និង នារីស៊ន ។ ពេលខ្ញុំទៅធ្វើការជាមួយ បើន នៅស្រែអំបិលខ្ញុំក៏បានជួបនឹងនារីពីរនាក់នោះ ។ ក្រោយមក បងសារ៉ុម បានមកដល់ស្រែអំបិលហើយក៏បានហៅខ្សែរយៈទាំងអស់មកប្រជុំ ។ នៅស្រែអំបិលនោះមានមិត្ត សារ៉េត និងមិត្ត ស៊ន ជាអ្នកដឹកនាំធ្វើសកម្មភាព ។ មិត្ត គេន ដឹកនាំធ្វើសកម្មភាពជាមួយឈ្មោះ ជឿន ។ បងសារ៉ុម បានប្រាប់ថា គេន ជាអ្នកដឹកនាំកន្លែងរោងម៉ាស៊ីនកិនស្រូវដោយឲ្យយកគ្រួសទៅដាក់ក្នុងអង្ករ និងលាក់អង្ករទុកដើម្បីត្រៀមសម្រាប់កម្លាំងយើងដើម្បីងើបប្រឆាំង ។ បន្ទាប់មកគាត់ក៏ត្រូវអង្គការយកទៅរៀនសូត្រ គាត់បានប្រាប់ពេលគាត់ត្រឡប់មកវិញ គាត់នឹងប្រាប់ពីផែនការផ្សេងៗទៀត ។ ខ្ញុំធ្វើការធម្មតាបានប្រហែល២០ថ្ងៃបងសារ៉ុម ក៏មកវិញហើយក៏ហៅយើងទៅប្រជុំទៀត ដោយនិយាយពីរឿងខ្សែទាក់ទងគ្នាគាត់ដែលមាន តាឆោម, ហុក, ស៊ុម និង ឆុន ។ ឯនៅយោធាតំបន់មាន បងសាទ និងបង ជ័យ អ្នកទាំងនេះជាអ្នកមានទំនាក់ទំនងជាមួយយួនខាងជើងគោក និងកំពុងតែរៀបចំកម្លាំងទាក់ទងគ្នាឲ្យដឹងពីផែនការរបស់យើង ដែលត្រូវធ្វើនៅឆ្នាំខាងមុខនេះ ។ បន្ទាប់មកគាត់ប្រាប់ខ្ញុំថា ឥឡូវយើងនៅការពារសមុទ្រត្រូវធ្វើសកម្មភាពដើរដកចម្រូងចោលមួយថ្ងៃបន្តិចៗ ដើម្បីទុកប្រហោងឲ្យយួនចូល ។ ក្រោយពីស្តាប់ការណែនាំនេះហើយ ខ្ញុំ, បើន និង បងពៅ ក៏បានអនុវត្តតាមផែនការដែលគាត់ដាក់ជាបន្តបន្ទាប់ ។ ខ្ញុំបានទៅទាក់ទងជាមួយនារី សារ៉េត និង ស៊ន ពេលនោះ បើន សួរថា បងសារ៉ុម មានដែលនិយាយរឿងអ្វីប្រាប់ទេ? គាត់ថាមានដែរ គឺរឿងទាក់ទងគ្នា ។ បើន សួរទៀតថា ដឹងថាខ្ញុំ និង អាង ជាស្ពឺនឹង បងសារ៉ុម ទេ? គាត់ថាដឹងហើយ ។ បន្ទាប់គាត់ក៏ប្រាប់ពីខ្សែរយៈនៅស្រែអំបិលដែលមានដូចជា រីន និង ភាព ។ បានរយៈពេលពីរថ្ងៃខ្ញុំក៏ទៅទាក់ទងអ្នកទាំងពីរដើម្បីនិយាយពីរឿងធ្វើសកម្មភាព ។ ក្រោយមក ខ្ញុំបានរួមគ្នាធ្វើឲ្យខូចម៉ាស៊ីនបូមទឹកនៅស្រែអំបិលអស់មួយគ្រឿង ទម្លាយទ្វារទឹកបណ្តាលឲ្យខូចអំបិលអស់ប្រហែលជាង១០ស្រែ ។ ចំណែក សារ៉េត និង នារីស៊ន បានបំផុសខាងផ្ទៃក្នុងរបស់គេ ដើម្បីឲ្យកើតកូនចៅឲ្យកាន់តែច្រើនដើម្បីងាយស្រួលក្នុងការធ្វើសកម្មភាព ។ ខ្ញុំធ្វើស្រែអំបិលបានតែពីរខែក៏ត្រូវត្រឡប់មកកងវិញ ពេលមកដល់ ខ្ញុំដើរទៅសួរឈ្មោះ ខេង ថា បងសារ៉ុម មានដែលមក

ប្រាប់ពីផែនការទេ ខេង ប្រាប់ថាដែល ។ រឿងដែលគាត់ប្រាប់នោះមិនខុសពីរឿងដែលគាត់ ប្រាប់ខ្ញុំនៅស្រែអំបិលនោះទេ ។ តាំងពីពេលនោះមកខ្ញុំ, ខេង, ខុន និង យឿន បានទាក់ទងគ្នាធ្វើសកម្មភាពជាប់រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។ បងសារ៉ុម បានឲ្យការតាមរយៈ អាន ថាឥឡូវក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ នេះ ឆុន និង ស៊ីម ទៅទាក់ទងនៅស្រុកយួនតាមកាណូតនេសាទនៅកោះត្រល់ ។ ខាងជើង ដៃ និង ចេន ទៅទាក់ទងនៅស្រុកយួនតាមផ្លូវលក និងផ្លូវប្រជាវ ។ យើងខ្ញុំក៏ចាប់ផ្ដើមដើរធ្វើសកម្មភាពតៗរហូតមិនដាច់ ដោយដើរដកចម្រូងផ្កាប់ចោលតាមឆ្នេរសមុទ្រ ។ បន្ទាប់មក បងសារ៉ុម ក៏បានមកវិញហើយគាត់ហៅគ្នាខ្ញុំបួននាក់ ដែលមានខ្ញុំ, ខេង, ខុន និង យឿន មកប្រាប់ពីសកម្មភាពដែលត្រូវធ្វើនៅចុងឆ្នាំ ១៩៧៧ ។ គាត់ថា ខ្ញុំត្រូវដើរប្រាប់មិត្តទាំងអស់ឲ្យដឹងពីផែនការថ្មីដែលដឹកនាំដោយ បងដៃ និង បងសាទ ដែលគាត់ទៅទាក់ទងមកពីយួន ។ គាត់ថា យើងត្រូវរៀបចំផែនការខាងក្នុងឲ្យហើយកុំព្រួយពីការទាក់ទងខាងក្រៅ ព្រោះមានគេរៀបចំរួចជាស្រេចហើយ ។ ផ្នែកយោធាមានឈ្មោះ ដៃ, សាទ និង ចេន ជាអ្នកទទួលខាងផ្នែកជើងគោក ។ ខ្ញុំទទួលខាងរៀបចំកម្លាំងអុកឡុកតាមឆ្នេរសមុទ្រ និង ភេន ទទួលខាងផ្នែកសេដ្ឋកិច្ច ។ ឯ នារីសារ៉េត និង នារីស៊ិន ទទួលខាងទុកអាវុធ និងធ្វើសកម្មភាពតាមស្រែអំបិល ។ ឆោម ទទួលខាងបំបះបំបោរប្រជាជនឲ្យរត់ចូលព្រៃ និងត្រៀមស្បៀងទុក ។ ឆុន និង ស៊ីម អ្នកទាក់ទងទៅស្រុកយួន តាមជើងទឹក ។ ចំណែក តាហុក ជាអ្នកទទួលខុសត្រូវខាងថ្នាំពេទ្យ ។ គាត់បានឲ្យដកចម្រូងទៀតដកឲ្យទាល់តែអស់នៅមុខសញ្ញាកង១១៧ និងកង១១៨ និងបំផ្លាញចម្រូងទាំងនោះចោល ។ ខ្ញុំ និង ឆុន ធ្វើសកម្មភាពជាបន្តបន្ទាប់ លុះអង្គការដឹងក៏ហៅទៅរៀនសូត្ររឿងចម្រូងនេះ ។ ឈប់ធ្វើចម្រូងនេះ ខ្ញុំ, ខេង និង យឿន បានបំផ្លាញម៉ាស៊ីនកាណូតអស់មួយគ្រឿងទៀត ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ដៃ បានទៅទាក់ទងខ្មែរយួន លុះត្រឡប់មកវិញត្រូវអង្គការដឹងក៏ដកគាត់ចេញពីកង ។ តែ ដៃ មិនទាន់ឈប់ធ្វើសកម្មភាពទេ ព្រោះនៅទាក់ទងគ្នាបាន ហើយគាត់ព្រមទាំងទាក់ទងជាមួយឈ្មោះ ភេន ទៀត ។ ដៃ បានរៀបចំទុកដាក់អង្ករ និងគ្រាប់កាំភ្លើងដែល ភេន ឲ្យ ហើយគាត់លាក់បានចំនួនពីរឃ្លាំង ។ គាត់ថា ជឿន ជាអ្នកយកកម្លាំងទៅវាយរំដោះយកអ្នកជាប់ទោសនៅកំពត ហើយបំពាក់អាវុធដើម្បីវាយបដិវត្តន៍វិញ ដូចជា វាយមន្ទីរពេទ្យយកថ្នាំ សម្រាប់ចោលអ្នកដែលមិនត្រូវជាមួយនឹងគ្នាយើង ។ យើងធ្វើនេះគឺដើម្បីដណ្ដើមយកអង្ករ សម្ភារ រត់ចូលក្នុងព្រៃដើម្បីតស៊ូនយោបាយ ។ សកម្មភាពក្រុមខ្ញុំគ្មានអ្វីក្រៅពីដកចម្រូងទេ ។ រហូតដល់ខែមិថុនា ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនក្រុមរបស់ខ្ញុំជាបន្តបន្ទាប់ដែលមានដូចជា ដៃ, សាទ និង ចេន នៅសល់តែបងសារ៉ុម គាត់ក៏បានណែនាំខ្ញុំឲ្យផ្អាកធ្វើសកម្មភាពសិន ។ ដល់ខែធ្នូ ឆ្នាំ១៩៧៧ អង្គការបានចាប់ខ្លួនអ្នកក្បត់អស់មួយចំនួន ។ អង្គការបានដក បងសារ៉ុម ទៅកាន់វរសេនាធំ២៣៦ ។ បងសារ៉ុម បានហៅខ្ញុំ, បងជន, ខេង និង អេង ទៅណែនាំថា ឥឡូវដល់វេលាវាយខ្មាំងហើយគឺវាយយួន ។ ខ្មែររបស់យើងមានពីរនាក់ឈ្មោះ ឡាវ និង ផល អ្នកទាំងពីរនេះអ្នកដឹកនាំធ្វើសកម្មភាពនៅលើសមរភូមិក្នុងការធ្វើឲ្យខូចខាតកម្លាំងបដិវត្តន៍ ។ អេង និង បងជន បានទៅជួបនឹងខ្មែរដែលឈ្មោះ ឡាវ និង ផល ដើម្បីនិយាយគ្នាពីខ្មែរយៈក្បត់ ។ និយាយរៀបរាប់រឿងរ៉ាវប្រាប់ទៅអ្នកទាំងពីរហើយ ឡាវ ក៏បានប្រាប់ទៅវិញថា គាត់ក៏បានទទួលផែនការពី បងសារ៉ុម ដែរ ។ បងសារ៉ុម បានប្រាប់ ជន, ផល និង អេង ឲ្យបំផុសបំផុលកម្លាំងផ្ទៃក្នុង និងបំពាក់បំប៉នដល់ជួរកម្មាភិបាល និងជួរយុទ្ធជនឲ្យធ្វើសកម្មភាពនៅតាមសមរភូមិ ។ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៨ បងជន បានឲ្យខ្ញុំធ្វើសកម្មភាពដូចជា ធ្វើឲ្យបាក់កាំភ្លើង យកគ្រាប់បោះចោល និងរត់ចោលសមរភូមិ ។ ក្រោយបានស្ដាប់ការណែនាំហើយ ខ្ញុំ, ខុន និង យឿន បានយកគ្រាប់អឹម៧៩មួយកេស បេ៤០ និង៤១ បានម្នាក់ ៥ គ្រាប់យកទៅទម្លាក់ចោលក្នុងទឹក ។ នៅពេលទៅវាយខ្មាំងនៅសមរភូមិ ខ្ញុំគិតតែបាញ់ផ្ដេសផ្ដាសដើម្បីឲ្យអស់គ្រាប់ ។ ពេលបាញ់ហើយ ខេង ក៏នាំរត់មកក្រោយបួននាក់ ពេលរត់មកមិត្តយើងឃើញក៏រត់តាមពីក្រោយអស់មួយចំហៀង ។ ក្រោយមក អង្គការបានរៀបចំកងទ័ពសាជាថ្មី ខ្ញុំត្រូវបានដាក់ទៅកងអន្តរាគមន៍វរសេនាធំ២៣៨ ជាមួយ អេង និងផល ដែលមាននាទីជាកងរយ ហើយយុទ្ធជនឈ្មោះ ស៊ើន និង ណូយ ជាខ្មែររបស់ខ្ញុំ ។ អង្គការបានឲ្យខ្ញុំរៀននយោបាយពីសភាពការណ៍បច្ចុប្បន្នរយៈពេលមួយអាទិត្យ ហាត់បច្ចេកទេសយោធាកន្លះខែទៀត ។ ពេលដែលកំពុងហាត់នោះ អង្គការដក បងឡាវ មកកងអន្តរាគមន៍ដែរ ។ ពេលហាត់ ខ្ញុំបានធ្វើ

ផ្ទុះកាំភ្លើងបេមួយគ្រាប់ដោយសារ បងឡាវ ឲ្យសាកមើល ហើយក៏ត្រូវមិត្តយើងគ្រោះថ្នាក់បីនាក់តែមិនស្លាប់ទេ ពេលកើតមានរឿងនេះ បងឡាវ បានជួយដោះស្រាយឲ្យខ្ញុំបានរួចខ្លួន ។ ក្រៅពីនេះ ខ្ញុំបាញ់ឲ្យត្រូវគោប្រជាជនបាក់ជើងអស់មួយក្បាលទៀត ។ ក្រោយមក អង្គការបានលើកទិសដៅទៅវាយយួនខ្ញុំក៏ត្រូវទៅដែរ ។ នៅពេលជួបជាមួយ បងឡាវ ស្រាប់តែអ្នកយកបាយមកប្រាប់ថាខ្មាំងបាក់មកច្រើនណាស់ បងឡាវ ធ្វើសកម្មភាពមិនឲ្យកម្លាំងទៅទប់ទេ ។ គាត់ឲ្យមួយក្រុមទៅទប់បណ្ដាលឲ្យខូចខាតកម្លាំងអស់មួយចំនួន ។ ក្រោយពីចប់ហើយ បង សារ៉ុម បានហៅមេៗទៅប្រជុំក្រោយពីបង ឡាវ ត្រឡប់មកពីប្រជុំវិញ គាត់ក៏ហៅខ្ញុំនិងអ្នកឯទៀតទៅប្រជុំម្ដងទៀត ។ ដោយ បងឡាវ ប្រាប់ថា យើងគ្មានសមត្ថភាពវាយបដិវត្តន៍ តែយើងត្រូវធ្វើសកម្មភាពតទៀតដើម្បីឲ្យវិចរិលបដិវត្តន៍ ។ ក្រោយទទួលផែនការ បង ផល បានឲ្យខ្ញុំ, ខុន និងមិត្តយើងយកគ្រាប់បែកទៅចងនៅផ្លូវដែលមិត្តយើងដើររាល់ថ្ងៃ ។ បងផល ឲ្យខ្ញុំបីនាក់នេះ ទៅលួចដកដំឡូងនារីនៅភ្នំអង្គោលចោលឲ្យអស់ ។ ខែមីនា ឆ្នាំ១៩៧៨ អង្គការចាប់ឈ្មោះ សារ៉ុម ។ ក្រោយមក អង្គការរៀបចំកម្លាំងទៅវាយសមរភូមិ ទៅទីនោះ គ្នាខ្ញុំក៏បានធ្វើសកម្មភាពនៅក្នុងសមរភូមិដែរ ។ វាយខ្មាំងបានតែបួនថ្ងៃ អង្គការដកឲ្យរៀនសូត្រដកពិសោធអស់បីថ្ងៃ ហើយសម្រាកប្រាំថ្ងៃ រួចហាត់បច្ចេកទេសបីថ្ងៃទៀត ។ ចប់ការហ្វឹកហាត់ហើយ អង្គការរៀបចំកម្លាំងឲ្យទៅវាយខ្មាំងនៅតាកែវ ស្រុកគិរីវង្ស ពេលនោះក្រុមខ្ញុំក៏ត្រូវបែកគ្នា ។ មានតែ ខ្ញុំ, បងឡាវ, បងផល, យឿន និង ខុនទេ ដែលត្រូវមកតាកែវ ក្រៅពីនោះត្រូវទៅតំបន់កំពត ។ មកដល់តាកែវបានបីថ្ងៃក៏រៀបចំកម្លាំង វាយខ្មាំង រៀនសូត្រនយោបាយបដិវត្តន៍ និងសភាពការណ៍ខ្មាំងអស់បីថ្ងៃ ។ រយៈពេលនោះដែរ បងឡាវ បានហៅគ្នាខ្ញុំទៅប្រជុំប្រាប់ ដោយណែនាំមិត្ត រីន ដែលជាខ្សែរយៈរបស់បង សារ៉ុម ។ ក្នុងពេលប្រជុំនោះ បងឡាវ ក៏ដាក់ផែនការឲ្យធ្វើសកម្មភាពទាំងអស់គ្នា ពីផែនការក្បត់ទៅទៀត ។ ខ្ញុំត្រូវបែកពីគេទៅសមរភូមិ ដល់ពេលផ្ទុះអាវុធភ្លាមខ្មាំងយួនក៏បាញ់មកច្រើន តែខ្ញុំមិនហ៊ានធ្វើអ្វីទេ យករួចខ្លួនសិន ដល់កម្លាំងទីពីទៅក៏វាយខ្មាំងបាក់ទៅ ។ ពេលនោះកងភូមិ ភាគនៅខាងស្ដាំដៃខ្ញុំចេះតែ បាញ់អត់ឡើង បាញ់តែពីក្រោយខ្ញុំ ខ្ញុំក៏បាញ់កាំភ្លើង៤១ មួយគ្រាប់ចំកន្លែងរបួសម្នាក់ ខ្ញុំបាញ់អ៊ឹម៧៩ អស់៤គ្រាប់ ហើយក៏ស្ងាត់ទៅ ។ ស្ងាត់ហើយខ្ញុំមើលទៅស្លាប់អស់ពីរនាក់ និងរបួសម្នាក់ ។ ពេលឡើងទៅភ្នំយួន ខ្ញុំក៏រត់មកក្រោយវិញ ហើយកងភាគនៅជិតខ្ញុំក៏រត់មកតាមខ្ញុំអស់មួយចំនួន ។ ស្អែកឡើងកងទ័ពមកក្រោយវិញរៀនសូត្រពិសោធទាំងអស់គ្នា ។ សម្រាកបានមួយយប់អង្គការដកឲ្យទៅវាយនៅសមរភូមិទន្លេបាសាក់ ។ នៅពេលធ្វើសកម្មភាពនៅសមរភូមិ ខ្ញុំបានបង្អត់បាយមិត្តយើងបីថ្ងៃ និងធ្វើឲ្យលិចទូកបាត់ស្មុគបាយមួយចំនួន ។ ចប់នៅសមរភូមិបាសាក់ហើយ អង្គការបើកការរៀនសូត្រទៀត ។ ចេញដំណើរអស់រយៈមួយយប់ទៅសម្រាកនៅស្រុកស្អាង មួយយប់បានឡានមកដឹកយកទៅ ។ ពេលនោះ បងឡាវ បានហៅខ្ញុំ និងខុន ទៅណែនាំថា បក្សពួករបស់យើងបែកគ្នាអស់ ហើយនៅសល់តែយើងបីនាក់ទេ ។ តែយើងមិនទាន់ឈប់ធ្វើសកម្មភាពទេទៅកន្លែងណាធ្វើកន្លែងនោះទាល់តែស្លាប់អស់ ។ ដល់ពេលចេញដំណើរមកដល់ភូមិភាគបូព៌ា អង្គការឲ្យសម្រាកបានពីរថ្ងៃដើម្បីរៀបចំកម្លាំងវាយសមរភូមិនោះ គឺសម្រាកនៅស្រុកសំរោង ខេត្តស្វាយរៀង ។ ពេលខ្ញុំទៅដល់ទីនោះ ក៏គ្រុន ហើយដេកនៅពេទ្យ «ព.១៧» ភ្នំពេញ ជិតមួយខែ ។ នៅក្នុងអង្គភាពខ្ញុំជាអ្នកដាំបាយឲ្យមិត្តយើង ។ មួយអាទិត្យក្រោយមកខ្ញុំបានទៅវាយខ្មាំងនឹងគេ ហើយក៏បានជួបនឹង បងឡាវ ដោយគាត់បានប្រាប់ថា ផល ត្រូវរបួសទៀតហើយ តែយើងនៅតែធ្វើសកម្មភាព ។ ដល់ពេលចូលដល់សមរភូមិ បងសាន បានដកខ្ញុំទៅការពារមិត្តនៅត្រចៀក ពេលនោះខ្ញុំបានធ្វើសកម្មភាពបាញ់ស្លាប់មិត្តយើងម្នាក់ និងរបួសពីរនាក់ ហើយអង្គការក៏បានហៅខ្ញុំទៅសួរខ្ញុំថា ប្រឡំដោយមិនបានទាក់ទងគ្នា ។ ខ្ញុំក៏ធ្វើពុតជាឈឺ ហើយបានបំផុសយុទ្ធជនដែលឈឺមួយចំនួនកុំឲ្យជាទៅប្រយុទ្ធ ដោយបំភ័យពីការស្លាប់ ។

ក្រោយមក នៅខែមិថុនា ឆ្នាំ១៩៧៨ អង្គការបានផ្លាស់សមរភូមិពីស្រុកសំរោង ទៅស្រុករមាសហែក តែអ្នកឈឺអង្គការមិនបានបញ្ជូនទៅទេ ។ ចំណែកខ្ញុំ និងបងឡាវ អង្គការឲ្យទៅវាយនឹងគេទាំងពីរលើក ។ នៅទីនោះ ខ្ញុំមិនបានធ្វើសកម្មភាពអ្វីទេ ។ តែពេលនោះខ្ញុំត្រូវរបួសដេកពេទ្យ «ព-១៧» ភ្នំពេញ រយៈពេល ១០ថ្ងៃក៏ជាសះស្បើយ ។ ក្រោយមក បងឡាវ បានហៅខ្ញុំទៅជួប

ទាំងអស់គ្នា បងផល និង បងរីន ណែនាំពីផែនការគេទៅទៀតថា ទី១ ផល, រីន, និងខ្ញុំ ត្រូវបន្តធ្វើសកម្មភាពបំផ្លាញកម្លាំងបដិវត្តន៍ឲ្យបាន ជាបន្តបន្ទាប់ ។ ពេលនោះ បងរីន បានទាក់ទងខ្មែររបស់គាត់ដែល មាន ឈ្មោះ ណន, ខេន និង បើង ។ ទាក់ទងបានហើយ ឡាវ និង រីន បានហៅមកជួបជុំគ្នាទាំងអស់ដើម្បីធ្វើសកម្មភាពទៅតាមមុខសញ្ញា របស់ខ្លួន ហើយផែនការនោះគឺធ្វើយ៉ាងណាឲ្យតែខូចខាតកម្លាំង បដិវត្តន៍ ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ ក្រោយពីចាត់តាំងហើយ អង្គការឲ្យមកសមរភូមិវិញ ។ បងផល បានណែនាំឲ្យធ្វើសកម្មភាព បំផ្លាញកម្លាំងបដិវត្តន៍ ខ្ញុំក៏បានធ្វើតាមដែលគាត់បានប្រាប់ ។ ខ្ញុំ បានធ្វើឲ្យមិត្តទាំងបីនាក់គ្រោះថ្នាក់គឺរបួសពីរនាក់ស្លាប់ម្នាក់ ។ ក្រោយ មក បងផល ត្រូវខ្មាំងផ្លោងត្រូវ ហើយក៏ស្លាប់នៅពេលនោះទៅ ។ អង្គការបានដូរមុខសញ្ញាឲ្យកង២៣០ ទៅស្រុកសំរោងវិញ ហើយ ពេលនោះអង្គការបានរំលាយកងពល២៣០ ចូលក្នុងកងពល៧០៣ ទាំងអស់នៅខែសីហា ឆ្នាំ១៩៧៨ ។ ពេលរំលាយនោះ ខ្ញុំក៏បាននៅ កងជាមួយបង រីន និង មិត្តខេន ហើយខ្ញុំក៏សួរគាត់ថាខ្មែររបស់ យើងទាក់ទងនៅប៉ុន្មាននាក់ គាត់ប្រាប់ថា នៅមានខ្លះដែរ ។ បងរីន បានណែនាំកម្លាំងថ្មីឲ្យស្គាល់ទៀត មានដូចជា វ៉ង, ម៉ើ, និង សឿន ។ ខ្ញុំបានដឹងខ្មែរ ហើយបានទាក់ទងគ្នាធ្វើសកម្មភាពរួមគ្នាតាមខ្មែរ ត្រៀម ។ ក្រោយមកទៀត បងរីន បានហៅខ្ញុំទៅប្រជុំជាមួយ ម៉ើ និង សឿន នៅក្រោយខ្មែរត្រៀម ។ រីន បានណែនាំពីផែនការក្បត់ ដោយឲ្យលាក់មីន ឲ្យបានច្រើនទុកធ្វើសកម្មភាពនៅខែប្រាំង ដើរ កម្ទេចបដិវត្តន៍ និងចាំដាក់មីនតាមថ្នល់នៅពេលដែល បងឌី និង បងពីន មកមើលសមរភូមិម្តងៗ ។ បន្ទាប់មក បងម៉ើ និងបងសឿន បានចាត់តាំងឲ្យ ណន, ខេន និង បើង ទៅពិនិត្យសមរភូមិដើម្បី បំផ្លាញបដិវត្តន៍ ដោយណែនាំថា បើពិនិត្យឃើញយួនយើងថា អត់ឃើញ ។ ពីរថ្ងៃក្រោយមក សឿន ស្នើបានកងអន្តរាគមន៍ វរសេនាធំបានមួយកងហាទៅវាយ ដោយមានមនុស្សរបួស និង ស្លាប់អស់មួយចំនួន ។ ក្រោយមកទៀត បងសឿន បានឲ្យខ្ញុំយក មីនទៅលាក់កុំឲ្យគេឃើញ ។ ដល់ខែកញ្ញា ឆ្នាំ១៩៧៨ ខ្ញុំ និង ខេន បានធ្វើតាមការណែនាំរបស់បងរីន និងបង សឿន ដោយធ្វើសកម្មភាពតាមខ្មែរត្រៀមប្រមៅ៉យ ដោយរាយការណ៍ថាខ្មាំងជីកត្រង់សេ នៅខាងមុខ ដើម្បីឲ្យផ្លោងកាំភ្លើងអស់គ្រាប់ ។ បន្ទាប់មកទៀត បំផ្លាញគ្រាប់អាគេ បងសឿន ឲ្យបាញ់ តែបាញ់មិនឲ្យដល់ខ្មាំងទេ ។ ហើយក្រោយមកខ្ញុំបានធ្វើសកម្មភាពដុតផ្ទះឲ្យខ្មាំងផ្លោងមកបណ្តាល ឲ្យត្រូវកម្លាំងបដិវត្តន៍មិត្តយើងថ្មីអស់បួននាក់ ។

ពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៨ បងសឿន និងបងម៉ើ បានហៅ បងរីន, ខេន, បើង, វ៉ង និងខ្ញុំ ទៅប្រជុំដាក់ផែនការម្តង ទៀតសម្រាប់ថ្ងៃធ្វើបុណ្យ ។ ដោយនាំកងអន្តរាគមន៍ទៅកាន់កន្លែង ដែលមានមីនច្រើន ។ គាត់ណែនាំបាន៦ថ្ងៃ ក៏ឃើញកងអន្តរាគមន៍ ឲ្យជូនទៅពិនិត្យសមរភូមិ ពេលនោះខ្ញុំអត់បានទៅទេ មិត្តខេន, បើង និង វ៉ង ជាអ្នកនាំទៅបាន៤ថ្ងៃអត់សម្រេចសមរភូមិនេះ ហើយមក ពិនិត្យមុខសញ្ញា បង ណន ទៀត ខ្ញុំក៏ទៅនឹងគេដែរ ។ អស់រយៈពេល បីយប់មិនសម្រេច អង្គការបន្ថែមឲ្យបីថ្ងៃទៀតបានសម្រេច ។ ពេលសម្រេចហើយ បងសឿន បានហៅខ្ញុំ រីន, ខេន, ណន និងបើង ទៅណែនាំ ព្រោះជិតដល់ថ្ងៃវាយខ្មាំងទៀតហើយ ។ ក្រោយមក បងរីន បានពង្រឹងកម្លាំងបានពីរនាក់ទៀត ឈ្មោះនារី ឡាវ និងនារី ហេន ។ ប្រាប់ហើយ បងរីន ហៅ ឡាវ និងហេន មកជួបខ្ញុំ និង ខេន ហើយក៏បានទទួលស្គាល់ថា ជាខ្មែរសម្ងាត់របស់យើង ។ នៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៧៨ ជាថ្ងៃបុណ្យអំណរខួបទី១៨ កំណើត បក្ស ។ ដល់ម៉ោងប្រហែល៩យប់ បងសឿន បានហៅខ្ញុំមកប្រាប់ ថា យប់ហ្នឹងធ្វើយ៉ាងម៉េចឲ្យបានតាមផែនការរបស់យើងដែលខ្ញុំ បានប្រាប់ពីមុន ។ ពេលគាត់ទៅផុតមួយសន្ទុះក្រោយមកក៏ផ្ទុះមីន មួយគ្រាប់ ពួកខ្ញុំក៏រត់មកដល់ប្រឡាយខាងក្រោយឃើញមិត្តយើង រត់ប្រសេចប្រសាចពេញវាលស្រែ ។ ពេលនោះមានមិត្តយើងមុខ ព្រួញខាងជើងមកទាក់ទងសួរខ្ញុំថា យ៉ាងម៉េចហើយ ហើយខាង គាត់អត់អីទេចូលដល់ហើយ ។ កំពុងតែទាក់ទងគ្នាស្រាប់តែកង អន្តរាគមន៍ស្រែកថា យួនមកពីក្រោយហើយ ពេលនោះខ្ញុំបាន ប្រាប់ឲ្យដកទ័ពមកក្រោយឲ្យអស់ ។ កើតរឿងដូចនេះហើយ ព្រឹក ឡើងបងវរសេនាធំហៅខ្ញុំទៅសួរថាពីណាឲ្យដក? ខ្ញុំថាអត់! គាត់ថា ថ្នាក់កងអនុសេនាធំ វរសេនាតូចមិនហ៊ានសម្រេចដកផង ឥឡូវមិត្ត ឯងទៅដោះស្រាយជាមួយអង្គការ ទៅខ្ញុំមិនដឹងទេ គាត់ក៏បញ្ជូនខ្ញុំ មកតាមខ្មែររយៈកងពល និងសេនាធិការរហូតដល់កន្លែងនេះតែ ម្តង ។ ខ្ញុំត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៧៨ ។

**អៀង ណារី**

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្ដី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្ដល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthpechet@dccam.org ។

**◆ ទីកន្លែង : អាគារ "ក" ជាន់លើ ◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ប៊ុន ពិន : «សូមតែរស់នៅជុំគ្រួសារ»

ប៊ុន ពិន អាយុ៥៩ឆ្នាំ ជាអតីតយោធាខ្មែរក្រហម សព្វថ្ងៃជាក្រុមប្រឹក្សាស្រុក រស់នៅឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ ពិន បានចូលបម្រើចលនាបដិវត្តន៍ខ្មែរក្រហមដំបូង នៅក្នុងឆ្នាំ១៩៧២ នៅស្រុកកំណើតរបស់គាត់នៅឃុំសេណារីឧត្តម ស្រុកព្រះស្ដេច ខេត្តព្រៃវែង ។

ពិន បានរៀបរាប់ថា គាត់មានបងប្អូនប្រាំបីនាក់ គឺប្រុសប្រាំ និងស្រីបីនាក់ ហើយគាត់ជាកូន ទីប្រាំពីរ ។ ឪពុករបស់ ពិន ឈ្មោះ ប៊ុន ពៅ (ស្លាប់នៅក្នុងឆ្នាំ១៩៨៥ ពេល ពិន មករស់នៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃជាមួយខ្មែរក្រហម) និងម្ដាយឈ្មោះ បួយ ដាន ។

កាលពីនៅវ័យក្មេង ឪពុកម្ដាយ ពិន បានយក ពិន ឲ្យទៅស្នាក់នៅវត្តសិរីសាគរដូនស្ដើង (ស្ថិតនៅចន្លោះពីភូមិធ្នង់ និងភូមិក្បឿង) ជាមួយព្រះសង្ឃដើម្បីរៀនអក្សរ និងលេខនព្វន្ធ ព្រោះនៅជំនាន់នោះសាលារៀនស្ថិតនៅក្នុងវត្តតែម្ដង ។ ពេល ពិន រៀនបានដល់ថ្នាក់ទី១០ (សង្គមចាស់) គាត់ក៏បានប្ដូរមកនៅរៀននៅសាលាស្ថិតនៅក្នុងវត្តទ្រាវិញ ។

ពិន បានឈប់រៀននៅត្រឹមថ្នាក់ទី៨ ដោយសាររដ្ឋប្រហារ ហើយស្រុកភូមិរបស់គាត់ចាប់ផ្ដើមកើតមានចលាចល និងមានសង្គ្រាម ។ បន្ទាប់ពីឈប់រៀន ម្ដាយរបស់ ពិន បានឲ្យ ពិន ទៅបួសនៅវត្តសិរីសាគរដូនស្ដើងដែលគាត់ធ្លាប់ស្នាក់នៅពីមុន ។ ពិន បួសបានប្រមាណជាងពីរវស្សា ក៏សឹកមកជាគ្រហស្ថវិញ ហើយនៅរដូវចម្រូត ឆ្នាំ១៩៧២ គាត់ក៏បានចូលព្រៃម៉ាគី តាមរយៈពូរបស់គាត់ឈ្មោះ ប៊ុន ពុំ (បាត់ខ្លួន) មេបញ្ជាការយ-៦ ប្រចាំការនៅព្រំដែនខាងត្បូង ក្នុងតំបន់២៤ ភូមិភាគបូព៌ា ។

ដំបូង ពិន ចូលទៅនៅក្នុងកង យ-៦ កងទ័ពតំបន់២៤ ដោយពេលនោះបែងចែកចេញជា បីយ រួមមាន យ-៤, យ-៥ និង យ-៦ (ដែលក្នុងមួយយស្មើនឹងមួយវរសេនាតូច) ។ ក្រោយមក អង្គការបានរៀបចំបញ្ចូល ពិន ឲ្យចូលទៅនៅក្នុងកងពល ៨០៥ ដែលមានឈ្មោះ សេន ជា មេបញ្ជាការ និង ឈ្មោះ ហួយ (សព្វថ្ងៃធ្វើជាចារ្យនៅវត្តដង្កោ ស្រុកបាភ្នំ ក្នុងខេត្តព្រៃវែង) ជា លេខា ។ នៅពេលនោះ ពិន ត្រូវបានបញ្ជូនឲ្យទៅឈរជើងនៅមុំអង្គ្រង ភូមិចាប និងត្រពាំងព្រាយ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដោយពេលនោះគាត់នៅជាយុទ្ធជន ។


ប៊ុន ពិន ជាសមាជិកក្រុមប្រឹក្សាស្រុក ថតនៅសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

រហូតដល់ឆ្នាំ១៩៧៧ កងរបស់ ពិន បានប៉ះទង្គិចជាមួយកងទ័ពវៀតណាមជាញឹកញាប់ ដូច្នេះហើយ ទើបមាន

មេបញ្ជាការបានចុះមកណែនាំឲ្យកងយោធាទាំងអស់ខិតខំការពារទឹកដីបន្សល់ទុកពីសម័យមុន កុំឲ្យយួនឈ្លានពាន គឺយើងការពារខ្លួន និងបន្តប្រយុទ្ធ ។ ចំណែកមេបញ្ជាខ្លះទៀតក៏លើកឡើងពីលទ្ធភាព ដែលឈានទៅវាយយកទឹកដីកម្ពុជាក្រោមមកវិញដែរ ។ ក្រោយមកនៅពេលមានការវាយប្រយុទ្ធគ្នា អង្គភាពរបស់ ពិន បានវាយផុតពីភូមិត្រពាំងព្រាយ ចូលទៅក្នុងទឹកដីវៀតណាម ហើយកងផ្សេងទៀត បានវាយចូលទៅដល់ផ្លូវខ្មៅ ឬផ្លូវកៅស៊ូរបស់វៀតណាមថែមទៀត ។ ពេលកងរបស់ ពិន វាយចូលទៅដល់ភូមិ ប្រជាជនវៀតណាមបានរត់គេចអស់ទៅហើយ ដោយបន្សល់ទុកតែសម្ភារប្រើប្រាស់ នង្គ័ល និងរនាស់ ប៉ុណ្ណោះ ។ ប៉ុន្តែភ្លាមនោះកងរបស់គាត់ក៏បានដកចេញមកវិញដែរ ព្រោះខាងកងទ័ពវៀតណាមបានវាយបកមកវិញ ។ ការប្រយុទ្ធគ្នានោះ បណ្តាលឲ្យកងយោធារបស់ខ្មែរក្រហមស្លាប់ជាច្រើន ដោយក្នុងមួយលើកៗមានចំនួនប្រមាណចាប់ពី បីទៅបួននាក់ឡើងទៅ ។

នៅខណៈនោះដែរ អង្គការក៏បានហៅមេៗមួយចំនួនទៅជួប តែបានបាត់ខ្លួនរហូត ធ្វើឲ្យសភាពការណ៍នៅក្នុងអង្គភាពរបស់គាត់ច្របូកច្របល់ ។ មកដល់ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយបុកខ្លាំង ពិន ក៏បានកាប់ដើមចេកជិះឆ្លងទន្លេមកក្បាលកោះកញ្ជើង (អ្នកលឿងក្រោម) ក្នុងស្រុកពាមជរ ហើយអង្គភាពរបស់គាត់បានបែកគ្នាចាប់តាំងពីពេលនោះមក ។ ពិន បានធ្វើដំណើរឆ្លងកាត់ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មកនៅម្តុំអន្លង់វិល ។ ប៉ុន្តែដោយសាររថក្រោះរបស់វៀតណាម និងរដ្ឋាភិបាលភ្នំពេញតាមមកពីក្រោយ គាត់ក៏រត់ទៅនៅខាងទន្លេសាបរយៈពេលបួនថ្ងៃ ។ នៅទីនោះ ពិន បាន ជួបកងពល៥១៩ ដឹកនាំដោយ តាយ៉ន (ក្រោយមក ឌុល សារឿន គ្រប់គ្រងនៅ សមរភូមិខាងជើងក្នុងស្រុកអូរជ្រៅ) ។

នៅឆ្នាំ១៩៨០ ពិន បានទៅរស់នៅជំរំចម្ការគ ស្ថិតនៅក្នុងស្រុកស្វាយចេក (បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ) ដែលគ្រប់គ្រងដោយខ្មែរក្រហម ។ នៅពេលនោះ ប្រធានជំរំឈ្មោះ ជន់ បានរៀបចំ ពិន ឲ្យយកប្រពន្ធ (នៅអង្គភាពផ្សេងគ្នា) ដោយមាន



ផ្លូវក្រាលគ្រួសក្រហមនៅក្នុងឃុំទំបន់ដាច់ ស្រុកត្រពាំងប្រាសាទ ភ្ជាប់ទៅភ្នំដងរែក ព្រំប្រទល់ជាមួយនឹងប្រទេសថៃ

ការឡើងចាប់អារម្មណ៍ និងប្តេជ្ញារក្សាគ្នាជាប្តីប្រពន្ធអស់មួយជីវិត ចំណែកជីវភាពគាត់ទទួលបានការឧត្ថម្ភពីអង្គការអន្តរជាតិ ។ រហូតមកដល់ឆ្នាំ១៩៨៣ កងទ័ពវៀតណាមបានបើកប្រតិបត្តិការវាយបោសសម្អាតកម្លាំងខ្មែរក្រហមនៅតាមបណ្តោយព្រំដែន ពិន បានទៅជំរំតាផ្ទឹក ឬសាយអេច នៅក្នុងដីថៃ ដោយគាត់នៅទទួលការឧត្ថម្ភស្បៀង មានដូចជា អង្ករ, ត្រីខ, ខ្លាញ និងសម្ភារមួយចំនួន ក្នុងមួយអាទិត្យម្តង រួមទាំងសេវាថែទាំសុខភាព ពីអង្គការយូ.នី.សេហ្វ ។ ចំណែកជំរំទាំងមូល គ្រប់គ្រងដោយភាគីខ្មែរក្រហមឈ្មោះ តាសុក ជាប្រធាន ។ នៅទីនោះ មានជនភៀសខ្លួនទាំងអស់ប្រមាណបីម៉ឺននាក់ ដែលអង្គការទទួលបន្ទុកជនភៀសខ្លួន រៀបចំឲ្យរស់នៅតាមសង្កាត់ (ដីឡូត៍) តែត្រូវសាងសង់ខ្ទមស្នាក់នៅដោយខ្លួនឯង ។

នៅឆ្នាំ១៩៨៤ ខ្មែរក្រហមបានជ្រើសរើស ពិន ឲ្យចូលមកនៅក្នុងអង្គភាពទ័ពវិញ រួចហើយបញ្ជូនឲ្យចុះមកនៅភ្នំព្រឹកជាមួយ នី កន ។ ក្រោយមក ខ្មែរក្រហមបានហៅ ពិន រួមទាំងប្រពន្ធកូនឲ្យទៅចូលរួមវគ្គរៀនសូត្រដែលរៀបចំដោយអង្គភាពទ័ពនៅខាងលិចអូរត្រាវ ។ បន្ទាប់ពីរៀនចប់ អង្គភាពនោះ បានបង្កើតទៅជាកងវរសេនាធំឯករាជ្យលេខ២៦ មានសមាជិកទាំងអស់១៧០នាក់ គ្រប់គ្រងដោយ តាម៉ុក តែម្តង ។ ពិន នៅកងឯករាជ្យលេខ២៦មួយរយៈ ខ្មែរក្រហមក៏ដកគាត់ឲ្យមកនៅក្នុងកងពល៨០១ គ្រប់គ្រងដោយ សារឿន វិញ ។ នៅឆ្នាំ១៩៨៥ ពិន ទទួលភារកិច្ចចុះទៅអប់រំពីនយោបាយ និងការតស៊ូរបស់ខ្មែរក្រហម ទៅដល់ប្រជាជននៅស្រុកស្រីសន្ធរ, ស្រុកកោះសូទិន ខេត្តកំពង់ចាម, ស្រុកពារាំង, ស៊ីធរកណ្តាល ខេត្តព្រៃវែង ។ ក្រៅពីការផ្សារអប់រំ កងរបស់ ពិន ដែលមានសមាជិកប្រមាណ២០នាក់ ត្រូវការពារអំពើចោរកម្មដូនដល់ប្រជាជនទៀត ។ កងរបស់ ពិន មិនបានស្នាក់នៅជាមួយប្រជាជននៅក្នុងភូមិទេ គឺត្រូវចេញមកដេកនៅតាមគុម្ពោតព្រៃនៅពេលថ្ងៃ ដើម្បីគេចចេញពីកងទ័ពវៀតណាម ហើយពេលយប់កងរបស់គាត់ត្រូវចូលទៅធ្វើការនៅក្នុងភូមិវិញ ។ ពេលខ្លះ ពិន ក៏ប៉ះទង្គិចជាមួយកងទ័ពវៀតណាមដែរ ហើយសមាជិកកងណាដែលរងរបួស ពិន ត្រូវសែងចូលទៅក្នុងព្រៃជ្រៅ ក្នុងខេត្តកំពង់ចាម ដើម្បីធ្វើការវះកាត់ ព្រោះខ្មែរក្រហមមានជំរំធំមួយនៅទីនោះ ដែលកងទ័ពវៀតណាមរកមិនឃើញ ។

ពិន ចុះធ្វើការនៅភូមិភាគបូព៌ារយៈបីឆ្នាំ ហើយក្រោយមកគាត់បានសហការជាមួយកងពល៨០២ ចុះទៅធ្វើការនៅជាប់ព្រំដែនជាមួយប្រទេសវៀតណាម ក្នុងស្រុកពញាក្រែក ខេត្តកំពង់ចាម, ស្រុកកំចាយមា ខេត្តព្រៃវែង និងស្រុករមាសហែក ខេត្តស្វាយរៀងវិញ ។ ពិន មិនដែលបានត្រឡប់ទៅជួបប្រពន្ធកូនទេ ហើយពេលគាត់ចង់ជួបម្តងៗគាត់ត្រូវទាក់ទងតាមសារទូរលេខ ។ យូរៗម្តង ទើបថ្នាក់លើបានហៅ ពិន ទៅរៀនរយៈពេលពីរបីថ្ងៃ ទៅមួយអាទិត្យ អំពីការឈ្លានពានរបស់របស់វៀតណាម និងយុទ្ធសាស្ត្រការពារទឹកដី ។

ក្រោយមក ពិន និងសមាជិកកងពល៨០១ ត្រូវបានអង្គការហៅត្រឡប់ទៅអង្គភាពនៅអន្លង់វែងវិញ បន្ទាប់ពីមានព្រឹត្តិការណ៍សម្លាប់ សុន សេន នៅឆ្នាំ ១៩៩៧ ។ មុនពេលទៅដល់ ថ្នាក់លើបានចាប់ខ្លួនមេបញ្ជាការកងពលរបស់ ពិន ឈ្មោះ សារឿន រួចទៅហើយ ហើយបានសុំដកហូតអាវុធពី ពិន និងឲ្យ ពិន នៅផ្ទះដោយមិនឲ្យធ្វើការងារអ្វីទាំងអស់ ។ ពិន បានគិតថា បើគាត់បន្តរស់នៅទីនោះទៀតគាត់នឹងស្លាប់មិនខាន ព្រោះ តាម៉ុក បានចាប់ប្រធានកងពលអស់មួយចំនួនហើយ ដូច្នេះហើយទើបគាត់បានសម្រេចចិត្តដឹកនាំកម្លាំងខ្មែរក្រហម៤៧នាក់ រួមជាមួយគ្រួសារកងទ័ពមួយចំនួនទៀត មកចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយសង្ឃឹមថា នឹងបានរស់ ។ ចំណែក ប្រពន្ធ និងកូន ដែលចេញមកមិនទាន់ ត្រូវ តាម៉ុក ចាប់យកទៅឃុំឃាំងទាំងអស់ ។ បន្ទាប់ពីចុះចូលជាមួយរដ្ឋាភិបាលរួចហើយ ទើប ពិន ដឹកនាំកម្លាំងវាយរហូតយកបានអន្លង់វែង ពីតាម៉ុក ទើបគាត់បានជួបប្រពន្ធ និងកូនវិញ រួចហើយក៏នាំគ្នាមករស់នៅឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ រហូតមកដល់បច្ចុប្បន្ន ។

ចុងក្រោយ ពិន បានមានប្រសាសន៍ថា “ជីវិតគាត់ធ្លាប់ទទួលការរងគ្រោះច្រើនលើកពេលនៅជាយុទ្ធជន តែនៅពេលដែលបែកបាក់ប្រពន្ធកូន និងពេលដែលប្រពន្ធកូនជាប់គុក រឹតតែលំបាកទៅទៀត ។ គាត់បន្តថា ក្នុងឆាកជីវិតរបស់គាត់ គាត់នឹងមិនធ្វើកងទ័ព ធ្វើទាហានទៀតទេ ។ គាត់សូមលាឈប់ ហើយសូមតែបានរស់នៅជួបជុំគ្រួសារ ប្រពន្ធកូនប៉ុណ្ណោះ” ។ **សោម ប៊ុនថន**

# ការរងគ្រោះនៃវត្ថុបុរាណ ក្នុងពេលសង្គ្រាម និងអសន្តិសុខ

សង្គ្រាម និងអសន្តិសុខ បានបំផ្លាញប្រាសាទ និងវត្ថុបុរាណជាច្រើននៅក្នុងប្រទេសកម្ពុជា ហើយមានមនុស្សតិចតួចណាស់ប៉ុណ្ណោះដែលនៅចងចាំពីហេតុការណ៍ទាំងនោះ ដាក់ស្តែងដូចជាព្រះតេជគុណ ឈយ ភិល ។

ព្រះតេជគុណ ឈយ ភិល មានព្រះជន្ម៨១ព្រះវស្សា គង់នៅវត្តប្រាសាទបន្ទាយឆ្មារ ។ ព្រះអង្គមានស្រុកកំណើតនៅឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ ព្រះអង្គមានឪពុកឈ្មោះ ឈយ និងម្តាយឈ្មោះ រី ។


ប្រាសាទបន្ទាយឆ្មារដែលទ្រុឌទ្រោម ដោយសារមិនមានអ្នកថែរក្សា និងដោយសារសង្គ្រាម

កាលពីព្រះអង្គមានអាយុប្រាំឆ្នាំ ព្រះអង្គឃើញជនជាតិបារាំងជាច្រើនចូលមកភូមិរបស់គាត់ក្នុងគោលបំណងដេញឥស្សរៈ និងថៃ ។ ក្រោយមក សម្តេចព្រះ នរោត្តម សីហនុ បានដេញបារាំងទាំងនោះចេញទៅវិញ ។ ចំណែកប្រាសាទ ក៏នៅមានទ្រង់ទ្រាយល្អដែរ ដែលគិតមកដល់បច្ចុប្បន្នមានរយៈពេលជាង៦០ឆ្នាំហើយ ។ ព្រះអង្គមានសង្ឃដីកាថា «នៅក្នុងសម័យនោះពុំមាននរណាទៅរើរុះទេ ប្រសិនបើបែកបាក់ជ្រុះនោះ ក៏ដោយសារតែភាពចាស់ទ្រុឌទ្រោមនៃអាយុកាលតែប៉ុណ្ណោះ ។ ចំណែកឯរូបចម្លាក់មានរាប់រយក្នុងបរិវេណប្រាសាទ និងនៅក្នុងប្រាសាទ» ។

នៅក្នុងឆ្នាំ១៩៦០ ព្រះអង្គបានរៀបការប្រពន្ធនៅភូមិគោកសម្រោង ឈ្មោះ ព្រីន ភ្លើយ ដោយប្រកបរបរធ្វើស្រែ និងចម្ការ ។ នៅសម័យ លន់ នល់ ព្រះអង្គបានឮថា រូបចម្លាក់ជាច្រើន ដែលនៅរាយប៉ាយតាមទីធ្លាត្រូវបានប្រមូលយកមកទុកនៅក្បែរមាត់ស្ទឹង ដើម្បីការពារខ្លាចបាត់បង់ ។ ចំណែកឯរូបចម្លាក់នៅក្នុងប្រាសាទពុំសូវមានទេ ព្រោះត្រូវប្រមូលយកមកទុកដែរ គឺនៅសល់តែរូបចម្លាក់កប់ក្នុងដីដែលមានរូបចម្លាក់សត្វពោះធំៗមួយចំនួនតែប៉ុណ្ណោះ ព្រោះមិនដឹងជាយកទៅទុកនៅទីណា ។ នៅជំនាន់នោះក៏មានបាត់រូបចម្លាក់ដែរ ទោះបីមានឆ្មាំការពារប្រាសាទក៏ដោយ ។ រូបចម្លាក់មួយចំនួនបានបាត់ក្បាល ប៉ុន្តែមិនមាននរណាស្រាវជ្រាវរកឃើញទេ ។ នៅពេលនោះ ឆ្មាំយាមការពារប្រាសាទ ក៏បានបាញ់សម្លាប់ខ្លួនឯងដែរ ។ ចំណែកឯរូបចម្លាក់ដែលបានប្រមូលយកទៅដាក់នៅជិតស្ទឹង ក៏គ្មានអ្នកយកមកទុកនៅក្នុងប្រាសាទវិញដែរ ហើយក៏បាត់រូបចម្លាក់នោះរហូតមក ។

បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ព្រះអង្គបានចូលរួមជាមួយចលនាខ្មែរក្រហម និងមាន

តួនាទីជាមេភូមិ ។ ប៉ុន្តែក្រោយមក ព្រះអង្គបានចាកពីភូមិរហូតដល់របបខ្មែរក្រហមដួលរលំទើបត្រឡប់មកវិញ ។

ព្រះអង្គបានបន្តថា ក្រោយពីខ្មែរក្រហមដួលរលំ វត្ថុបុរាណជាច្រើនត្រូវប្រជាជន និងទាហាន ប្រមូលយកទៅព្រំដែនថៃ ។ ក្រោយមក ព្រះអង្គបានចូលធ្វើការជាមួយវៀតណាមវិញ ដោយមានតួនាទីជាប្រធានភូមិ ។ ព្រះអង្គបានបញ្ជាក់ថា ទាំងខ្មែរ ទាំងវៀតណាម បានលួចយកវត្ថុបុរាណដូចគ្នា ។ ព្រះអង្គបានឃើញអ្នកទាំងនោះដឹកវត្ថុបុរាណ ដោយយកស្រូវ ឬសំណាប គ្របពីលើរូបចម្លាក់ ។ ក្រោយមក ព្រះអង្គបានស្តីបន្ទោស និងបានណែនាំប្រជាជន និងបងប្អូនដែលបានប្រព្រឹត្តអំពើទាំងនោះ លើកលែងតែទាហានប៉ាវ៉ា ប៉ុណ្ណោះ ។

នៅឆ្នាំ១៩៨៧ ពេលព្រះអង្គធ្វើអាចារ្យវត្ត ទើបព្រះអង្គឃើញរូបចម្លាក់មួយចំនួនបានខូចខាតជាទម្ងន់ និងមួយចំនួនទៀតត្រូវប្រជាជនយកទៅលក់ និងត្រូវចោរលួច ។ ព្រះអង្គនៅចាំថា "នៅពេលប៉ាវ៉ាចូលស្រុក ក្នុងអំឡុងទសវត្សរ៍ឆ្នាំ៩០ វត្ថុបុរាណជាច្រើនបានបាត់បង់ ពិសេសគឺ រូបក្បាលនាគ" ។ នៅឆ្នាំ១៩៩៧ ព្រះអង្គបានឡើងធ្វើជាប្រធានឃុំ ទើបព្រះអង្គប្រកាសប្រាប់ប្រជាជនកុំឲ្យលក់វត្ថុបុរាណ និងត្រូវនាំគ្នាជួយរក្សា ព្រោះយើងពុំអាចធ្វើរបស់ទាំងអស់នោះបានទេ ប៉ុន្តែនៅតែមានការលួចជាបន្តបន្ទាប់ ។

ក្រោយមក ព្រះអង្គបានបួស ហើយក្នុងនាមជាព្រះសង្ឃ ព្រះអង្គបានត្រឹមតែប្រៀនប្រដៅប្រជាជនតែប៉ុណ្ណោះ ពុំអាចទប់ស្កាត់ការជួញដូរវត្ថុបុរាណបានទេ ។

ព្រះអង្គបានត្រឹមតែមានអារម្មណ៍សោកស្តាយពីការបាត់បង់រូបចម្លាក់ និងការខូចខាតរបស់ប្រាសាទ ។ ព្រះអង្គព្រួយបារម្ភថា នៅថ្ងៃមុខ កូនចៅនឹងមិនបានឃើញរបស់ដែលយើងធ្លាប់មានពីដូនតាទេ ។

**ឆាយ ជាទីន**



រូបយក្ស និង នាគ ដែលបាត់ក្បាល នៅប្រាសាទបន្ទាយឆ្មារ ។ រូបចម្លាក់ជាច្រើនត្រូវបានចោរលួច និងមួយចំនួនទៀតបានបាត់នៅក្នុងអំឡុងពេលសង្គ្រាម

# ជនជាតិព័រក្នុងរបបខ្មែរក្រហម

ព័រគឺជាជនជាតិមួយដែលមានដើមកំណើតមកពីភ្នំត្បែង ខេត្តព្រះវិហារ ។ នៅក្នុងសម័យខ្មែរក្រហមជនជាតិមួយនេះបាន រត់ទៅរស់នៅតាមតំបន់ផ្សេងៗ នៅក្នុងប្រទេសកម្ពុជា ។ នាពេលបច្ចុប្បន្ននេះ ជនជាតិព័របានមកតាំងទីលំនៅនៅតាមខេត្តផ្សេងៗ ដូចជា ខេត្តព្រះវិហារ និង ខេត្តបាត់ដំបង ។ អត្តសញ្ញាណរបស់ជនជាតិមួយនេះ បានបាត់បង់បន្ទាប់ពីការកើតឡើងនៃរបបខ្មែរក្រហម ក្នុងអំឡុងឆ្នាំ១៩៧៥ និង ឆ្នាំ១៩៧៩ ។

យាយ សេប អាយុ៧១ឆ្នាំ ដែលមានដើមកំណើតជាជនជាតិព័រ សព្វថ្ងៃរស់នៅភូមិឪឡឹក ឃុំរំដោះ ស្រុករវៀង ខេត្តព្រះវិហារ ។ គាត់បាននិយាយថា តាំងពីដូនតាមក ជនជាតិពណ៌ ប្រកបរបរធ្វើស្រែចម្ការ ដោយកាប់ទន្រ្ទានព្រៃចំការតូចៗ ដើម្បីយកដីមកធ្វើចម្ការ និងប្រកបរបរបរបាញ់សត្វ ។ ជនជាព័រគឺគោរពសាសនាព្រះពុទ្ធ តែក៏មានលក្ខណៈជាព្រហ្មញ្ញសាសនាផងដែរ ពីព្រោះអ្នកទាំងនោះក៏គោរពចំពោះអ្នកតា ដែលមានការធ្វើពិធីឡើងអ្នកតា ចាប់ពីខែមករា រហូតដល់ខែកុម្ភៈ ជារៀងរាល់ឆ្នាំ ដែលការសែនព្រេន មានដូចជា បាយ សម្ល ដើម្បីទទួលទានព្រលឹងអ្នកតា ព្រោះពួកគេជឿជាក់ថាការធ្វើបែបនេះដើម្បីឲ្យអ្នកតាសប្បាយចិត្ត តាមថែរក្សាជនជាតិខ្លួនឲ្យមានសេចក្តីសុខ និងដើម្បីបញ្ចៀសភាពខបទ្រុបចង្រៃឲ្យចាកចេញឆ្ងាយពីភូមិឋានរបស់ខ្លួន ។ ជាពិសេស មុនពេលទៅធ្វើការបរបាញ់សសត្វ អ្នកតែងតែធ្វើការសែនជាសំណែនផ្សេងៗ ដូចជា ស្រាស និងម្ហូបអាហារ ដោយមានការវាយស្គរ ។ ព័រ គឺជាជនជាតិមួយដែលមានវប្បធម៌ក្នុងការចែករំលែក នៅពេលដែលមាននរណាម្នាក់បរបាញ់សត្វព្រៃបាន អ្នកនោះតែងតែបែងចែកទៅឲ្យអ្នកជិតខាងរបស់ខ្លួនក្នុងចំណែកស្មើៗគ្នា ជាងនេះទៅទៀតនោះ ប្រសិនបើក្នុងគ្រួសារនោះមានស្រ្តីមានផ្ទៃពោះ គ្រួសារនោះនឹងបានចំណែកលើសបន្ថែមទៀត ។ ជនជាតិនេះមានតែភាសានិយាយ គ្មានភាសាសរសេរទេ ។ ដំបូងឡើយភាសារបស់ជនជាតិព័របានបង្កើតឡើង នៅពេលដែលអ្នកទាំងនោះចង់និយាយរឿងអ្វីដែលសំខាន់ៗ ប៉ុន្តែនាពេលក្រោយមក ភាសាព័របានគេយកមកនិយាយនៅពេលដែលមានការនិទានរឿងពីប្រពៃណី រវាងសមាជិកគ្រួសារ ។ យាយ សេប បានមានប្រសាសន៍បន្តថា ពិធីរៀបការបានប្រព្រឹត្ត ដូចជា ជនជាតិខ្មែរ ដែលកូនកម្លោះស្លៀកសារុង និង ពាក់ឈាង រីឯកូនក្រមុំស្លៀកសំពត់សូត្រដែលជាស្នាដៃរបស់ជនជាតិព័រ ។ ផ្ទះរបស់ជនជាតិព័រធ្វើឡើងដោយយកដើមកាចាងធ្វើជញ្ជាំង រនាបឫស្សី និងដំបូលប្រក់ស្បូវ ដែលសព្វថ្ងៃនេះជនជាតិព័រភាគច្រើននៅក្នុងភូមិឪឡឹកនៅតែបន្តរស់នៅផ្ទះបែបបុរាណនេះដដែល ។

ទន្ទឹមនឹងនេះ យាយសេប ក៏បានលើកឡើងពីជីវិតរបស់គាត់ដែលបានឆ្លងកាត់នៅក្នុងសម័យខ្មែរក្រហមថា គាត់មិនត្រូវបានជម្លៀសទៅកាន់តំបន់ណាទេ ប៉ុន្តែការហូបចុកគឺពិបាកណាស់ ដោយសារតែធ្វើការធ្ងន់លើសកម្លាំងដោយម្នាក់ទទួលបានតែបបររាវជាមួយអំបិលសម្រាប់ហូបតែប៉ុណ្ណោះ ។ គាត់ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើស្រែនៅក្នុងរដូវវស្សា ។ ជារៀងរាល់ម៉ោង៤ភ្លឺ គាត់ត្រូវប្រញាប់រួតរះចេញទៅស្រែ ដើម្បីលើកដីដាក់ក្នុងស្រែ និងដកស្ទូង អង្គការមិនដែលទុកឲ្យគាត់ទំនេរឡើយ បន្ទាប់ពីរដូវវស្សាចូលដល់ ។ ចំណែករដូវប្រាំងគាត់ត្រូវបានអង្គការចាត់តាំងឲ្យដើរជីកដំឡូងនៅក្នុងព្រៃជាមួយនឹងប្រជាជនដទៃទៀត ។ យាយសេប បន្តថា ការងារក៏ច្រើនតែហូបចុកមិនគ្រប់គ្រាន់ ហើយនៅពេលដែលឈឺម្តងៗ គ្មានថ្នាំសង្កូវគ្រប់គ្រាន់សម្រាប់ព្យាបាល គឺមានតែថ្នាំអាចម៍ទន្សាយដែលខ្មែរក្រហមធ្វើឡើងពីឫសឈើ ។ ជួនកាល គាត់លេបហើយក៏ជា ជួនកាលទៀតនោះធ្វើឲ្យជំងឺគាត់កាន់តែធ្ងន់លើសដើម ។ យាយសែប បានបន្តទៀតថា ទោះបីមានការសម្លាប់មនុស្សជាច្រើននៅក្នុងសម័យខ្មែរក្រហមក៏ដោយ តែគាត់មិនដែលបានឃើញសម្លាប់មនុស្សដោយផ្ទាល់ភ្នែកនោះទេ តែគាត់ធ្លាប់បានឃើញកម្មាភិបាលខ្មែរក្រហមហៅមនុស្សយកទៅសម្លាប់ ។ ជាភ័ព្វសំណាងរបស់គាត់ និងក្រុមគ្រួសារគាត់ដែលពុំមានសមាជិកក្នុងគ្រួសារណាមួយបានបាត់បង់ជីវិតនៅសម័យដ៏សាហាវយង់ឃ្នងនេះ ។ **ខង ស៊ីវនាថ**

# ការអប់រំ ក្នុង និងក្រោយរបបខ្មែរក្រហម

បន្ទាប់ពីឡើងកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមបានចាប់ផ្តើមកាច់ចង្កូតដឹកនាំប្រទេសរបស់ខ្លួនតាមបែបកុម្មុយនីស្តផ្តាច់ការ ដោយមានបំណងធ្វើយ៉ាងណាប្រែក្លាយប្រទេសឲ្យទៅជាប្រទេសសង្គមនិយមដ៏ស្អាតស្អំមួយ ពោលគឺគ្មានការបែងចែកវណ្ណៈសង្គម និងមិនមានការពឹងពាក់ប្រទេសដទៃ ។ ខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនចេញ ពីទីក្រុង និងតាមទីប្រជុំជននានាឲ្យទៅធ្វើការងារកសិកម្មនៅតាមទីជនបទ និងបានបែងចែកប្រជាជនឲ្យធ្វើការជាកង ក្រុម និង សហករណ៍ ។ មេដឹកនាំខ្មែរក្រហមបានកំណត់មហិច្ឆតារបស់ខ្លួនក្នុងការសម្រេចឲ្យបាននូវផែនការមហាលោតផ្លោះ មហាអស្ចារ្យ គឺធ្វើយ៉ាងណាសម្រេចឲ្យបាននូវផែនការបួនឆ្នាំដែលមានលក្ខណៈជឿនលឿនជាងប្រទេសកុម្មុយនីស្តមួយចំនួនទៀត ដូចជា ប្រទេសវៀតណាម និងចិន ជាដើម ។ ស្របពេលជាមួយគ្នានេះដែរ ខ្មែរក្រហមមិនបានគិតគូរពីហានិភ័យ ឬបញ្ហាប្រឈមនានា ដែលជាឧបសគ្គរារាំងដល់ដំណើរការនៃការអនុវត្តគោលនយោបាយកុម្មុយនីស្តផ្តាច់ការ មហាត្រឹមត្រូវ មហាអស្ចារ្យរបស់ខ្លួននោះឡើយ ។ មហិច្ឆតាមហាលោតផ្លោះ មហាអស្ចារ្យរបស់មេដឹកនាំខ្មែរក្រហម បានបង្កឲ្យមានវិនាសកម្មយ៉ាងអាណោចអាធ័ម ជាប្រវត្តិសាស្ត្រ ដោយរាប់បញ្ចូលទាំងជីវិតប្រជាជនរាប់លាននាក់ ហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងប្រទេស ទំនៀមទំលាប់ប្រពៃណី ការគោរពសាសនា និងការអប់រំ ដែលធ្វើឲ្យប្រទេសជាតិ ត្រូវធ្លាក់ក្នុងជ្រោះដ៏ខ្មៅងងឹត ។

ប្រសិនបើយើងពិនិត្យឲ្យស៊ីជម្រៅយើងឃើញថា មេដឹកនាំខ្មែរក្រហមបានបញ្ជ្រាបមនោគមវិជ្ជាយ៉ាងខ្លាំងក្លាទៅលើប្រជាជន និងកម្មាភិបាលរបស់ខ្លួន ហើយមនោគមវិជ្ជានេះពិតជាមានឥទ្ធិពលចាក់ឫសយ៉ាងជ្រៅទៅលើសតិអារម្មណ៍របស់ប្រជាជន និងធ្វើឲ្យប្រជាជនភាគច្រើនមានជំងឺបាក់ស្បាត ។ ការប្រើប្រាស់ពាក្យស្លោកគឺជាមធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយជាច្រើនទៀត ដែលមេដឹកនាំខ្មែរក្រហមបានអនុវត្តដើម្បីបញ្ជ្រាបមនោគមវិជ្ជា និងបំបាក់ស្មារតីរបស់ប្រជាជនឲ្យដើរតាមមាគ៌ាបដិវត្តន៍ដ៏មហាអស្ចារ្យ មហាត្រឹមត្រូវ មហាភ្លឺស្វាង របស់ខ្លួន ។ ជាក់ស្តែង ពាក្យស្លោករបស់ខ្មែរក្រហមមួយពោលថា "អង្គការគ្មានទេសញ្ញាបត្រ មានតែសញ្ញាឃើញ បើចង់បានបាក់ឌុប បាក់អង ត្រូវទៅយកនៅទំនប់ ប្រឡាយ" គឺជាពាក្យស្លោកមួយដែលឆ្លុះបញ្ចាំងយ៉ាងច្បាស់ឲ្យឃើញថា ខ្មែរក្រហមមិនបានយកចិត្តទុកដាក់លើការអប់រំទេ ។ ប៉ុន្តែ ខ្មែរក្រហមបានចាត់ទុកថា ការដ្ឋានការងារជាកន្លែងតែមួយគត់សម្រាប់រៀនសូត្រ និងលត់ដំខ្លួនទៅវិញ ។ ដោយសារតែពាក្យស្លោកមួយនេះ សាលារៀននៅទូទាំងប្រទេសត្រូវបានបិទទ្វារ អគារសិក្សាមួយចំនួនត្រូវបានកម្ទេចចោល យកធ្វើជាគុក ឬធ្វើជាកន្លែងស្តុកផលិតផលកសិកម្ម ។ ក្មេងៗដែលគ្រប់អាយុចូលរៀនទាំងអស់ត្រូវបានបញ្ជូនឲ្យទៅធ្វើការងារតាមកង ឬក្រុមនៅតាមការដ្ឋានការងារផ្សេងៗ ។ "សញ្ញាឃើញ" របស់ខ្មែរក្រហមគឺសំដៅទៅលើសមិទ្ធិផលផ្សេងៗដូចជា ប្រព័ន្ធធារាសាស្ត្រ និងផលិតផលកសិកម្ម ដែលកើតចេញពីពលកម្មហួសកម្លាំងរបស់ប្រជាជនកម្ពុជារាប់លាននាក់ ដែលខំធ្វើការងារទាំងថ្ងៃ ទាំងយប់ដើម្បីសម្រេចតាមផែនការមហាលោតផ្លោះ មហាអស្ចារ្យ ដើម្បីជាការដោះដូរជាមួយនឹងរបបបបរមួយវែក ពីរវែក និងការរក្សាជីវិតពីមួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ ។ កុមារនៅក្នុងរបបខ្មែរក្រហម មិនបានទទួលការអប់រំឲ្យបានត្រឹមត្រូវនោះទេ ។ ការកំភ្លើង ចប បង្គី ត្រូវបានប្រើប្រាស់ជំនួសឲ្យ ប៊ិច ឬសៀវភៅ ។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ កម្ពុជាបានចាប់ផ្តើមបើកបវេសនកាលឡើងវិញជាលើកដំបូង នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៩ ដែលរហូតមកដល់ពេលនេះគឺមានរយៈពេល៣៥ឆ្នាំហើយ ។ ដំណើរការនៃការស្តា និងអភិវឌ្ឍវិស័យអប់រំត្រូវប្រឈមនឹងឧបសគ្គជាច្រើន ដូចជា កង្វះខាតធនធានមនុស្ស គ្រឿងបរិក្ខារសម្រាប់រៀន និងបង្រៀនជាដើម ។ ក្នុងដំណើរការបើកសាលាឡើងវិញ រដ្ឋាភិបាលបានអំពាវនាវជ្រើសរើសគ្រូបង្រៀនក្នុងចំណោមអ្នកដែលវិលត្រឡប់ ចូលមករាជធានីភ្នំពេញវិញ និងអ្នកដែលចេះអាន និងចេះសរសេរ ។ ក្រៅពីអគារបាក់បែកដែល

សេសសល់ពីការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហម ការរៀន និងបង្រៀនគឺនៅតាមវត្ត នៅក្រោមផ្ទះប្រជាជន។

ស្ថិតក្នុងស្មារតីស្នេហាជាតិ អ្នកមានចំណេះដឹងដែលរួចរស់ជីវិតពីការកាប់សម្លាប់របស់ខ្មែរក្រហមមួយចំនួន បានស្ម័គ្រចិត្តសហការជាមួយរដ្ឋាភិបាលក្នុងការរៀបចំសរសេរកម្មវិធី និងសៀវភៅសិក្សាឡើងវិញ ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការស្តារវិស័យអប់រំនៅកម្ពុជា។ ដោយសារតែការខ្វះខាតសព្វគ្រប់បែបយ៉ាង ទាំងធនធានមនុស្ស និងសម្ភារសម្រាប់សិក្សា ក្រុមអ្នកស្ម័គ្រចិត្ត បានខិតខំសរសេរដោយដៃទាំងថ្ងៃទាំងយប់ក្រោមពន្លឺចង្កៀងប្រេងកាតមួយសន្លឹកម្តងៗ ដើម្បីចែកឲ្យគ្រូបង្រៀន និងសិស្សានុសិស្ស ដែលនៅពេលនោះអ្វីៗក៏គ្មាន គឺខ្វះសព្វគ្រប់រហូតដល់ប្រើធ្យូងធ្វើជាដីសក៏មាន។ សម្រាប់បវេសនកាលដំបូងនេះ កម្ពុជាទទួលបានសិស្សានុសិស្សសរុបទូទាំងប្រទេសបានត្រឹមតែជាង៩សែននាក់ និងគ្រូបង្រៀនត្រឹមតែជាង២ម៉ឺននាក់ប៉ុណ្ណោះ។ ដូចនេះហើយកម្ពុជាត្រូវបន្តធ្វើដំណើរវែងឆ្ងាយក្នុងការធ្វើកំណែទម្រង់ និងស្តារវិស័យអប់រំនេះឡើងវិញ។

ដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងមានការចូលរួមពីសហគមន៍ជាតិ អន្តរជាតិ រហូតមកដល់បច្ចុប្បន្ននេះ វិស័យអប់រំនៅកម្ពុជាមានការរីកចម្រើនទាំងបរិមាណ និងគុណភាពគួរឲ្យមានមោទកភាពយ៉ាងខ្លាំង។ គុណភាពអប់រំកំពុងត្រូវបានលើកកម្ពស់នៅតាមគ្រឹះស្ថានសិក្សា តាមរយៈការកែលម្អកម្មវិធីសិក្សា និងសៀវភៅសិក្សា។ ការលើកកម្ពស់គុណភាពគ្រូបង្រៀន ការកែលម្អការគ្រប់គ្រង ការធ្វើអធិការកិច្ច និងការកសាងសាលារៀន និងគ្រឹះស្ថានសិក្សា បំពាក់ដោយសម្ភារបរិក្ខារ និងឧបករណ៍បច្ចេកទេស ដែលនេះគឺជាវិធានការសម្រាប់ធានាឲ្យបាននូវគុណភាពអប់រំ ដើម្បីធានាឲ្យបានថា សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សា ហើយមានតម្លៃ និងគុណភាពសម្រាប់ទីផ្សារការងារនាពេលបច្ចុប្បន្ន។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ការងារអប់រំត្រូវបានជំរុញយ៉ាងខ្លាំងក្លានៅគ្រប់ផ្នែក និងគ្រប់ភូមិសិក្សា ដែលជាលទ្ធផលក្នុងឆ្នាំសិក្សា២០១៣-១៤នេះ បរិមាណសាលារៀន សិស្ស និស្សិត និងគ្រូបង្រៀនបានកើនឡើងគួរឲ្យកត់សម្គាល់។ កម្ពុជាបានបង្កើតសាលារៀននៅទូទាំងប្រទេសរហូតទៅដល់ចំនួន ១១.៨៦៥ ក្នុងនោះមានសាលាមត្តេយ្យចំនួន៣១៨៤, បឋមសិក្សាចំនួន៦៩៩៣, អនុវិទ្យាល័យ ចំនួន១២៤៤ និងវិទ្យាល័យចំនួន៤៤៤។ ប្រការដែលគួរឲ្យកត់សម្គាល់មួយទៀតគឺសាលារៀន ត្រូវបានសាងសង់នៅគ្រប់មូលដ្ឋានភូមិ ឃុំ ដើម្បីបង្កលក្ខណៈនិងផ្តល់ឱកាសឲ្យក្មេងៗបានរៀនសូត្រគ្រប់ៗគ្នា ពោលគឺយ៉ាងហោចណាស់បានបញ្ចប់ការអប់រំមូលដ្ឋាន៩ឆ្នាំ ស្របទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

រយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ គឺជាពេលវេលាដ៏យូរសម្រាប់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម ប៉ុន្តែ៣៥ឆ្នាំសម្រាប់ការស្តារវិស័យអប់រំនៅកម្ពុជាមិនមែនជារយៈពេលយូរនោះទេ ព្រោះកម្ពុជាបានចាប់ផ្តើមពីចំណុចសូន្យសម្រាប់វិស័យអប់រំ ហើយការអប់រំគឺជាការងារដែលត្រូវធ្វើយូរអង្វែងមិនចេះចប់ ពីជំនាន់មួយទៅជំនាន់មួយ។ ក្នុងនាមជាប្រជាជនកម្ពុជាម្នាក់ខ្ញុំសុំឲ្យប្រជាជនខ្មែរផ្សេងទៀត ក៏ដូចជាអ្នកនយោបាយទូទៅក្រឡេកទៅមើលអតីតកាលរបស់ខ្លួន និងយកអតីតកាលធ្វើជាមេរៀនសម្រាប់ការអភិវឌ្ឍខ្លួនឯង និងសង្គមជាតិ ជាជាងការប្រើប្រាស់ពាក្យ "ស្នេហាជាតិ" ជាទុនសម្រាប់ចិញ្ចឹមឆ្នាំង។ ជាការពិតណាស់ ប្រព័ន្ធអប់រំនៅកម្ពុជា ពុំទាន់អាចយកទៅប្រៀបធៀបទៅនឹងប្រព័ន្ធអប់រំនៅក្នុងបណ្តាប្រទេសអភិវឌ្ឍដទៃទៀតនៅលើសកលលោកបាននៅឡើយទេ ប៉ុន្តែដោយផ្អែកទៅលើសន្ទុះនៃការរីកចម្រើននាពេលបច្ចុប្បន្ន ការអប់រំនៅកម្ពុជានឹងឈានទៅដល់កម្រិតមួយដែលអាចទទួលបានការទទួលស្គាល់ពីអន្តរជាតិនាពេលអនាគត។ ការអប់រំគឺជាកូនសោសម្រាប់ដោះស្រាយរាល់បញ្ហាសង្គម និងសេដ្ឋកិច្ច។

**លន់ ដាលីន**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# វេទិកាអប់រំសាធារណៈពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ











# … នៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ ក្នុងខែកក្កដា ឆ្នាំ២០១៤











# ជនរងគ្រោះចូលរួមសវនាការបឋមបន្ថែមក្នុងសំណុំរឿ
# ក្នុងតុលាការកម្ពុជា កាលពីថ









# ឿង០០២ ដំណាក់កាលទី២ នៅអង្គជំនុំជម្រះវិសាមញ្ញ ថ្ងៃ៣០ ខែកក្កដា ឆ្នាំ២០១៤









# សំណុំរឿង០០៣ និង ០០៤ : និយមន័យនៃពាក្យអ្នកទទួលខុសត្រូវខ្ពស់បំផុតផ្នែកលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

***(តពីលេខមុន)***

***វិធាន១១ស្ទួនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងសេចក្តីសម្រេចបញ្ជូនសំណុំរឿង***

*តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី មិនបានដាក់បញ្ចូលបញ្ញត្តិជាក់លាក់ណាមួយនៅក្នុងឯកសារសម្អាងរបស់ខ្លួន ដែលកំណត់នូវយុត្តាធិការបុគ្គលដើម្បីចាត់ថ្នាក់បុគ្គលនោះឡើយ ។ ផ្ទុយទៅវិញ តុលាការទាំងពីរ ត្រូវបានផ្តល់អំណាចដើម្បីចោទប្រកាន់អ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការ និង បញ្ហាជាប់ពាក់ព័ន្ធ ។ អាស្រ័យហេតុនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី បានចោទប្រកាន់ជនសង្ស័យជាង ២០០នាក់ជាសរុប ។ ឆ្លើយតបនឹងសំណុំរឿងដែលទទួលបន្ទុកដោយតុលាការទាំងពីរ ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ បានអនុម័តិសេចក្តីសម្រេច១៥០៣ នៅខែសីហា ឆ្នាំ២០០៣ ដែលណែនាំតុលាការទាំងពីរផ្ទេរសំណុំរឿងទាក់ទងអ្នកដែលមិនត្រូវបាន ចាត់ទុកថា ជាមេដឹកនាំជាន់ខ្ពស់ ដែលទទួលខុសត្រូវ ទៅតុលាការជាតិដែលមានសមត្ថកិច្ច ។ ដំណើរនីតិវិធីដើម្បីផ្ទេរសំណុំរឿងនោះ ត្រូវបានគូសបញ្ជាក់នៅក្នុងវិធាន ១១ស្ទួន នៃវិធាននីតិវិធី និងភស្តុតាងក្នុងតុលាការទាំងពីរ តាមរយៈក្រុមប្រឹក្សាវិនិច្ឆ័យផ្ទេរសំណុំរឿង ។ វិធាន១១ស្ទួន របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ចែងថា ដោយអនុលោមតាមសេចក្តីសម្រេច១៥៣៤ (២០០៤) របស់ក្រុមប្រឹក្សាសន្តិសុខ ចៅក្រមត្រូវតែពិចារណា អំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទនៅពេលដែលខ្លួនកំណត់ថា តើការផ្ទេរសំណុំរឿងមានលក្ខណៈត្រឹមត្រូវឬទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា មិនមានពាក្យពេចន៍ក្នុងយុត្តាធិការស្រដៀងគ្នា និងវិធាន១១ស្ទួនរបស់ខ្លួននោះទេ ។ អាស្រ័យហេតុនេះ ការសម្រេចចិត្តបានផ្តោតលើការពិចារណាផ្សេងៗ ដូចជាការជំនុំជម្រះត្រឹមត្រូវ និងបញ្ហាសន្តិសុខទៅវិញ ។*

*តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានផ្ទេរជនដែលត្រូវចោទប្រកាន់១៨នាក់ ទៅកាន់តុលាការថ្នាក់ជាតិ ដោយបដិសេធចំពោះការផ្ទេរជនដែលត្រូវចោទប្រកាន់៨នាក់ផ្សេងទៀត ។ ព្រះរាជអាជ្ញាបានដកសំណើរបស់ខ្លួនចំពោះការផ្ទេរជនដែលត្រូវចោទប្រកាន់៥ នាក់ទៀត ។ សេចក្តីសម្រេចក្នុងការផ្ទេរជនដែលត្រូវចោទប្រកាន់តាមវិធានផ្ទេក្នុង១១ស្ទួនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានផ្ទេរកទៅរកការកំណត់ថា តើជនជាប់ចោទនៅក្នុងសំណុំរឿងនីមួយៗ ត្រូវបានចោទប្រកាន់ថាជា «មេដឹកនាំជាន់ខ្ពស់ អ្នកទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់តុលាការ ឬយ៉ាងណា ។ ជាងនេះទៅទៀត សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិនិច្ឆ័យផ្ទេរសំណុំរឿងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីដែលថា តើត្រូវផ្ទេរសំណុំរឿងនីមួយៗ ដែលតាំងដោយព្រះរាជអាជ្ញាត្រូវបានបកស្រាយថា ជា «សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ» ឬទេ ។*

*ក្នុងអត្ថន័យជាទូទៅ ឧក្រិដ្ឋកម្មកាន់តែធ្ងន់ធ្ងរ ហើយជនដែលត្រូវចោទប្រកាន់ មានកាន់តែច្រើនដែលជាប់ពាក់ព័ន្ធនោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ជនដែលត្រូវចោទប្រកាន់ទាំងនោះកាន់តែច្រើននឹងត្រូវបានរកឃើញថា មិនស័ក្តិសមដើម្បីផ្ទេរទៅតុលាការដទៃ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាវិនិច្ឆ័យរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានតស៊ូដើម្បីកំណត់រវាងសំណុំរឿង ដែលមានលក្ខណៈធ្ងន់ធ្ងរ ដែលចាំបាច់ត្រូវវិនិច្ឆ័យ*

នៅតុលាការ និងអ្នកដែលស័ក្តិសមត្រូវផ្ទេរទៅកាន់តុលាការដទៃ ។ កត្តាពាក់ព័ន្ធដែលត្រូវបានពិចារណាដោយក្រុមប្រឹក្សាវិនិច្ឆ័យរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រួមមានៈ ចំនួនជនរងគ្រោះ អំឡុងពេលនៃការប្រព្រឹត្តខក្រិដ្ឋកម្ម ទីតាំងនៃសកម្មភាពខក្រិដ្ឋកម្ម ហើយវិសាលភាពនៃការគ្រប់គ្រងអំណាចរបស់ជនជាប់ចោទពាក់ព័ន្ធនឹងការចោទប្រកាន់ នៅពេលដែលសម្រេចចិត្តថា តើការផ្ទេរទៅតុលាការផ្សេងទៀតមានលក្ខណៈត្រឹមត្រូវដែរឬទេ ។ ប្រសិនបើខក្រិដ្ឋកម្មនៅក្នុងបទចោទប្រកាន់ស្ថិតក្នុងទីតាំងតូច ហើយមានអំឡុងពេលកំណត់នោះ លទ្ធភាពនៃការផ្ទេរជនដែលត្រូវចោទទៅកាន់តុលាការផ្សេងអាចនឹងកើតឡើង ។ ដំណើរការនៃការវាយតម្លៃលើស្ថានទម្ងន់នៃបទចោទប្រកាន់នៅក្នុងសំណុំរឿងផ្សេងៗ មិនបានស្តែងឲ្យឃើញពីកាតព្វកិច្ចងាយស្រួលសម្រាប់ចៅក្រម នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនោះទេ ។ ដូចដែលបានកត់សម្គាល់ ដោយក្រុមប្រឹក្សាវិនិច្ឆ័យក្នុងរឿងក្តីរវាងព្រះរាជអាជ្ញាតទល់នឹង អាឌីមី និង ណូវ៉ាក់ វាមិនអាចធ្វើទៅរួចដើម្បីវាស់ស្ទង់ពីស្ថានទម្ងន់នៃខក្រិដ្ឋកម្មណាមួយដាច់ដោយឡែក ដែលផ្តោតជាសំខាន់ថា សំណើក្នុងការផ្ទេរជនជាប់ចោទត្រូវតែបង្ហាញនៅក្នុងបរិបទនៃសំណុំរឿងដទៃ ដែលជំនុំជម្រះដោយតុលាការ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាវិនិច្ឆ័យ មិនបានប្រៀបធៀបការចោទប្រកាន់ដដែលជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿងក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវីលើកមុន ដោយមិនបានធ្វើឲ្យមានភាពប្រាកដប្រជាចំពោះកម្រិតប្រៀបធៀបនោះទេ ។

## ការផ្ទេរដូប៊ូសិក និង ត្រឹបិក

សំណុំរឿងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដ៏ធ្ងន់ធ្ងរបំផុតទាំងពីរ ដែលត្រូវបានបញ្ជូនទៅកាន់តុលាការថ្នាក់ជាតិ គឺជារឿងក្តីរវាង ព្រះរាជអាជ្ញាតទល់នឹង ដូប៊ីសិក និងរឿងក្តីតទល់រវាងព្រះរាជអាជ្ញា និង ត្រឹបិក បានកាន់តំណែងជាច្រើននៅក្នុងជួរយោធារបស់ប្រទេសក្រូអាត ហើយអំឡុងពេលដែលជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់ គឺជាមេបញ្ជាការយោធានៅក្នុងប្រទេសបូស្នៀ ។ ជាងនេះទៅទៀត ការចោទប្រកាន់ បានចោទថា "ក្រុមប្រឆាំងនឹងភេរវកម្មដ៏ពិសេស" ដែលស្គាល់ថា ជា "ប៊ូកក័រ" ត្រូវបានបង្កើតដោយដូប៊ីសិក រួមជាមួយនឹងបុគ្គលដទៃក្រោមបទបញ្ជារបស់ ដូប៊ីសិក ទទួលខុសត្រូវៈ

> ការវាយប្រហារជាបន្តបន្ទាប់មកលើទីក្រុង និងភូមិដែលធ្វើឡើងនៅខែមករា និងខែមេសា ឆ្នាំ ១៩៩៣ ហើយបណ្តាលឲ្យមានជនស៊ីវិលជាង ១០០នាក់ស្លាប់ ការឃុំឃាំង និងការប្រព្រឹត្តយង់ឃ្នងរបស់មនុស្សមួយក្រុម ការបំផ្លិចបំផ្លាញភូមិ កន្លែងសាសនា ការប្លន់ និង ការជម្លៀសប្រជាជនដោយបង្ខំ ។

ដូប៊ីសិក ត្រូវបានចោទប្រកាន់ពីបទខក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងខក្រិដ្ឋកម្មសង្គ្រាម សរុប១៥យ៉ាង ដោយផ្អែកលើអង្គហេតុទាំងនេះ ។ ក្រុមប្រឹក្សាវិនិច្ឆ័យបានរកឃើញថា ខណៈដែលដូប៊ីសិក គឺជាមេដឹកនាំយោធា ហើយមានតួនាទីកាន់អំណាចនៅក្នុងសំណុំរឿងដទៃ ដែលបានជំនុំជម្រះនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ វាមិនគួរជាក់ស្តែងដែលថា គាត់គឺជាមនុស្សម្នាក់ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់បំផុត ដែលទទួលខុសត្រូវចំពោះខក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ហើយបានបញ្ជូនសំណុំរឿងនេះទៅកាន់ប្រទេសបូស្នៀហ្សឺហ្គោវីណា ។

ស្របពេលជាមួយគ្នានេះ សំណុំរឿងត្រឹបិក បានកត់សម្គាល់ថា ជាសំណុំជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ តាមវិធាន១១ស្ទួនរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ការចោទប្រកាន់នោះ បានចោទប្រកាន់ថា មីលូរាដ ត្រឹបិក គឺជាមន្ត្រីគយនៅក្នុងជួរកងកម្លាំងប្រទេសសែប៊ី ដោយកាន់តួនាទីមេកងយោធា ប៉ុន្តែថ្វីបើមានឋានៈធម្មតារបស់ខ្លួន ត្រឹបិក ត្រូវបានចោទប្រកាន់ គាត់ស្ថិតក្រោមអនុសេនីត្រីយ៍ ត្រាហ្គូ នីកូលិក ហើយគាត់ទទួលខុសត្រូវជួយគ្រប់គ្រងកងពលតូចវូនិកក្នុងចំណោមការងារផ្សេងៗ ។ ត្រឹបិក ត្រូវបានចោទប្រកាន់ថា ជាសមាជិកម្នាក់ក្នុងចំណោមក្រុមឧក្រិដ្ឋជនរួមពីរ ដាច់ដោយឡែកពីគ្នា ដែលគោលដៅរបស់ក្រុមនោះគឺជាការសម្លាប់ និងកប់កុមារ និងមនុស្សប្រុសម៉ូស្លីមបូស្នៀរាប់ពាន់

នាក់ ដែលត្រូវបានចាប់ខ្លួនពីតំបន់ស្រីប្រឹនីកា ចាប់តាំងពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៩៥ រហូតដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៥ និងការជម្លៀសជនម៉ូស្លីមបូស្នៀ ពីតំបន់ស្រីប្រឹនីកា និងតំបន់ ហ្សីប៉ា ទៅតំបន់ដទៃ ក្រៅពីសាធារណរដ្ឋស្រកស្កា ។ បទចោទប្រកាន់នោះ បានចោទថា ត្រឹបិក៖

> *បានជួយគ្រប់គ្រង សម្របសម្រួលឲ្យមានការឃុំឃាំងខ្លួន ការដឹកជញ្ជូន ការសម្លាប់ និងការកប់ជនម៉ូស្លីម និងធ្វើសកម្មភាពជាលក្ខណៈបុគ្គល ឬជាប់ទាក់ទងនឹងសមាជិកដទៃរបស់ក្រុមឧក្រិដ្ឋជនរួម និងការរួមគំនិត ដូចជា ការសម្លាប់និងកប់ជនម៉ូស្លីមពីតំបន់ស្រីប្រឹនីកា ។*

ជាក់ស្តែង ក្រុមប្រឹក្សាវិនិច្ឆ័យ បានរកឃើញថា ការជាប់ពាក់ព័ន្ធដ៏សំខាន់របស់ ត្រឹបិក ត្រូវបានចោទប្រកាន់នៅសាលាកុបាស៊ី នៅអូរាហូវ៉ាក នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៥ ជាទីដែលគាត់ និង ត្រាហ្គូ នីកូលិក ត្រូវបានចោទប្រកាន់ថា គ្រប់គ្រងកងកម្លាំងយោធាប៉ូលិស ដើម្បីគ្រប់គ្រងទណ្ឌិតជនម៉ូស្លីម និងដឹកជញ្ជូនទណ្ឌិតទាំងនោះទៅកាន់វាលស្រែនោះសម្លាប់ចោល ។ បទចោទប្រកាន់នោះ អះអាងបន្ថែមថា ត្រឹបិក បានសម្លាប់ទណ្ឌិតរាប់សិបនាក់ដោយខ្លួនគាត់ផ្ទាល់ ។ ត្រឹបិក ត្រូវបានចោទប្រកាន់ដោយអំពើប្រល័យពូជសាសន៍ ការរួមគំនិតដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ក្រុមប្រឹក្សាវិនិច្ឆ័យ បានកត់សម្គាល់ថា មិនមានលំដាប់លំដោយនៃឧក្រិដ្ឋកម្មនោះទេក្រោមយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ ដូច្នេះហើយ ការចោទប្រកាន់អំពើប្រល័យពូជសាសន៍ មិនអាចកែប្រែសំណុំរឿងឲ្យទៅជាការមិនអាចផ្ទេរសំណុំរឿងបាននោះទេ ។ ផ្ទុយទៅវិញ ក្រុមប្រឹក្សាវិនិច្ឆ័យ បានផ្តល់ទស្សនៈថា ខ្លួនត្រូវតែក្រឡេកមើលទៅការប្រព្រឹត្តឧក្រិដ្ឋកម្ម ព្រមទាំងស្ថានភាពផ្សេងៗដើម្បីកំណត់ពីស្ថានទម្ងន់នៃបទឧក្រិដ្ឋ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាវិនិច្ឆ័យនៅតែផ្ទេរសំណុំរឿងទៅតុលាការថ្នាក់ជាតិ នៅប្រទេសបូស្នៀហ្សឺហ្គោវីណា ដោយសារខ្លួនរកឃើញថា ក្នុងចំណោមមនុស្សរាប់រយនាក់ដែលជាប់ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍នៅស្រីប្រឹនីកា ។ កម្រិតនៃការទទួលខុសត្រូវរបស់ ត្រឹបិក មានកម្រិតទាប ដោយសារ ត្រឹបិក មិនមានតួនាទីសំខាន់ក្នុងការបង្កើតឲ្យមានសហឧក្រិដ្ឋកម្មរួម ឬតួនាទីក្នុងការធ្វើផែនការ ឬការធ្វើឲ្យផែនការសម្រេចនោះ ។

## ១) ការបដិសេធការផ្ទេរ មីកូស្សូវិក ឌីលិក និង លូគិក

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបដិសេធសំណើរផ្ទេរសំណុំរឿង ដែលធ្វើឡើងដោយព្រះរាជអាជ្ញា ទាក់ទងនឹងជនដែលត្រូវចោទទាំង៤ រួមមាន ត្រាហ្គោម័រ មីលូសូវិក, រាស៊ីម ឌីលិក, ស្រេដូជេ លូគិក និង មីលាន លូគិក ។ នៅក្នុងឆ្នាំ២០០៥ ក្រុមប្រឹក្សាវិនិច្ឆ័យរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបដិសេធសំណើរបស់ព្រះរាជអាជ្ញា ដើម្បីបញ្ជូនសំណុំរឿងរបស់ ត្រាហ្គោម័រ មីលូសូវិក ទៅកាន់តុលាការថ្នាក់ជាតិរបស់ប្រទេសបូស្នៀហ្សឺហ្គោវីណា ដោយសម្រេចថា ស្ថានទម្ងន់ទោសនៃបទល្មើសដែលត្រូវបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ បានតម្រូវថា សំណុំរឿងនាពេលបច្ចុប្បន្នគួរតែត្រូវបានជំនុំជម្រះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ជាពិសេស នៅពេលដែលឧក្រិដ្ឋកម្មទាំងនោះត្រូវបានពិចារណារួមគ្នា ។ មីលូសូវិក ត្រូវបានចោទប្រកាន់ជាមួយនឹងឧក្រិដ្ឋកម្ម១៨ករណីនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ដែលជាប់ទាក់ទងនឹងយុទ្ធនាការបាញ់សម្លាប់នៅសេរ៉ាជីវ៉ូ ចាប់ពីឆ្នាំ១៩៩៤ ដល់ ឆ្នាំ១៩៩៥ ។ បទចោទប្រកាន់នោះ រួមមាន ៖ កងកម្លាំងនៅក្រោមបញ្ជារបស់មីលូសូវិក ដែលបានបាញ់ជនស៊ីវិល ខណៈដែលជនស៊ីវិលទាំងនោះ កំពុងតែមើលថែបន្ទៃរបស់ខ្លួនតម្រង់ជួរគ្នា សុំនំប៉័ង ដងទឹក ចូលរួមពិធីបុណ្យសព ដើរទិញទំនិញនៅតាមផ្សារ ជិះរថភ្លើងដើរដោយអគ្គិសនី ជិះកង់ ប្រមូលឧស ឬដើរជាមួយក្មេង និងមិត្តភក្តិ ។ យុទ្ធនាការនោះមានបំណងធ្វើការបំភិតបំភ័យដល់ជនស៊ីវិល និងរួមបញ្ចូលការទម្លាក់គ្រាប់បែកកែច្នៃ ដែលមិនត្រូវបានបង្កើតឡើងសម្រាប់ប្រើប្រាស់ប្រឆាំងនឹងជនស៊ីវិល ។

ជារួម យុទ្ធនាការដែលដឹកនាំដោយមីលូសូវិក ដែល “ក្រៅពីការស្លាប់ និងការបង្ករបួសស្នាម មានដូចជា ការបង្កដោយការ

បាញ់គ្រាប់ផ្លោង និងការលបបាញ់ គឺការគំរាមកំហែងចំពោះការកាប់សម្លាប់ និងការបង្កគ្រោះថ្នាក់ ដែលបង្កការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ និងការប៉ះពាល់សតិអារម្មណ៍ដល់អ្នករស់នៅតំបន់សេរ៉ាជីវ៉ូ ។ ក្រុមប្រឹក្សាវិនិច្ឆ័យ បានកត់សម្គាល់ថា បទចោទប្រកាន់ខាងដើម មានលក្ខណៈជាក់លាក់នៃការបង្កគ្រោះថ្នាក់ ។

មីលូស្ងូវិក ត្រូវបានចោទប្រកាន់ថា ជាប្រមុខនៃកងកម្លាំងបូស្នៀ និង ស៊ែប ដែលជាកងកម្លាំង សេរ៉ាជីវ៉ូ រូម៉ានី ចាប់តាំងពីខែមីនា ឆ្នាំ១៩៩៣ ហើយបានក្លាយជាមេបញ្ជាការរបស់កងកម្លាំង សេរ៉ាជីវ៉ូ-រូម៉ានី នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ។ មីលូស្ងូវិក បានបញ្ជាយោធាជាង១ម៉ឺន ៨ពាន់នាក់ ហើយបានចរចា ចុះហត្ថលេខា និងអនុវត្តកិច្ចព្រមព្រៀងប្រឆាំងនឹងការលបបាញ់សម្លាប់ កិច្ចព្រមព្រៀងឈប់បាញ់គ្នាក្នុងតំបន់ និងចូលរួមក្នុងការចរចាទាក់ទងនឹងអាវុធធុនធ្ងន់ និងការចូលទៅកាន់ដែនដីតំបន់សេរ៉ាជីវ៉ូ ។ ក្រុមប្រឹក្សាវិនិច្ឆ័យបានរកឃើញថា ទោះបី មីលូស្ងូវិក ស្ថិតក្រោមមេបញ្ជាការយោធាជាន់ខ្ពស់របស់កងកម្លាំងបូស្នៀ និងស៊ែប ។ពាក្យថា "មេដឹកនាំជាន់ខ្ពស់" ដែលត្រូវបានប្រើប្រាស់ដោយក្រុមប្រឹក្សាសន្តិសុខ មិនមានការដាក់កំហិតដល់បុគ្គលដែលជាស្ថាបនិកនៃគោលនយោបាយទាំងមូល ដែលបង្កើតជាមូលដ្ឋាននៃឧក្រិដ្ឋកម្មនោះទេ ។ តាមទស្សនៈរបស់ក្រុមប្រឹក្សាវិនិច្ឆ័យ ការដាក់កំហិតធ្ងន់ធ្ងរនោះ នឹងបន្ថយកម្រិតនៃការទទួលខុសត្រូវរបស់មេបញ្ជាការនៅសមរភូមិ និងសហការីមួយចំនួនដែលត្រូវបានចោទប្រកាន់ថា បានកាន់អំណាច ហើយស័ក្តិសមជាមេដឹកនាំជាន់ខ្ពស់ ជាជាងមេដឹកនាំកម្រិតធម្មតា ។

ក្រុមប្រឹក្សាវិនិច្ឆ័យ បានរកឃើញថា ឧក្រិដ្ឋកម្មដែលមីលូស្ងូវិក ត្រូវបានចោទប្រកាន់ គឺមានស្ថានទម្ងន់ នៅពេលដែលប្រៀបធៀបជាមួយនឹងសំណុំរឿងដទៃនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដោយផ្អែកលើការសម្លាប់ដែលប្រព្រឹត្តឡើងក្នុងពេលឡោមព័ទ្ធសេរ៉ាជីវ៉ូ ដែលបានសម្លាប់ និងបង្ករបួសដល់ជនស៊ីវិលទាំងពីរភេទ រាប់ពាន់នាក់ និងគ្រប់អាយុទាំងអស់ ហើយបានបំផ្លិចបំផ្លាញសម្ភារជាច្រើនក្នុងរយៈពេល១៥ខែ ។ ក្រុមប្រឹក្សាវិនិច្ឆ័យ បានកត់សម្គាល់ថា អំពើហិង្សាប្រឆាំងនឹងជនស៊ីវិលបានកើនឡើងនៅពេលដែលមីលូស្ងូវិក បានបន្តបញ្ជាក្នុងតំបន់ ។ ជាចុងក្រោយ ការពិតដែលថា ឧក្រិដ្ឋកម្ម និងការចោទប្រកាន់តាមសម្អាងហេតុដែលមាននៅក្នុងបទចោទប្រកាន់ ដែលអាចត្រូវបានដោះស្រាយដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅក្នុងសំណុំរឿងលើកមុន ត្រូវបានច្រានចោលដោយក្រុមប្រឹក្សាវិនិច្ឆ័យដោយសារ "មិនមានភាពជាប់ពាក់ព័ន្ធ" ។ ដោយផ្អែកលើគំហើញទាំងនេះ ក្រុមប្រឹក្សាវិនិច្ឆ័យ បានថែងថា មីលូស្ងូវិច ត្រូវបានចាត់ថ្នាក់ថា ជាបុគ្គលដែលតម្រូវឲ្យមានការជំនុំជម្រះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តាមវិធាន ១១ស្ទួន ។

នៅក្នុងឆ្នាំ២០០៧ ក្រុមប្រឹក្សាវិនិច្ឆ័យរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបដិសេធសំណើរបស់ព្រះរាជអាជ្ញាដើម្បីផ្ទេរសំណុំរឿងរបស់ រ៉ាស៊ីម ដាលិក ទៅកាន់អាជ្ញាធររបស់ប្រទេសបូស្នៀហ្សឺហ្គោវីណា ។ យោងតាមបទចោទប្រកាន់ដាលិកគឺជាមេបញ្ជាការរបស់កងកម្លាំងប្រទេសបូស្នៀហ្សឺហ្គោវីណា ចាប់តាំងពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ ១៩៩៣ រហូតដល់គាត់ចូលនិវត្តន៍ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០០០ ។ ក្នុងតួនាទីនេះ ដេលិក គឺជាមនុស្សថ្នាក់ក្រោមរបស់ប្រធានាធិបតីប្រទេសបូស្នៀហ្សឺហ្គោវីណា ហើយបានអនុវត្តបញ្ជាយោធា និងគ្រប់គ្រងលើកងកម្លាំងទាំងអស់របស់ប្រទេសបូស្នៀហ្សឺហ្គោវីណា ។ នៅក្នុងឆ្នាំ១៩៩៣ ដេលិក បានបង្កើតក្រុមអែលមូចាហ៊ីដ ដែលមានក្រុមស្ម័គ្រចិត្តបរទេសដែលត្រៀមខ្លួនធ្វើសង្គ្រាមសាសនាប្រឆាំងនឹងសត្រូវរបស់ជនជាតិម៉ូស្លីមបូស្នៀ និងដែលបានសម្លាប់ បានធ្វើបាបរំលោភជនស៊ីវិល និងសម្លាប់យោធាសត្រូវដែលត្រូវបានចាប់ខ្លួន និងបានចុះញម ។

ដេលិក ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មសង្គ្រាមបួនប្រភេទ ។ បទចោទប្រកាន់ជាប់ពាក់ព័ន្ធនឹងជនរងគ្រោះ១០០នាក់ នៃអំពើកាប់សម្លាប់ ការប្រព្រឹត្តយង់ឃ្នង និងអំពើចាប់រំលោភ ដែលប្រព្រឹត្តឡើងនៅ៤កន្លែងនៅបូស្នៀ ក្នុងអំឡុងពេលមិនលើសពី៣ខែ ក្នុងឆ្នាំ១៩៩៣ និងក្នុងឆ្នាំ១៩៩៥ ។ មិនដូចគ្នាទៅនឹងសំណុំរឿងរបស់មីលូស្ងូវិក ក្រុមប្រឹក្សាវិនិច្ឆ័យ បានសម្រេចថាឋានៈរបស់ដេលិក ជា "មេដឹកនាំជាន់ខ្ពស់" មិនរាប់បញ្ចូលការផ្ទេរ

សំណុំរឿង ថ្វីបើការពិតដែលថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ មានស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងសំណុំរឿងនៅក្នុងសំណុំរឿងដែលផ្ទេរលើកមុនក៏ដោយ ។

សំណុំរឿងទី៣នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបដិសេធចំពោះសំណើផ្ទេរការចោទប្រកាន់ជាប់ពាក់ព័ន្ធនឹង មីលាន និង ស្រេដូជេ លូគិក ហើយស្នើឲ្យក្រុមប្រឹក្សាវិនិច្ឆ័យបញ្ជូនសំណុំរឿងទៅតុលាការប្រទេសបូស្នៀហ្សឺហ្គោវីណាវិញ ។ មីលាន លូគិក បានខិតខំរក្សាសំណុំរឿងរបស់គាត់នៅតុលាការ ហើយបានប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិនិច្ឆ័យទៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ មីលាន លូគិក បានបង្កើតក្រុមយោធាប៉ារ៉ា ដែលស្គាល់ថា ជា «ក្រុមឥន្ទ្រីស» ឬ «អ្នកសងសឹក» ហើយ ស្រេដូជិក លូគិក ត្រូវបានចោទប្រកាន់ថា ជាសមាជិកម្នាក់នៃក្រុមនេះ ។ អ្នកទាំងពីរនាក់ត្រូវបានចោទប្រកាន់ថា បានសម្លាប់មនុស្សប្រហែល១៤០នាក់ និងបានបង្ករបួសស្នាមដល់អ្នកដទៃក្នុងឧប្បទ្ទវហេតុទីពី ដោយបានរារាំងមនុស្សនៅក្នុងផ្ទះ ហើយបានដុតផ្ទះសម្លាប់មនុស្សទាំងនោះចោល ។ ក្រៅពីនេះ មីលាន លូគិក ត្រូវបានចោទប្រកាន់ថា បានសម្លាប់មនុស្ស១៣នាក់ផ្សេងទៀត នៅក្នុងឧប្បទ្ទវហេតុបី ។ ក្រុមប្រឹក្សាវិនិច្ឆ័យបានរកឃើញឧក្រិដ្ឋកម្មទាំងនេះ មានសភាពធ្ងន់ធ្ងរ ប៉ុន្តែបានធ្វើសេចក្តីសន្និដ្ឋានចុងក្រោយថា មិនមានជនដែលត្រូវចោទប្រកាន់ណា គឺជា «មេដឹកនាំជាន់ខ្ពស់» ហើយក្រុមប្រឹក្សាវិនិច្ឆ័យ បានចេញដីការផ្ទេរសំណុំរឿង ។

អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានយល់ស្របនឹងការជំទាស់នឹងស្ថានទម្ងន់ទោសរបស់ក្រុមប្រឹក្សាវិនិច្ឆ័យ ប៉ុន្តែបានរកឃើញការធ្វើសេចក្តីសន្និដ្ឋានលើកម្រិតនៃការគ្រប់គ្រងអំណាចរបស់មីលានលូគិក បានកំណត់ខុសជាមុនថា មេដឹកនាំក្រុមយោធាប៉ារ៉ាក្នុងស្រុក មិនអាចត្រូវបានចាត់ទុកថា ជា «មេដឹកនាំជាន់ខ្ពស់» នោះទេ ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានរកឃើញថា «មីលាន លូគិក គឺជាអ្នកត្រួតត្រាក្នុងតំបន់ផ្ទាល់របស់ខ្លួន» ហើយថា ក្រុមប្រឹក្សាវិនិច្ឆ័យបានកំណត់ហួសហេតុលើទីតាំងនៃអំពើឧក្រិដ្ឋកម្មបានកើតឡើងតាមការចោទប្រកាន់ ។ បន្ទាប់មក អង្គជំនុំជម្រះបានកត់សម្គាល់ថា ក្រុមឥន្ទ្រីស បានធ្វើប្រតិបត្តិការដោយមិនមានការដាក់ទោសទណ្ឌ ហើយមិនបានរាយការណ៍ទៅកាន់ថ្នាក់លើអស់រយៈពេលជាង២ឆ្នាំ ដែលនេះធ្វើឲ្យ មីលាន លូគិក ក្លាយជាមេដឹកនាំក្រុមយោធាប៉ារ៉ា ដ៏សំខាន់បំផុត ដែលត្រូវបានចោទប្រកាន់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ បានសន្និដ្ឋានថា សំណុំរឿងប្រឆាំងនឹង មីលាន លូគិក មានសារសំខាន់ រហូតដល់មិនអាចស័ក្តិសមផ្ទេរសំណុំរឿង ហើយបានបដិសេធចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិនិច្ឆ័យ ។

## ក) ឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ

តុលាការព្រហ្មទណ្ឌអន្តរជាតិ មានយុត្តាធិការលើបុគ្គលដែលជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដែលជាបញ្ហារបស់អន្តរជាតិ ។ លក្ខន្តិកក្រុងរ៉ូម បានណែនាំព្រះរាជអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិឲ្យកំណត់ថា តើមានហេតុផលគ្រប់គ្រាន់ដើម្បីជឿថាការចាប់ផ្តើមការស៊ើបអង្កេត នឹងបម្រើប្រយោជន៍ ក្នុងការស្វែងរកយុត្តិធម៌ ទន្ទឹមពេលដែលពិចារណាលើស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម និងផលប្រយោជន៍របស់ជនរងគ្រោះ ។ ក្នុងឆ្នាំ២០០៣ ការិយាល័យព្រះរាជអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានផ្សព្វផ្សាយឯកសារគោលនយោបាយកំណត់ «យុទ្ធសាស្រ្តទូទៅ» នៃការវាយតម្លៃសំណុំរឿង ដ៏សំខាន់សម្រាប់ការស៊ើបអង្កេត ដោយលើកឡើងថា៖

> ទោះបីជាឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការនៃតុលាការ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរក៏ដោយ ក៏លក្ខន្តិកទីក្រុងរ៉ូម បានព្យាករណ៍ និងតម្រូវយ៉ាងច្បាស់អំពីការពិចារណាអំពីស្ថានទម្ងន់ ដូច្នេះហើយ បានជាការិយាល័យរដ្ឋអាជ្ញា ត្រូវតែកំណត់ថា តើរឿងក្តីនោះមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីឲ្យតុលាការលើកហេតុផលនៃចំណាត់ការបន្ថែមដែរឬយ៉ាងណា ។ កត្តាដែលជាប់ពាក់ព័ន្ធនឹងការវាយ តម្លៃលើស្ថានទម្ងន់ រួមមាន៖ កម្រិតនៃឧក្រិដ្ឋកម្ម សារជាតិនៃឧក្រិដ្ឋកម្ម របៀបនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម និងផលប៉ះពាល់នៃឧក្រិដ្ឋកម្ម ។

នៅក្នុងអត្ថបទបោះពុម្ពផ្សាយជាបន្តបន្ទាប់ ការិយាល័យរដ្ឋអាជ្ញា បានលើកឡើងបន្ថែមថា ខ្លួននឹងស៊ើបអង្កេត និងចោទប្រកាន់អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដោយរួមបញ្ចូលអ្នកដែលជាកម្មាភិបាលជាន់ខ្ពស់ដែលមានទំនួលខុសត្រូវ រួមមាន អ្នកដែលបានចេញបញ្ជា ផ្តល់ថវិកា ឬរៀបចំឲ្យមានឧក្រិដ្ឋកម្ម ។ អត្ថបទបោះពុម្ពផ្សាយទាំងពីរ បានបញ្ជាក់អំពីការផ្តោតជាទូទៅនៃប្រភេទដែលនាំឲ្យមានការចោទប្រកាន់ដ៏កម្រ នៅក្រោមការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិស្តីពីការបន្តការចោទប្រកាន់បុគ្គល ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងស្របជាមួយនឹងយុត្តាធិការបុគ្គល ដែលជាយុត្តិសាស្ត្ររបស់តុលាការពិសេស សម្រាប់ប្រទេស សេរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។

## ខ្លឹមសារនៃយុត្តាធិការអន្តរជាតិបុគ្គល

តាមរយៈទស្សនៃការអនុវត្តច្បាប់នៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិ កត្តាមួយចំនួនតាមផ្លូវច្បាប់អាចត្រូវបានយកមកក្នុងការកំណត់ថា តើបុគ្គលត្រូវបានចាត់ទុកថា ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ។ ជាទូទៅ វាច្បាស់ដែលថា បុគ្គលដែលត្រូវបានចាត់ទុកថា ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅពេលដែលបុគ្គលនោះជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ដើម្បីវាយតម្លៃការប្រព្រឹត្តរបស់ជនសង្ស័យ កត្តាដ៏សំខាន់២ដើម្បីពិចារណា គឺលក្ខណៈធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលជនសង្ស័យមានជាប់ពាក់ព័ន្ធ និងសារសំខាន់នៃតួនាទីរបស់ជនសង្ស័យនៅក្នុងការរួមចំណែកដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ លក្ខណៈធ្ងន់ធ្ងរត្រូវបានវាយតម្លៃតាមរយៈភាពជាប់ទាក់ទងនឹងចំនួននៃជនរងគ្រោះ ដែលរងការប៉ះពាល់ ផលប៉ះពាល់នៃឧក្រិដ្ឋកម្ម ទីតាំង និងអំឡុងពេលនៃការប្រព្រឹត្តបទឧក្រិដ្ឋ និងសារជាតិ និងលក្ខណៈនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ។

ទន្ទឹមពេលដែលចៅក្រមបានចៀសវាងការពិចារណាលើចំនួនអ្នកស្លាប់ ឬចំនួនជនរងគ្រោះដែលប៉ះពាល់ការវាយតម្លៃទាំងនេះត្រូវតែធ្វើឡើងតាមរយៈ ការប្រើប្រាស់សំណុំរឿងផ្សេងៗតាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិជាចំណុចសម្អាងរបស់ខ្លួន ជាពិសេសអ្នកដែលត្រូវបានចោទប្រកាន់ ដោយតុលាការដូចគ្នា ។ តួនាទីរបស់ជនសង្ស័យត្រូវបានវាយតម្លៃ តាមរយៈការពិចារណាអំពីកម្រិតនៃអំណាចបង្គាប់បញ្ជាអ្នកដទៃ ដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទព្រហ្មទណ្ឌ ហើយថាតើជនសង្ស័យបានដើរតួនាទីក្នុងការសម្រេចចិត្ត ដែលនាំទៅរកការប្រព្រឹត្តឧក្រិដ្ឋកម្មដែរឬយ៉ាងណា ។ ជាងនេះទៅទៀត កត្តាទាំងពីរស្តីពីស្ថានទម្ងន់ និងការទទួលខុសត្រូវត្រូវបានបង្ហាញជារួម ជាជាងយកមកបកស្រាយបន្ថែមពីលើគ្នា ។

ក្រៅពីការវាយតម្លៃលើលក្ខណៈពិស្តារ ការសំដៅទៅរកការចោទប្រកាន់ដ៏ជាក់ច្បាស់នោះ គឺជាលក្ខណៈជាក់ស្តែង ដោយសារតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបដិសេធចោទប្រកាន់ជនសង្ស័យ ដោយផ្អែកលើការរកឃើញថា គាត់មិនមែនជា "អ្នកដែលទទួលខុសត្រូវជាន់ខ្ពស់" ហើយគំហើញនេះធ្វើឲ្យមានការចោទប្រកាន់ជនសង្ស័យនៅតុលាការថ្នាក់ជាតិ ។ នេះគឺជាការខ្វែងគំនិតគ្នារវាងសេចក្តីសម្រេចនៃវិធាន១១ស្ទួន របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងវាសនានៃសំណុំរឿង ០០៣, ០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដោយសារមានការខ្វែងគំនិតគ្នាជាមូលដ្ឋានរវាងការផ្ទេរយុត្តាធិការចោទប្រកាន់កម្រិតអន្តរជាតិមកត្រឹមថ្នាក់ជាតិ និងការបញ្ឈប់កិច្ចដំណើរនីតិវិធីព្រហ្មទណ្ឌប្រឆាំងទៅនឹងបុគ្គលដែលជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិ ។ មិនមានការលើកឡើងណាមួយដែលថាប្រសិនបើជនសង្ស័យមួយចំនួន ឬទាំងអស់ក្នុងសំណុំរឿង០០៣, ០០៤មិនត្រូវបានធ្វើការជំនុំជម្រះ អ្នកទាំងនោះប្រហែលជាត្រូវចោទប្រកាន់ដោយតុលាការព្រហ្មទណ្ឌកម្ពុជាធម្មតា ។ ផ្ទុយទៅវិញ ប្រសិនបើសំណុំរឿងត្រូវបានបញ្ចប់ មុនពេលការធ្វើការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនសង្ស័យនឹងគេចពីការទទួលខុសត្រូវបទព្រហ្មទណ្ឌទាំងអស់ ។ ប្រការនេះនឹងក្លាយជាការងាកចេញពីគោលការណ៍ស្នូលនៃការទទួលខុសត្រូវដោយលក្ខណៈបុគ្គល ដែលកំណត់ដោយច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដោយសារមកដល់ពេលបច្ចុប្បន្ន មិនមានសំណុំរឿងមួយក្នុងចំណោមសំណុំរឿងជាច្រើននៅតុលាការអន្តរជាតិដ៏សំខាន់ ធ្លាប់

ត្រូវបានច្រានចោលជាមុន ដោយផ្អែកលើការវាយតម្លៃអំពីការទទួលខុសត្រូវ ថ្វីបើមានភស្តុតាងគ្រប់គ្រាន់ដើម្បីចេញដីការដំនុំជម្រះនោះទេ ។

ជនសង្ស័យដែលត្រូវបានសន្មត់នៅក្នុងសំណុំរឿង០០៣ និង០០៤

ទោះបីជាសំណុំរឿង០០៣,០០៤ទាំងពីរ នៅបន្តអូសបន្លាយនៅក្នុងដំណាក់កាលស៊ើបអង្កេត ដូច្នេះហើយអត្តសញ្ញាណរបស់ជនសង្ស័យក្នុងសំណុំរឿងទាំងពីរនៅតែជាការសម្ងាត់ ឈ្មោះជនសង្ស័យទាំង៥នាក់នៅក្នុងសំណុំរឿង០០៣ និង០០៤ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ នៅក្នុងអត្ថបទសារព័ត៌មានជាច្រើន ហើយជនសង្ស័យមួយចំនួនត្រូវបានរាយការណ៍ថា បានផ្តល់បទសម្ភាសទៅឲ្យអ្នកសារព័ត៌មាន ។ ពិតប្រាកដណាស់ ការយល់ដឹងជាសាធារណ មានលក្ខណៈជ្រួតជ្រាបហួសពីការគ្រាន់តែប៉ាន់ស្មាន់ ដោយសារដីការបញ្ជូនសំណុំរឿងរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលបានផ្តួចផ្តើមសំណុំរឿងនីមួយៗ ត្រូវបានបែកធ្លាយនៅលើគេហទំព័រសារព័ត៌មាន ដែលមានមូលដ្ឋាននៅប្រទេសញ៉ូវសេឡែន ដែលបានផ្សព្វផ្សាយឯកសារទាញយកទិន្នន័យជាច្រើននៅលើគេហទំព័រ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១ ។

ទាក់ទងនឹងទស្សនជាសាធារណៈ និងបើកចំហឯកសារនេះ នឹងពិភាក្សាអំពីតួនាទីរបស់ជនសង្ស័យដែលត្រូវបានកំណត់នាពេលបច្ចុប្បន្ន ។ សំណុំរឿង០០៣ខាងដើម ដែលជាប់ពាក់ព័ន្ធនឹងជនសង្ស័យ២នាក់ដូចជា មាស មុត និង ស៊ូ ម៉េត និងសំណុំរឿង០០៤ ដែលជាប់ពាក់ព័ន្ធនឹងជនសង្ស័យបីនាក់ដូចជា តាអាន, អ៊ឹម ចែម និង តាទិត្យ ។ ស៊ូ ម៉េត បានស្លាប់ ដោយសារជំងឺទឹកនោមផ្អែម នៅខែមិថុនា ឆ្នាំ២០១៣ ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃអត្តសញ្ញាណ និងតួនាទីរបស់ជនសង្ស័យជាអតីតខ្មែរក្រហមទាំង៤នាក់ ដែលរស់រានមានជីវិត ហើយត្រូវបានដកស្រង់ចេញពីឯកសារបែកធ្លាយ និងបណ្តាញសារព័ត៌មានផ្សេងៗ ។

### សំណុំរឿង០០៣ ៖ មាស មុត និង ស៊ូ ម៉េត

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ សំណុំរឿង០០២ បានចោទប្រកាន់មេធាវីការពារក្តី នួន ជា ដែលបានចាត់ទុក មាស មុត ថា ជាជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យ២នាក់ទៀតក្នុងសំណុំរឿង០០៣ ក្នុងអំឡុងពេលការធ្វើអំណះអំណាងផ្ទាល់មាត់ ដោយបញ្ជាក់អំពីភាពត្រឹមត្រូវនៃដីកាបញ្ជូនសំណុំរឿង០០៣ដែលបានបែកធ្លាយ ។ មាស មុត ត្រូវបានចាត់ទុកថា ជាជនសង្ស័យដ៏សំខាន់ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយសារសំណុំរឿងប្រឆាំងនឹងគាត់ ត្រូវបានបង្ហាញនៅក្នុងសៀវភៅស្តីពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ដែលនិពន្ធដោយអ្នកស្រាវជ្រាវ ស្ទីវ ហេដឌ័រ និងមេធាវី ប្រាអាន ទីតទីម័រ ។

ហេដឌ័រ និង ទីតទីម័រ បានចោទប្រកាន់ មាស មុត និងសហជនសង្ស័យដែលបានស្លាប់ ស៊ូ ម៉េត ដោយលើកឡើងពីឋានន្តរសក្តិនៅតំបន់និរតី និងកាន់តួនាទីផ្នែកយោធាយ៉ាងសំខាន់ ក្រោមមេដឹកនាំ ដែលផ្តល់តួនាទីឲ្យអ្នកទាំងនោះ អនុវត្តគោលនយោបាយរបស់ខ្មែរក្រហម និងការប្រព្រឹត្តរបស់កម្មាភិបាលថ្នាក់ទាប ។ មាស មុត បានក្លាយជាលេខានៃកងពលធំលេខ១៦៤ របស់គណមជ្ឈិម ដែលបានដាក់បញ្ចូលកងទ័ពជើងទឹកខ្មែរក្រហម ហើយគាត់ជាកូនប្រុសរបស់មន្ត្រីខ្មែរក្រហមឈ្មោះ ប៉ាង ដែលបានស្លាប់នៅក្នុងឆ្នាំ១៩៦៨ ។ យោងតាមរបាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស មាស មុត បានបញ្ជាកងទ័ពចាប់ពី៨ពាន់នាក់ដល់១ម៉ឺននាក់ ។

**(នៅមានត)**

**វ៉ែនឌុល ជីហ្សាលក្ស**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm • ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។





















# តើអ្នកអាចជួយព្យាបាលរបួសនៅក្នុងសង្គមកម្ពុជាឱ្យជាសះស្បើយតាមវិធីណា?

ប្រជាជនកម្ពុជាបានរង់ចាំអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីមើលឃើញមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ។ ប្រជាជនកម្ពុជាបានរង់ចាំអស់រយៈពេលជិត៣០ឆ្នាំ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទម្រាំអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦ ។ នៅក្នុងចន្លោះពេលនៃការរង់ចាំនោះ មេដឹកនាំខ្មែរក្រហមបានវិវត្តទៅរកភាពចាស់ជរា និងមេដឹកនាំមួយចំនួនបានក្លាយជាអ្នកមានទ្រព្យធន ។ ចំណែកឯប្រជាជនកម្ពុជាវិញនៅតែចងចាំមិនភ្លេចអំពីរឿងរ៉ាវទាំងឡាយ ដែលបានកើតនៅក្នុងរបបខ្មែរក្រហម ដែលខ្លួនធ្លាប់បានឆ្លងកាត់ ។ ប្រជាជនកម្ពុជាជាច្រើនមិនចង់រំឭកឡើងវិញនូវព្រឹត្តិការណ៍ដ៏គួរឲ្យភ័យខ្លាចដែលបានកើតឡើងនៅក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ នៃរបបខ្មែរក្រហមនោះទេ ។ សូម្បីតែសាលារៀនក៏មិនបានបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនោះទេ ។ ប្រជាជនខ្មែរជំនាន់ក្រោយដែលកើតក្រោយរបបខ្មែរក្រហមបានធំដឹងក្តីឡើងដោយពុំបានយល់ដឹងអំពីប្រវត្តិសាស្ត្រនៃប្រទេសរបស់ខ្លួនដូចៗគ្នា ។

ការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជា



ជនរងគ្រោះតម្រង់ជួរចូលស្តាប់សវនាការបឋមបន្ថែមក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ មានជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅសាលាក្តីខ្មែរក្រហម

ជំហានដ៏សំខាន់មួយដែលញ៉ាំងឲ្យប្រវត្តិសាស្ត្រខ្មែរក្រហមមានពន្លឺឡើង ។ ដាក់ស្ដែងសំណុំរឿង០០១របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានលាតត្រដាងពីស្ថានភាពមន្ទីរស-២១ ឬគុកទួលស្លែង ។ សំណុំរឿងផ្នែកទីមួយនៃសំណុំរឿង០០២ របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមផ្ដោតសំខាន់ទៅលើការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗនៅទូទាំងប្រទេសកម្ពុជា ។ ការផ្សព្វផ្សាយជាសារធារណៈនិងកិច្ចខំប្រឹងប្រែងដើម្បីធានាថា ប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានបង្រៀននៅតាមសាលារៀន បានបង្កើននូវការយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីប្រវត្តិអតីតកាលរបស់ប្រទេសកម្ពុជា ។

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានបើកទ្វាររបស់ខ្លួនដើម្បីអនុញ្ញាតឲ្យជនរងគ្រោះនៃរបបខ្មែរក្រហមបានចូលរួមនៅក្នុងដំណើរការផ្នែកច្បាប់ ។ ជនរងគ្រោះនៃរបបខ្មែរក្រហមបាននិយាយរៀបរាប់រឿងរ៉ាវរបស់ខ្លួននៅចំពោះមុខតុលាការ និងបានស្នើសុំឲ្យមានសំណងពីរបបខ្មែរក្រហម ។ ជាសរុប ជនរងគ្រោះនៅសំណុំរឿងផ្នែកទីមួយនៃសំណុំរឿង០០២ បានស្នើសុំសំណងចំនួន១៣ នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សំណងដែលបានស្នើសុំទាំងនោះ រួមមាន ការតាំងពិព័រណ៍ស្ដីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ទិវាចងចាំរបស់ជាតិ ការសាងសង់បូជនីយដ្ឋានសាធារណៈនៅប្រទេសកម្ពុជា និងប្រទេសបារាំង មជ្ឈមណ្ឌលសហគមន៍សម្រាប់ការសិក្សាអំពីសន្តិភាព ការបោះពុម្ពរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ការចងក្រងជំពូកមេរៀនស្ដីអំពីការជម្លៀសដោយបង្ខំនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ កម្មវិធីព្យាបាលរបួសផ្លូវចិត្តដល់ជនរងគ្រោះនៃរបបខ្មែរក្រហម និងការបោះពុម្ពផ្សាយនៃសាលក្រមរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏ដូចជាឈ្មោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។ សំណើខាងលើនេះនឹងអាចជួយឲ្យប្រជាជនកម្ពុជាចងចាំ និងព្យាបាលរបួសពីអតីតកាល ។

សំណើដែលបានរៀបរាប់ខាងលើ ជាដំណាក់កាលមួយក្នុងចំណោមដំណាក់កាលជាច្រើនសម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការចងចាំប្រវត្តិសាស្ត្រកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាជនកម្ពុជាចំនួនតិចតួចនៅឡើយ ដែលបានចូលរួមស្ដាប់សវនាការនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ឬបានយល់ច្បាស់ពីអ្វីដែលបានកើតឡើងនៅបន្ទប់សវនាការ ។ ប៉ុន្តែតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មិនទាន់អាចរកបានមូលនិធិគ្រប់គ្រាន់ដើម្បីចំណាយលើការអនុវត្តគម្រោងសំណង ដែលបានរៀបរាប់ខាងលើនោះទេ ។ ហេតុដូច្នេះប្រជាជនកម្ពុជាជំនាន់ក្រោយ ដែល៧០ភាគរយបានកើតក្រោយរបបខ្មែរក្រហម និងប្រជាជនជំនាន់មុនគប្បីសម្រេចចិត្តថា គួរធ្វើយ៉ាងណាដើម្បីពង្រឹងការយល់ដឹងរបស់ខ្លួនទាក់ទងនឹងប្រវត្តិសាស្ត្រជូរចត់របស់ខ្លួន ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងផ្សេងៗ ដើម្បីព្យាបាលរបួសកាលពីអតីតកាលឲ្យជាសះស្បើយ និងដើម្បីអភិវឌ្ឍប្រទេសជាតិ ។

ការរៀបចំពិព័រណ៍អចិន្ត្រៃយ៍ស្ដីអំពីរបបខ្មែរក្រហម គឺជាជំហានសំខាន់មួយក្នុងការអប់រំសាធារណជនអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ការចូលទស្សនារូបថតខ្សែវីដេអូ និងការស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អាចជួយធានាថា ប្រវត្តិសាស្ត្រខ្មែរក្រហមនឹងមិនត្រូវបានបំភ្លេច ។ ប្រសិនបើយើងគ្រប់គ្នាចងចាំទុកនូវសោកនាដកម្មដែលបានកើតឡើងនោះមានន័យថា យើងបានចូលរួមចំណែកមួយក្នុងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនោះ កុំឲ្យកើតឡើងម្ដងទៀតនៅលើទឹកដីនៃប្រទេសកម្ពុជា ។ ប្រជាជនកម្ពុជាដែលមិនធ្លាប់ឆ្លងកាត់របបខ្មែរក្រហម នឹងមានការយល់ឃើញប្រសើរជាងប្រជាជនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ព្រមទាំងអាចជួយដល់ដំណើរការព្យាបាលរបួសពីអតីតកាលផងដែរ ។ អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមអាចរៀបរាប់ប្រាប់អ្នកដទៃអំពីការចងចាំរបស់ខ្លួនទាក់ទងនឹងបទពិសោធឈឺចាប់កាលពីរបបខ្មែរក្រហម ដើម្បីចូលរួមរៀបចំសង្គមកម្ពុជាឡើងវិញ ដែលធ្លាប់បានហែកហួរដោយសារសង្គ្រាម ។

ទន្ទឹមនឹងនេះដែរ មានកត្តាជាច្រើនដែលយើងគ្រប់គ្នាអាចចូលរួមចំណែកដើម្បីព្យាបាលរបួសពីអតីតកាល និងឈានទៅរកអនាគតដ៏ភ្លឺស្វាង ។

### ការជូនដំណឹងដល់សាធារណជន

ការតាំងពិព័រណ៍អចិន្ត្រៃយ៍ស្ដីអំពីការជម្លៀសប្រជាជន

នៅក្នុងរបបខ្មែរក្រហម បានបង្ហាញពីទិដ្ឋភាពមួយនៃឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ តាមរយៈការទស្សនាពិព័រណ៍នេះ អ្នកនឹងអាចយល់ដឹងបន្ថែមអំពីហេតុផល និងផលប៉ះពាល់នៃការជម្លៀសមកលើប្រជាជនកម្ពុជា ។ ទន្ទឹមនឹងនេះដែរ ប្រជាជនកម្ពុជាគួរស្វែងយល់បន្ថែមអំពីឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្ត និងស្វែងយល់បន្ថែមពីការឈឺចាប់របស់អ្នកដែលធ្លាប់រស់ក្នុងរបបខ្មែរក្រហម ព្រមទាំងមូលហេតុដែលខ្មែរក្រហមឡើងកាន់អំណាចដើម្បីទប់ស្កាត់ក្រុមមនុស្សគ្រោះថ្នាក់ដទៃទៀតកុំឲ្យឡើងកាន់អំណាច ។ គេហទំព័រមួយចំនួនបានផ្ដល់ព័ត៌មានបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម រួមមាន វិទ្យាស្ថានស្ទីករីត (www.cambosiasri.org) មជ្ឈមណ្ឌលឯកសារកម្ពុជា (www.dccam.org) គម្រោងឃ្លាំមើលសាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហម (www.cambodiatribunal.org) ជាដើម ។

**ការប្រាស្រ័យទាក់ទងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត**

ការឈឺចាប់ដែលប្រជាជនកម្ពុជាបានទទួលរងក្នុងរបបខ្មែរក្រហម ពិតជាពិបាកក្នុងការរៀបរាប់ ។ ទោះបីជាអ្នកមិនបានរស់ក្នុងរបបខ្មែរក្រហមក៏ដោយ ក៏ការចងចាំនៅក្នុងរបបខ្មែរក្រហមបានប៉ះពាល់ដល់ជីវិតអ្នកដទៃដែរ ។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែមានសាច់ញាតិ និងមិត្តភក្ដិដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ។ ការតាំងពិព័រណ៍ស្ដីអំពីរបបខ្មែរក្រហមអាចជួយឲ្យអ្នកចាប់ផ្ដើមការសន្ទនាជាមួយអ្នកដែលរស់រានមានជីវិត ពីរបបខ្មែរក្រហមអំពីការឈឺចាប់ដែលបានកប់ទុកក្នុងចិត្ត ។ ការប្រាស្រ័យទាក់ទងគ្នាអាចជួយឲ្យអ្នករកវិធីជួយជនរងគ្រោះពីរបបខ្មែរក្រហមបាន ។ អ្នកអាចជួបការលំបាកក្នុងការស្ដាប់រឿងរ៉ាវរបស់ជនរងគ្រោះពីរបបខ្មែរក្រហម ប៉ុន្តែអ្នកអាចជួយជនរងគ្រោះទាំងនោះទៅរកសេវាព្យាបាលរបួសផ្លូវចិត្ត ឬការអប់រំផ្លូវចិត្តតាមបែបសាសនា ។ អ្នកអាចជួយជនរងគ្រោះទាំងនោះស្វែងរកកម្លាំងចិត្ត និងផ្ដល់ជំនួយផ្សេងៗ ដែលជនរងគ្រោះពីរបបខ្មែរក្រហមត្រូវការដើម្បីព្យាបាលរបួសផ្លូវចិត្ត ។

**ការចូលរួមចំណែកក្នុងការងារផ្សេងៗ**

បន្ទាប់ពីបានទស្សនាពិព័រណ៍ស្ដីអំពីរបបខ្មែរក្រហម អ្នកពិតជាចូលរួមចំណែកក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមទៅដល់ប្រជាជនដទៃទៀត តាមរយៈការចែករំលែកព័ត៌មានដែលអ្នកទទួលបាននៅថ្ងៃនេះ ក៏ដូចជាព័ត៌មានដែលអ្នកអាចរកបាននៅក្នុងគេហទំព័រដែលបានរៀបរាប់ខាងលើជាមួយមិត្តភក្ដិ និងក្រុមគ្រួសាររបស់អ្នក ។ ប្រសិនបើអ្នកជាគ្រូបង្រៀន អ្នកអាចប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និពន្ធដោយ ឌី ខាំបូលី ដើម្បីបង្រៀនជនដទៃពីរបបខ្មែរក្រហម ។ អ្នកអាចទាក់ទងជាមួយវិទ្យាស្ថានស្ទីករីត (www.cambosiasri.org) ដើម្បីស្វែងយល់បន្ថែមពីប្រវត្តិសាស្ត្រសម័យខ្មែរក្រហម ឬដាក់ពាក្យធ្វើការងារស្ម័គ្រចិត្ត ដើម្បីចូលរួមចែករំលែកព័ត៌មានដល់អ្នកដទៃ ។

**ការចងចាំអំពីកេរដំណែលប្រវត្តិសាស្ត្ររបស់កម្ពុជា**

ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រដ៏យូរលង់ និងសម្បូរបែបដែលចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា ។ ប្រទេសកម្ពុជាមានកេរដំណែលវប្បធម៌ជាច្រើន ដូចជា ប្រាសាទអង្គរវត្ត របាំបុរាណ និងរបាំប្រជាប្រិយ ដែលប្រជាជនកម្ពុជាគួរតែអបអរសាទរ ។ ខ្មែរក្រហមបានព្យាយាមបំផ្លាញប្រពៃណី និងវប្បធម៌ដ៏សម្បូរបែបទាំងនេះ និងបានបំបិទសិទ្ធិប្រជាជនកម្ពុជា ។ ដូច្នេះអ្នកអាចចូលរួមក្នុងការព្យាបាលរបួសកាលពីអតីតកាល និងស្ដារប្រពៃណីវប្បធម៌របស់កម្ពុជាឡើងវិញ ។

**ការរក្សាអនាគតកម្ពុជា**

ចំណេះដឹងអំពីប្រវត្តិសាស្ត្រ អាចជួយទប់ស្កាត់ការប្រព្រឹត្តកំហុសឆ្គងពីអតីតកាល និងឈានទៅរកអនាគតភ្លឺស្វាង ។ អនាគតរបស់ប្រទេសកម្ពុជា ស្ថិតក្នុងដៃរបស់អ្នក ក៏ដូចជាប្រជាជនកម្ពុជាគ្រប់រូប ។ ឥឡូវនេះ កម្ពុជាគឺជាប្រទេសប្រជាធិបតេយ្យ ។ ដូច្នេះយើងគ្រប់គ្នាគួរតែមានការទទួលខុសត្រូវខ្ពស់ ។ យើងគ្រប់គ្នាត្រូវសិក្សាឲ្យបានច្បាស់លាស់ និងត្រិះរិះពិចារណាឲ្យបានល្អិតល្អន់មុនពេលបោះឆ្នោត ។ តើបញ្ហាណាខ្លះដែលអ្នកគិតថា ចាំបាច់ និងបេក្ខជនឈរឈ្មោះបោះឆ្នោតរូបណាខ្លះដែលអ្នកគិតថា អាចជួយដោះស្រាយបញ្ហារបស់អ្នកបាន? ប្រជាជនគ្រប់រូបមានសិទ្ធិក្នុងការបោះឆ្នោត ។ ដូច្នេះ យើងត្រូវតែអនុវត្តសិទ្ធិរបស់យើង ។ ការចងចាំរបស់ប្រជាជនដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមគួរតែជាគោលគំនិតមួយក្នុងការជ្រើសរើសមេដឹកនាំប្រទេស ។ **ចាយ៉ា វ៉ាមជី**

# ជីវិត ក្នុងព្យុះមរណា

*(តចប់)*

## ***៦) ធ្វើដំណើរសំដៅទៅស្រុកកំណើត***

វំលងបានមួយយប់ បាតជើងខ្ញុំអន់ឈឺបន្តិច ខ្ញុំពីរនាក់ឪពុកកូន ស្ពាយកាបូបម្នាក់មួយចេញ ដើរសំដៅទៅកាន់ខេត្តសៀមរាបតែម្តង ហើយភូមិសាស្ត្រក្នុងការធ្វើដំណើរព្រមទាំងការហូបចុក ឪពុកខ្ញុំគាត់រ៉ាប់រងមិនឲ្យខ្ញុំគិតទេ ព្រោះគាត់ពូកែទំនាក់ទំនងជាមួយនឹងមហាជនណាស់ ។ ពេលឈប់សម្រាកម្តងៗ គាត់សួរនាំគេឯងមិនចេះចប់ ។ ថ្ងៃនោះ យើងធ្វើដំណើរពេញមួយថ្ងៃ គឺមានជួបអ្នកដំណើរដូចគ្នាយូរៗម្តង ហើយនៅកន្លែងដែលយើងដើរនេះមានគេប្រាប់ថា អរិយក្សត្រ ។ នៅម្តុំនេះមានផ្ទះដែរ តែឆេះអស់ នៅសល់តែសសរឆេះរោលខ្មៅចនៅឈរច្រូងច្រាង ។ ពេលព្រលប់ចូលមកដល់ ខ្ញុំបម្រុងចុះទៅក្បង់ទឹកដីកលើស្ពានឈើមួយ ខ្ញុំបានក្រឡេកទៅខាងឆ្វេងដៃ ស្រាប់តែឃើញទាហានអាវខ្មៅ៥នាក់ស្ពាយកាំភ្លើងគ្រប់ដៃ ហើយអ្នកដែលដើរពីក្រោយគេមានកាន់ចុងក្រមាចងដឹកដៃឆ្វេងនារីកូនកាត់ចិនម្នាក់ ស្ថិតនៅក្នុងវ័យជាង២០ឆ្នាំ ស្លៀកពាក់ខោអាវខ្មៅរលោងៗ ប្រកបដោយទឹកមុខភិតភ័យ បានចោលក្រសែភ្នែកមករកខ្ញុំ ហាក់បីដាចង់ឲ្យខ្ញុំជួយដល់រូបនាង ។ ខ្ញុំភ្ញាក់មាត់ សួរទៅកាន់មិត្តនោះថា ចុះយ៉ាងម៉េចមិត្ត? គេសំឡឹងមើលមកខ្ញុំ ហើយប្រាប់ថា វានេះរឹងណាស់ យកទៅឲ្យរៀនសូត្រ ហើយគេបន្តដើរលឿនដូចដើម ដោយអូសនារីនោះពីក្រោយ បីដូចជា សត្វគោក្របី ។ ខ្ញុំភ័យខ្លួន ព្រោះមិនគួរហ៊ានសួរបែបនេះសោះ បើសិនខ្មែរក្រហមនោះជាមនុស្សកំណាច ម៉្លេះសមនឹងចាប់ខ្ញុំដឹកទៅជាមួយបាត់ហើយ គ្មាននរណារកខុសត្រូវឡើយ ។ លុះម៉ោងប្រហែល១១យប់ យើងបានមកដល់ហ្វូងមនុស្សមួយក្រុម ហើយយើងពីរនាក់ឪពុកកូនត្រូវខ្មែរក្រហមឃាត់ឲ្យឈប់ដែរ រកកន្លែងដេករៀងៗខ្លួន ។ លុះព្រឹកឡើង ខ្ញុំឃើញមានកាណូតធំៗដំបូលពីរជាន់៤-៥គ្រឿង ចូលមកដឹកពួកយើង បត់បែនទៅតាមដងទន្លេមេគង្គមិនដឹងទៅជាយ៉ាងណាទេ គ្រាន់តែដល់កោះមួយ នោះពួកគេនិយាយថា កោះខកញាតិ ។ ដោយខែចេត្រទឹកស្រកអស់ច្រើន ទើបយើងអាចមើលឃើញខ្មោចកប៉ាល់ម៉ារីន សល់តែគ្រោងឆ្អឹងទទេ ព្រោះចាប់ក្រហមច្រាល ទើនៅតាមច្រាំងទន្លេ ប្រមាណ៥-៦គ្រឿង ។ ចរាចរផ្លូវទឹកនេះក៏មានស្នាក់ការកុងត្រូល ដែលចាក់មេក្រូបំពងសំឡេង ហើយកាណូតរបស់យើងក៏បានចូលធ្វើការទំនាក់ទំនងពីរឬបីស្នាក់ការដែរ ក្នុងពេលធ្វើដំណើរ ។ ការធ្វើដំណើរនេះ ស្ទើរតែរកពេលសម្រាកគ្មាន លុះត្រាដល់ម៉ោង៨យប់ ទើបកាណូតចូលចតច្រាំងឲ្យយើងសម្រាក ។ គឺនៅទីនោះ ហើយខ្ញុំត្រូវគេលួចកន្សែងសូត្រមួយក្រាស់ធំ រាងគ្រើមបន្តិចផលិតពីក្បាលសរសៃសូត្រ ដែលខ្ញុំចងដាយហាលលើដំបូលកាណូតក្បែរកន្លែងខ្ញុំដេក ។ ស្អែកឡើងបន្តដំណើរពេញមួយថ្ងៃទៀត រហូតដល់ពាក់កណ្តាលយប់ ទើបគេចូលចតនៅកន្លែងមួយ ដែលមានរទេះគោ១០-១៤គ្រឿង រង់ចាំជាស្រេចដើម្បីដឹកពួកយើងបន្តទៅមុខ ដោយមានបាយដាកញ្ចប់ៗសម្រាប់ឲ្យយើងហូបដែរ ។ដល់ភ្លឺព្រាងៗឡើង យើងចេញមកខាងក្រៅ ទើបឃើញ អក្សរសរសេរលើក្លោងទ្វារវត្តមួយថា "វត្តត្នោត" ក្នុងទឹកដីអូរលេង ខេត្តកំពង់ចាម ។ យើងដេកនៅក្រោមកុដិលោកមួយ មិនមានឃើញលោកទេ ដែលកំបាំងពីគេបន្តិច នៅយប់នោះខ្ញុំគ្រុនក្តៅរងាញាក់ ដោយបានគ្រួសារមួយមានគ្នាបីនាក់ អ៊ំប្រុសរាងចំណាស់ជាងឪពុកខ្ញុំឈ្មោះ មុជ, ប្រពន្ធ និងកូនប្រុសជំទង់ម្នាក់ ឈ្មោះ មុត បានឲ្យ ចំណិតគ្រាប់ស្លែងពីរបីចំណិតមកខ្ញុំលេប ហើយក៏បានធូរស្រាលទៅ ។ ចាប់ពីនោះមក យើងរាប់អានជាមួយគ្រួសារនេះ ដែលគាត់មានស្រុកកំណើតនៅភូមិអំពិល ចម្ងាយពីស្ពាន១០គីឡូម៉ែត្រ ក្នុងខេត្តកំពង់ចាមនេះតែម្តង ។

យើងមានឱកាសល្អមួយ បានក្រោកពីយប់លួចរត់ចេញពីវត្តត្នោត ហើយដួលទូកចាមចម្លងទៅត្រើយខាងលិចនៃទន្លេសំដៅទៅកាន់ភូមិអំពិល ។ យើងដើរពេញមួយថ្ងៃទៀត ដោយដើរតាមផ្លូវជាតិលេខ៧ ខ្លះដើរកាត់វាលស្រែសំដៅស្គន់ ។ លុះដល់ពាក់កណ្តាលយប់ ទើបបានដល់ភូមិអំពិល និងបានទទួលការស្វាគមន៍ពីគ្រួសារ អ៊ំមុជ ។ រហូតដល់ថ្ងៃស្អែកមួយថ្ងៃទៀត ធ្វើឲ្យខ្ញុំមានអារម្មណ៍កាន់តែនឹកស្រុក ។ តាមពិតភូមិអំពិលមិនមែនស្ថិតនៅ

លើផ្លូវជាតិលេខ៧ទេ គឺនៅខាងកើតផ្លូវតែបន្តិចប៉ុណ្ណោះ នៅទីនោះ យើងបានជួបមិត្តតាម្នាក់ឯកសណ្ឋានពាក់មួកកន្តឹប ទំពារម្លូបបូរមាត់ក្រហម សំឡេងស្អក និយាយបូរបាច់ក្រមាច់ក្រមើម ធ្វើឲ្យយើងទាំងអស់គ្នាសើច តែការពិតគាត់ជាមនុស្សស្រីសោះ ។ ថ្ងៃបន្ទាប់ ឪពុកខ្ញុំគាត់បានយកវិទ្យុ សាន់យូ មួយគ្រឿង ដូរកង់ចាស់មួយគ្រឿងពីក្មួយរបស់អ៊ំមុជ មានឈ្មោះ អុល, នឹងឈ្មោះ សៀម ។

**៧) អង្គការចាត់តាំងឲ្យរស់នៅសហករណ៍មួយ**

ថ្ងៃបន្ទាប់ខ្ញុំ និងឪពុកខ្ញុំចាប់ផ្តើមចេញដំណើរទៅទិសខាងលិចទៀតដោយឆ្លងកាត់ផ្លូវជាតិលេខ៧ ពីកើតទៅលិច ។ កង់នេះបានជួយសម្រួលដល់ការធ្វើដំណើរក្រៅពីការដើរដឹក យើងអាចជិះបានខ្លះដែរ តែតឹងណាស់ ព្រោះញាត់ចំបើងទាំងកង់ខាងមុខនិងក្រោយ ។ ពេលមួយនោះ ខ្ញុំដើរឡើងមកពីក្បង់ទឹកពីក្នុងត្រពាំងដឹក ស្រាប់តែខ្ញុំដើរធ្វើឲ្យមុតបន្លាអញ្ចាញនៅកែងជើងខាងស្តាំ ហើយបាក់ចុងបន្លាយ៉ាងជ្រៅនៅក្នុងនោះ ។ ចាប់ពីពេលនោះមកជើងខ្ញុំត្រូវខ្វិន ដើរកាន់តែឈឺប្រចាំ ឬដើរដំទើតជើងយឺតៗ ។ ការធ្វើដំណើរនេះ គឺតាមផ្លូវដែលមានស្រុកភូមិគេធម្មតា យើងមានសាច់មាន់ទាំងមូលឆ្អិនស្រាប់ដាក់ក្នុងកាមែលសំប៉ែតដែលយកបានពីភ្នំពេញមកនោះ ចងព្យួរសំយុងជាប់នៅរានកង់ខាងក្រោយ មិនដែលខ្វះខាតទេ ។ យើងបត់ឆ្វេងវិញម្តងគឺសំដៅចុះមកផ្លូវជាតិលេខ៦ តាមផ្លូវឈ្មោះ "បាខម" កាលបើមកដល់ផ្លូវជាតិលេខ៦ហើយ យើងខំស្រូតឆ្ពោះទៅកាន់ខេត្តសៀមរាប ។ ដល់កន្លែងមួយខាងមុខ ខ្មែរក្រហមបានឃាត់យើងទាំងពីរ និងមនុស្សមួយចំនួនទៀតឲ្យធ្វើប្រវត្តិរូប ហើយបែងចែកទៅតាមឈ្មោះឲ្យរស់តាមសហករណ៍ទៅ ។ ខ្ញុំ និងឪពុក ត្រូវចាត់ឲ្យរស់នៅក្នុងភូមិផ្លោងសង្កាត់ស្រឡៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ គឺម្តុំអាហារដ្ឋាន អ៊ីងចាន់វុធ ខាងកើតផ្សាររំលងប្រហែល១គីឡូម៉ែត្រ ។ ម្ចាស់ផ្ទះដែលខ្ញុំរស់នៅជាមួយឈ្មោះ សឿង សម្បុរសជ្រះ អាយុស្របាលឪពុកខ្ញុំដែរ ប្រពន្ធឈ្មោះ ជី មានកូនស្រីច្បងអាយុប្អូនខ្ញុំមួយឆ្នាំមានប្តីនៅភូមិផ្សេង និងកូនប្រុសតូចសម្បុរជ្រះដែរ ឈ្មោះ សុខមានពកលើខ្នងប្រមុះមួយ ។ ការងារក្នុងសហករណ៍ គឺឪពុកខ្ញុំ ត្រូវអង្គការចាត់តាំងឲ្យធ្វើនៅកងដាំដំឡូងមី ។ ចំណែកខ្ញុំ ជើងខ្វិនជួយជាន់អង្ករម្ចាស់ផ្ទះបន្តិចបន្តួច ។ មានអ្នក១៧មេសា ធ្វើដំណើរខ្លះដែរនៅផ្លូវជាតិខាងមុខផ្ទះ ខ្ញុំតែងអង្គុយលេង មើលការធ្វើដំណើរនេះ ខ្ញុំធ្លាប់បានអ្នកគ្រូពេទ្យចំណាស់ម្នាក់នៅសហករណ៍ជាមួយ ជួយដោះបន្លាជើងឲ្យនៅទីនោះ តែមិនបានសោះ ។ ឪពុកខ្ញុំបាននិយាយត្រូវជាមួយម្ចាស់ផ្ទះ ដោយយកនាឡិកាដៃខ្ញុំម៉ាក រ៉ាដូ៩៩៩ មួយគ្រឿងទិញទឹកចិត្តប្រធានក្រុម ហើយគាត់ទាំងពីរនាក់យកលេសធ្វើជាទៅរកត្រីនៅវាលរនាមដ៏ឆ្ងាយបាត់ទៅ ។ ម៉ោង៣ជិតភ្លឺយើងចុះពីលើផ្ទះដោយស្ងាត់ស្ងៀម នឹងបន្តដំណើរទៅលើផ្លូវជាតិលេខ៦ ដែលមានរទេះអ្នកដំណើរមួយគ្រឿងដើរអូសមុខយើងដោយមានភ្លើងទៀនអុជ ដាក់លើរទេះបំភ្លឺផ្លូវផង ឆ្ពោះទៅទិសខាងជើងដូចគ្នា ។ មិនយូរប៉ុន្មាន ពេលចេញផុតពីផ្សាររំលងប្រហែលមួយគីឡូ នៅខាងឆ្វេងដៃ មានមិត្តមួយក្រុម ឃាត់យើងទាំងពីរជាប់ទៀត ឲ្យចូលទៅក្នុងវត្តមួយឈ្មោះ វត្តស្វាយ ហើយខ្ញុំពីរនាក់ទៅសម្ងំនៅក្នុងតូបៗសំណាក់ធម៌នៅម្ខាងព្រះវិហារ ពោល គឺនៅឆ្ងាយពីក្រុមធំ ។ ភ្លឺច្បាស់ឡើង យើងឃើញមិត្តពីរនាក់ (គ្មានកាំភ្លើងទេ) ដើរក្បែរតូប ខ្ញុំភ័យណាស់ថា នឹងមកចាប់ តែតាមពិតគឺគេស្នាក់នៅតូបម្ខាងឯណោះយូរមកហើយ ។ ខ្ញុំតែងតែស្មៀកខោខ្មៅគេតារុងជើងវែងខ្សែយឺត នឹងអាវដៃខ្លី រាងចាស់បន្តិច ។ បើអ្នកដំណើរនៅក្នុងវត្តមកខ្ញីពូថៅធំមួយ ទៅពុះអុសអត់ជួបក្រុមមិត្តទេ គេហៅខ្ញុំថា "មិត្តខ្ញីពូថៅសិន!" ។ ឪពុករបស់ខ្ញុំខស្សរាហ៍ឈ្លបចូលទៅក្នុងវត្តក្លាប់សភាពការណ៍ទូទៅ ព្រោះមានមនុស្សអ្នកដំណើរនៅទីនោះរាប់រយនាក់ ។ យើងនាំគ្នាទន្ទេញ "ភូមិកំពង់ថ្មសង្កាត់បល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ" ដើម្បីចុះប្រវត្តិរូប ទើបគេឲ្យចេញ បើយើងប្រាប់គេត្រង់ គឺគេមិនឲ្យទៅឡើយ ច្បាស់ជាចាត់ឲ្យទៅនៅតាមសហករណ៍ដូចមុនទៀតមិនខាន ។ ឪពុកខ្ញុំបានអនុញ្ញាតឲ្យខ្ញុំចូលទៅលេងក្នុងវត្តនោះ ហើយជាដំបូងបានឃើញមនុស្សស្រីម្នាក់អាយុ៣០ឆ្នាំ ឈើញរ័ៗ ចុះពីលើជណ្តើរព្រះវិហារដាំដូងក្បាលមកមុន ក្រោកវិញស្ទើរតែពុំរួច ។ កំពុងតែផ្តោតអារម្មណ៍មើលទិដ្ឋភាពគួរឲ្យសង្វេគនោះ ស្រាប់តែឮសំឡេងមួយក្បែរត្រចៀកឆ្វេងខ្ញុំថា ផុនៗ ខ្ញុំភាំងបន្តិចទើបងាកយឺតៗមកដល់ម្ចាស់សំឡេងស្រាប់តែឃើញនារីសម្បុរស្រអែមម្នាក់សើចដាក់ ។ នាងមានឈ្មោះ សុម៉ាលី ធ្លាប់រៀនជាមួយគ្នាពីរឆ្នាំនៅអនុវិទ្យាល័យអង្គរ សៀមរាប ។ យើងឈរសំណេះសំណាលគ្នាក្នុងក្តីនឹក

រលឹក ព្រោះបែកគ្នាយូរដែរ តែមិនបានប៉ុន្មានផង ព្រោះមិត្តបេះតែ ងើបសម្ងំមកយើងពីរទៅបីដងយើងក៏បែកគ្នារហូតមក ។

ក្រោយពីការចុះប្រវត្តិរូបរួច យើងក៏បានធ្វើដំណើរតាមផ្លូវជាតិលេខ៦ ឆ្ពោះទៅជើងដូចការរំពឹងទុកមែន ។ នៅតាមផ្លូវយើងបានជួបអ្នកដំណើរប្រុសទិសដៅដូចយើងដែរ គាត់ជិះកង់ប្រុសមួយម្នាក់ឯង អាយុ៣០ឆ្នាំ សម្បុរជ្រះ កោរសក់ ស្រុកកំណើតនៅខេត្តបាត់ដំបង ទៅរកជួបប្រពន្ធកូនគាត់ បើតាមយល់គឺធ្លាប់ធ្វើទាហាន ។ យើងរួមដំណើរជាមួយគ្នា គឺគាត់ជិះឌុបឪពុកខ្ញុំ និងខ្ញុំជិះកង់របស់ខ្ញុំម្នាក់ឯងព្រោះញាត់ចំបើងជិះតឹងណាស់ តែងតែនៅពីក្រោយគាត់ទាំងពីររហូត ។ កាលពីយើងស្នាក់នៅវត្តស្វាយក្នុងតូបសំណាក់ធម៌ ពីរនាក់ឪពុកខ្ញុំ គាត់តែងឲ្យដំបូន្មានថា ហូបបាយដោយមានម្ហូបឆាញ់ៗ ជួយយើងឲ្យមានប្រាជ្ញា ។ នៅម្នាក់ឯងមិនល្អទេ តែបើមានគ្នាច្រើន មួយគិតមិនឃើញ មួយទៀតអាចគិតឃើញ ។ យើងប្រឹងស្រូតដំណើរទៅមុខណាស់ ទោះបីដល់គោលដៅដែលយើងបានចុះប្រវត្តិរូបនោះហើយក្ដី ក៏មិនឈប់ដែរ ហើយក៏គ្មានអ្នកដំណើរណាផ្សេងក្រៅពីយើងបីនាក់នោះដែរ ។ ដល់ម៉ោងប្រហែល៩យប់ មានទាហានខ្មែរក្រហមមួយក្រុម ចុះពីលើផ្ទះមួយខាងឆ្វេងដៃឃាត់កង់ខ្ញុំជាប់ សុំរើមើលវ៉ាលិស ខោអាវ គេក៏មិនបើកបន្ទះស្បែកបាតកាបូបទេ ដែលនៅក្នុងនោះមាន នាឡិកាដៃវ៉ាដូមួយគ្រឿង ខ្សែកមាសមានបន្តោងព្រះមួយខ្សែ ។ បន្តិចមកមានទាហានម្នាក់ទៀត ទើបមកដល់ក្រោយគេ ហើយប្រាប់អ្នកដែលមកដល់មុនថា ឲ្យគាត់ទៅចុះ ហើយកុំយកឥវ៉ាន់គាត់ ហើយអ្នកនោះ ក៏បិទភ្លើងពិលវិញទៅ ។ ខ្ញុំបន្តដំណើរទៅទៀត ប្រឹងធាក់កង់បណ្ដើរថា បើកុំតែបានប្រធានគេមកទាន់ កុំអីត្រូវអស់ម៉ាញ៉េ នីវីកូ និងកម្រាលពូកប៉ាវ៉ាញាត់ទៅក្នុងកំសៀវធំព្យួរដៃកង់នោះមិនខានឡើយ ។ ឪពុកខ្ញុំគាត់ឈប់កង់នៅចាំខាងមុខ ហើយគាត់ក៏ពុំបានជួបក្រុមយោធានោះដែរ ។ យប់ជិតពាក់កណ្ដាលអាធ្រាត្រទៅហើយ យើងសម្រាកក្បែរគុម្ពឫស្សីមួយនៅខាងឆ្វេងដៃ ក្បែរថ្នល់ជាតិ ខ្ញុំសម្រាកនៅកណ្ដាលគេ ហើយក៏ គ្មាននរណាមករំខានយើងឡើយ គ្រាន់តែភ័យបន្តិចនឹងស្នូរខ្យល់ ខ្ញុំស្មានតែចង្រ្កង់សេះរបស់ក្រុមមិត្តតែប៉ុណ្ណោះ ។ ព្រឹកឡើង យើងចូលទៅកាន់កន្លែងរំងាស់ស្ករត្នោតមួយកន្លែង ដើម្បីរកទឹកត្នោតផឹក ។ ក្រោយហូបទឹកត្នោតផ្អែមរួច ឪពុកខ្ញុំនិយាយតាមត្រង់ថា ក្រុមមិត្តៗនៅតាមដងផ្លូវពិសេស អង្គការនិយាយតែភូតភរកុហករកជឿមិនបាន ហើយបានអ្នកធ្វើស្ករប្រាប់ថា សូមបងកុំនិយាយឲ្យប៉ះពាល់អង្គការឲ្យសោះគឺមិនបានទេ! ។ ចេញពីរោងស្ករត្នោតមកវិញ ខ្ញុំក្រឡេកមើលទៅឆ្ងាយ ឃើញមានកំពូលភ្នំ ហើយភ្នំដែលមើលទៅស្គាល់ គឺភ្នំសន្ទុកដែលធ្វើឲ្យអារម្មណ៍ដែលនឹកស្រុកស្រាប់នោះ កាន់តែពុះកញ្ជ្រោលឡើងៗ ។ យើងឈប់ កង់បន្តិចដើម្បីពិគ្រោះ ព្រោះជិតចូលក្នុងក្រុងកំពង់ធំហើយ បើវាងក្រុងខ្លាចគេមើលឃើញ ព្រោះជុំវិញក្រុងនេះវាល្វឹងល្វើយ ។ យើងសម្រេចចិត្តឆ្លងកាត់ក្រុងហើយយើងទាំងអស់គ្នាត្រូវខ្មែរក្រហមឃាត់ម្ដងទៀត នៅស្ពានឆ្លងស្ទឹងសែន ពេលនោះ ខ្មែរក្រហមបានដកហូតកង់ និងម៉ាញ៉េអស់ នៅសល់តែកាបូបស្ពាយ និងកំសៀវទឹក ដើរកាន់ឈើច្រត់តាមពីក្រោយគាត់ទាំងពីរ ។ ការបន្តដំណើរទៅមុខ បញ្ហាគឺមានតែខ្ញុំម្នាក់ទេ ព្រោះមិត្តដកយកកង់ទៅបាត់ ខ្ញុំត្រូវបានឪពុកខ្ញុំសុំផ្ញើជាមួយមធ្យោបាយធ្វើដំណើរផ្សេងៗជាបន្តបន្ទាប់ ។ ចេញពីកំពង់ធំ ដំបូងជិះរទេះ បន្ទាប់មកជិះពីក្រោយកង់គេម្នាក់ ចេញពីឃុំប្រឡាយស្រុកស្ទោង ។ បន្តមក ខ្ញុំជិះរទេះដឹកត្រីឆ្អើរ មកដល់ផ្ទះមួយ ក្បែរគីឡូធំ (បង្គោលគីឡូព្រំប្រទល់ខេត្តសៀមរាប និងខេត្តកំពង់ធំ) ។ នៅទីនេះ ខ្ញុំត្រូវបានអ្នកភូមិមកសួរសុខទុក្ខ ខ្លះឲ្យបាយខ្លះឲ្យនំបញ្ចុក ហើយម្ចាស់ផ្ទះក្រាលកន្ទេលឲ្យដេកលង់លក់ទៅ ។

## ៨) លុះជួបជុំគ្រួសារបន្ទាចេញពីកែងដើង

លុះជិតភ្លឺខ្ញុំបានឮសូរសំឡេងមួយស្រែកសួរថា “ ម្ចាស់ផ្ទះៗមានឃើញប្រុសម្នាក់ដេកនៅទីនេះទេ! ខ្ញុំដេកជិតទ្វារ បានងើបមើលតាមប្រឡោះទ្វារឃើញភ្លើងចន្លុះមួយកាន់ចុះមក ហើយសួរនូវប្រយោគដដែលនោះម្ដងទៀត ខ្ញុំក៏ដឹងច្បាស់ថា ជាឪពុកខ្ញុំគាត់មានពាក់មួកស្លឹកហាមធំមួយផង ។ ដល់ភ្លឺស្រាងៗឡើង យើងទាំងបីនាក់បន្តដំណើរចូលដល់ទឹកដីខេត្តសៀមរាប ហើយឪពុកខ្ញុំបានផ្ញើខ្ញុំឲ្យទៅជិះលើរទេះគោដឹកជ័រទឹកក្នុងដំណើរនៃម្ចាស់រទេះឆ្ពោះទៅកាន់ឃុំកំពង់ល្ពង ។ រទេះយើងឆ្លងកាត់មន្ទីរស្រុកជីក្រែងដែលពុំមានការសួរនាំអ្វីពីទាហានខ្មែរក្រហមម្នាក់អង្គុយចាំនៅមាត់ផ្លូវនោះទេ ។ មកដល់ដើមពោធិ៍ខាងលិចស្ពាននាគ ឪពុកខ្ញុំបានជួបចិនម្នាក់ជាអ្នកកំពង់ឃ្លាំងដែរ ឈ្មោះ យូ ឈង់ ពាក់មួកជ័រ

ពណ៌សជិះកង់ ។ គឺស្ថិតក្នុងពេលដ៏កម្រនេះដែលយើងបានជួបជុំឡើងវិញ ក្រោយពីបែកគ្នា អស់រយៈពេល៥ឆ្នាំ (ឆ្នាំ១៩៧០ ដល់ ១៩៧៥) យ៉ាងយូរកន្លងមក ។ ដំបូងក្រុមគ្រួសារខ្ញុំទាំងអស់គ្នាហាក់បីដូចជាស្រឡាំងកាំងក្នុងពេលដ៏ប្រថុចញ៉ុចនេះ បន្តិចមកទើបឃើញម្ដាយខ្ញុំខ្សឹកខ្សួលស្រែកយំមុនគេ ហើយបន្ដមកទើបឮសូរសំឡេងយំកាន់តែច្រើនគ្នាឡើង សូម្បីតែជីដូនខ្ញុំភ្នែកងងឹតក៏ត្រដរវារចេញមកយំខ្សឹកខ្សួលនឹងគេដែរ ។ ក្រោយពេលសម្រួលឥរិយាបថបន្តិចមក យើងបានសួរសុខទុក្ខគ្នាទៅវិញទៅមកក្នុងក្ដីរំភើប ហើយពេលនោះខ្ញុំសំឡឹងមើលប្អូនស្រីខ្ញុំម្នាក់ស្ទើរតែមិនស្គាល់ ដូចជាសៀវ សុវុតនា រាងធាត់ក្រមប់ អង្គុយបត់ជើងក្នុងទឹកមុខញញឹមញញែម និងអៀនខ្មាស ។ ចំណែកនៅលើជើងជីដូនខ្ញុំ ឃើញក្មេងប្រុសម្នាក់ សម្បុរសណ្ដែកបាយ ស្លៀកខោខ្មៅវៀលត្រឹមក្រលៀន អាយុប្រមាណ១ឆ្នាំ -២ឆ្នាំ ត្រូវជីដូនខ្ញុំឱបជាប់ លុះក្រោយមកទើបស្គាល់ថា គេឈ្មោះ គង់ សូនិច ហៅ ញ៉ែម ជាកូនបងស្រីខ្ញុំ ។ គាប់ជួនពេលនោះ ប្អូនស្រីខ្ញុំបានលាន់មាត់ថា មានអ្វីខ្មៅចេញពីកែងជើងនោះ ខ្ញុំងាកមើលទៅឃើញបន្ទាអញ្ចាញដ៏ចង្រៃប្រវែងកន្លះថ្នាំងដៃ ដែលធ្វើឲ្យខ្ញុំខ្វិនជាយូរមកហើយ ។ ការធ្វើដំណើរចេញពីភ្នំពេញ មកដល់ភូមិថ្នល់តាសិត ឃុំគោកធ្លកក្រោម ស្រុកជីក្រែង យើងមានរយៈពេល២៨ថ្ងៃ ។

ក្រោយពេលហូបបាយថ្ងៃត្រង់រួច ទាំងរទេះដ័រទឹក និងបងប្រុសដែលជាអ្នកបាភ្នំផងនោះ ក៏ចេញដំណើរឆ្ពោះទៅទិសខាងលិចព្រមគ្នាបាត់ទៅ ។ យើងជួបជុំគ្រួសារមិនទាន់បាន១០ថ្ងៃផងទិសអង្គការត្រូវឲ្យជម្លៀសប្រជាជនថ្មីទៅកាន់ព្រៃស្នឹប ខាងលើភូមិថ្នល់តាសិតដែលខ្ញុំរស់នៅប្រមាណ២០គីឡូម៉ែត្រ ពេលនោះម្ដាយខ្ញុំគាត់ស្ម័គ្រចិត្តទៅជាមួយដែរ គ្រាន់បានធ្វើជាចុងភៅ ហើយយើងធ្វើដំណើរដោយរទេះគោយើងផ្ទាល់ ។ ឪពុកម្ដាយខ្ញុំជិះលើរទេះឯខ្ញុំដើរតាមពីក្រោយ រយៈពេលពេញមួយថ្ងៃទើបទៅដល់ ហើយស្នាក់នៅជាមួយអ្នកកំពង់ឃ្លាំងមួយគ្រួសារជាអ្នករដ្ឋការចាស់ដែលជម្លៀសមកនៅទីនោះយូរហើយ ។ ប្ដីគាត់ឈ្មោះ ស្មៀន អ៊ាង និងប្រពន្ធឈ្មោះ សុត មានកូនតូចៗបីនាក់ ។ នេះគឺជាលើកដំបូងហើយដែលខ្ញុំឮសត្វទោចយំយ៉ាងគ្រលួចពីលើចុងឈើក្នុងព្រៃធំ ហើយឪពុកខ្ញុំជាទម្លាប់មិនចេះនៅទំនេរទេ គាត់កាប់ គាត់អារដើមចំបក់ ធ្វើជាជ្រុញ និងធ្វើត្បាល់បុកតូចៗ ។ គាត់មានដែកអង្រួសរូសឈើថ្មីសន្ទាងមួយដៃ យកជាប់តាំងពីសៀមរាបខ្ញុំ ដល់ភ្នំពេញ និងយកមកដល់ទីនេះទៀត ដែលជាប្រយោជន៍ក្នុងការផលិតរបស់ទាំងនោះ ។ យើងនៅទីនោះ បានតែមួយអាទិត្យប៉ុណ្ណោះ អង្គការបានរំសាយយើងត្រឡប់មកភូមិថ្នល់តាសិតវិញ ។ យើងត្រេកអរណាស់ ហើយឪពុកខ្ញុំឲ្យជួយលើកជ្រុញ ប្រហែល១០ និង ត្បាល់បុក៤-៥ ដាក់លើរទេះ ទុកទៅដូរត្រីនៅកំពង់ឃ្លាំង ។ មិនតែប៉ុណ្ណោះ គាត់ឲ្យជួយលើកដើមចំបក់ដាក់ឡើងពេញហៀរលើរទេះថែមទៀត ទោះជាម្ដាយខ្ញុំ គាត់ឃាត់ថា ឈើនេះនៅថ្នល់តាសិតមានដែរ តែគាត់មិនស្ដាប់ ។ នៅថ្នល់តាសិត ម្ដាយរបស់ខ្ញុំមានស្រែមួយកន្លែងដែរ ដោយបងខ្ញុំយកម៉ូតូដូរឲ្យ ។ឆ្នាំនោះយើងទាំងអស់គ្នាធ្វើស្រែកើតណាស់ តែដល់ពេលប្រមូលផល អង្គការយកមកដាក់រួមទាំងដីស្រែ ហើយមនុស្សក៏ធ្វើការរួមដែរ ឈប់ជាក្រុមសាមគ្គីប្រវាស់ដៃទៀតហើយ ។

## ៩) គ្រោះភ័យច្រើនដងក្នុងកងចល័ត

គ្រួសារយើងទាំងមូលរស់នៅក្នុងភូមិថ្នល់តាសិត ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប ជាប់ថ្នល់ជាតិលេខ៦ ចម្ងាយ៧គីឡូម៉ែត្រ ខាងលិចទីរួមស្រុកជីក្រែង ។ នៅទីនោះ អំណោយផលល្អដែរ ដល់ជីវភាពរស់នៅព្រោះសម្បូរផលស្រូវ និងមានត្រីសាច់ហូបចុកគ្រប់គ្រាន់ ។ ឪពុកខ្ញុំ មិនសូវបាននៅភូមិទេ អង្គការច្រើនឲ្យគាត់ទៅរកត្រីនៅតំបន់ជិតបឹងទន្លេសាប ចំណែកខ្ញុំជាមួយប្អូនស្រីពីរនាក់ទៀត ស្ថិតនៅក្នុងកងចល័ត ។ ដោយខ្ញុំជាអ្នក១៧មេសា ទោះបីជាមានបងប្អូនទាំងអស់រស់នៅតំបន់រំដោះយូរមកហើយក្ដី ខ្ញុំនៅតែទទួលការរើសអើងពីអ្នកមូលដ្ឋានចាស់ខ្លះដែរ សូមបញ្ជាក់ ថាជាបងប្អូននឹងម្ដាយខ្ញុំត្រូវបានអង្គការជម្លៀសចេញពីស្រុកកំណើតនៅកំពង់ឃ្លាំង កាលពីឆ្នាំ១៩៧៣ ។ យើងទាំងអស់គ្នារស់នៅតាមកងចល័ត ហូបបាយរួម ធ្វើការរួមគ្មានថ្ងៃសម្រាកទេ ខួបប្រាំង ខួបវស្សា ។ ខ្ញុំអាណិតម្ដាយ គឺមានថ្ងៃមួយ ខ្ញុំសុំគេមកលេងផ្ទះថ្ងៃរសៀល ម្ដាយខ្ញុំចាក់នំបាញ់ឆែវឲ្យហូប ។ លុះចាក់បានមួយ គាត់ឲ្យខ្ញុំហូបមួយ ពេលចាក់បានពីរ គាត់ឲ្យខ្ញុំហូបពីរ លុះចាក់ដល់លើកទី១៤ ខ្ញុំហូបអស់ទៀត ហើយបាញ់ឆែវក៏អស់ត្រឹមនេះដែរ ។ ខ្ញុំសែនអាណិតគាត់

ណាស់ ព្រោះគាត់ពុំបានពិសារបន្តិចសោះ ។ ខ្ញុំប្រែទឹកមុខជាក្រៀមក្រំ តែគាត់បែរជាសើចក្អាកក្អាយដើម្បីលួងលោមចិត្តខ្ញុំកុំឲ្យទឹករំពុកសង្ខេគដល់គាត់អី ។

ថ្ងៃមួយនារដូវវស្សាខ្ញុំ ចុងឆ្នាំ១៩៧៥ ខ្ញុំបានជួបផ្ទាល់នូវហេតុការណ៍ភ័យរន្ធត់ គឺកាលនោះក្រុមអាវខ្មៅបានចុះមកដល់ចាប់អ្នក១៧ខ្ញុំ មេសា នៅក្នុងភូមិថ្នល់តាសិត ដើម្បីយកទៅវាយចោល ។ ខ្ញុំភ័យពេកបានឡើងទៅលើផ្ទះ បង្អើបស្បូវលួចមើលទៅមុខថ្នល់ជាតិ បានឃើញខ្មែរក្រហមចងមនុស្សបណ្ដើរផង ឌុបដាក់លើកង់ផង ដួនឃើញពីស្ដាំដៃ ដួនឃើញមកពីឆ្វេងដៃតម្រង់ទៅកាន់ឡាន ទ្រុងមួយគ្រឿង ដែលមានបញ្ឈរចាំនៅមុខស្នាក់ការសង្កាត់ជាប់នឹងផ្លូវជាតិលេខ៦ ។ ខ្មែរក្រហមសាហាវណាស់ សូម្បីតែពូម្នាក់គាត់ថ្ងូរចង្អោះក្រោកពុំរួច ក៏វានាំគ្នាលើកដាក់លើកង់ឌុបយកទៅបាត់ដែរ ។ ស្ថិតក្នុងហេតុការណ៍នេះ ខ្ញុំបានសម្រេចចិត្តធ្វើអត្តឃាតដោយដៃស្ដាំកាន់កូនដបថ្នាំពុលអង់ទ្រីន ដែលលាក់ទុកជាយូរមកហើយ គ្មានអ្នកណាដឹង ។ បើសិនឃើញក្រុមអាវខ្មៅណាម្នាក់ចុះដើរលុយទឹកតម្រង់មកកាន់ផ្ទះខ្ញុំ ខ្ញុំៗនឹងបញ្ចប់ជីវិតពេលនោះតែម្ដង ។ ក្រុមវាចតឡាន រួចដើរចាប់មនុស្សចាប់តាំងពីថ្ងៃរសៀលដល់ថ្ងៃជិតលិច ទើបវាបើកឡានដឹកប្រជាជនទាំងនោះទៅកាន់មន្ទីរស្រុកជីក្រែងបាត់ទៅ ។ ចូលមកដល់ឆ្នាំ១៩៧៦ ស្ថិតនៅក្នុងកងចល័តខ្ញុំ ខ្ញុំជួបគ្រោះភ័យពីរលើកទៀត តែមិនខ្លាំងដូចលើកទីមួយនោះទេ ។ កន្លែងកងចល័តស្នាក់នៅអចិន្ត្រៃយ៍ធំជាងគេក្នុងសង្កាត់គោកធ្លកក្រោម ឈ្មោះ ទួលឆ្អេះ ស្ថិតនៅក្នុងភូមិដូនរាជ ។ ក្នុងយប់មួយ មានភ្លៀងធ្លាក់ខ្លាំង និងរលឹមស្ទើរទល់ភ្លឺខ្ញុំ ខ្មែរក្រហមចាប់បានអ្នកថ្មីឈ្មោះ វុត, ចូរ, ថន និងមនុស្ស៤-៥នាក់ ។

មួយលើកទៀតនៅប្រឡាយទឹកដងទង់ ក្នុងភូមិដូនរាជដដែល ។ ឈ្លបចាប់ពេទ្យ ហេង រាងស្ដើង សម្បុរសជ្រះ ដែលធ្លាប់រាប់អានខ្ញុំយកទៅបាត់ទៀត ។ មួយថ្ងៃបន្ទាប់មក ទើបខ្ញុំដឹងរឿងនេះតាមរយៈ មនុស្សស្គាល់គ្នានៅក្រុមជាមួយ ហើយបានប្រាប់ខ្ញុំថា ឲ្យប្រយ័ត្នខ្លួន ។ ខ្ញុំភ័យពេកនៅពេលយប់នេះ ខ្ញុំលួចរត់មកផ្ទះដើម្បីទទួលភាពកក់ក្ដៅពីម៉ែ បងប្អូនបានប្រាប់ខ្ញុំឲ្យក្រោកពីយប់ត្រឡប់ទៅអង្គភាពវិញ ដើម្បីកុំឲ្យអង្គការចាប់ថ្នាក់បាន ។ ក្រោយពីអង្គការដកខ្ញុំឲ្យទៅខាងរកត្រីនៅកំពង់ឃ្លាំង ដាំដំណាំនៅកំពីងបឹងក្នុងព្រៃនាម នៅខែមិថុនា ឆ្នាំ១៩៧៧ ខ្ញុំរួមជាមួយនឹងអ្នកដែលទើបរៀបគ្រួសារថ្មីសរុបទាំងអស់ប្រហែល១២នាក់ (គ្មានអ្នកមូលដ្ឋានចាស់ទេ) ជាអ្នករស់នៅក្នុងភូមិថ្នល់តាសិតខ្ញុំ ត្រូវអង្គការចាត់តាំងឲ្យទៅវាយថ្មនៅជាយក្រុងសៀមរាប ។ យើងជិះឡានរបស់ស្រុកមួយគ្រឿងដែលមានស្នាមប្រឡាក់ឈាមតាមជញ្ជាំងឡានខាងក្នុង ដឹកយើងទៅកាន់ក្រុងសៀមរាប ។ ការវាយថ្មនេះ គឺវាយយកតែថ្មធំៗ ថ្មភ្នំក្រោម ទៅធ្វើទ្វារទឹកស្រូវប្រាំងរនាមខ្ញុំ ក្នុងស្រុកជីក្រែង ។ ពេលចូលវាយថ្មដំបូង គឺចូលក្នុងក្រុង យើងបានមើលពីចម្ងាយឃើញមនុស្សប្រុសពីរនាក់ ស្លៀកខោអាវខ្មៅលើជង្គង់ ពាក់អាវខ្មៅដៃខ្លីដូចគ្នា ដើរក្នុងកាយវិការរហ័សរហួនលើផ្លូវជាតិលេខ៦ ពីខាងស្ពានថ្មព្រះរាជដំណាក់សំដៅមកទិសខាងកើតប្រាសទិសគ្នាជាមួយយើង ។ ស្រាប់តែមកដល់ទន្ទឹមគ្នា ខ្ញុំចង់ស្រែកបន្តិច ចង់យំបន្តិច ព្រោះពុំមែនជាមនុស្សទៅវិញ តែបើជាមនុស្សក៏មិនដឹងថាអាយុប៉ុន្មានត្រូវដែរ ព្រោះមុខអ្នកទាំងពីរផុសចេញសុទ្ធតែឆ្អឹង ភ្នែករូងជ្រៅស្ទើរមិនឃើញគ្រាប់ គ្មានសក់ កដៃប៉ុនដងវែក ក្បាលជង្គង់ធំជាងក្បាល ខោអាវបែរជារលុង រហែកច្រៀកង៉ៀត ។ កាលខ្ញុំវាយថ្ម នៅមុខនាគ (អង្គរវត្ត) មានអនុស្សាវរីយ៍មួយ គឺនាយប់នោះកំពុងតែហូបបាយ ពូកម៉ាកខ្ញុំឈ្មោះ សាំង ស៊ាន កូនលោក សាំងទ្រី (ខ្មែរឥស្សរៈ) ខ្សឹបប្រាប់ខ្ញុំថា គាត់បានរកទឹកបានកន្ទះកូនចានដែក លាក់ទុកល្អហើយ ។ លុះបាយរួចខ្ញុំលើកដឹកក្រោយ ស៊ាន ឃើញសុទ្ធតែកាកបាយ នឹងឆ្អឹងត្រីនៅបាតចានដោយងងឹត ទោះបីចង់កួនក៏កួតមិនចេញ ។ ក្រោយៗមកទៀត គឺមុនវាយខឿនព្រះវិហារ វត្តស្វាយរមៀត (មានសុទ្ធតែថ្មធំៗនៅភ្នំក្រោម) ខ្ញុំពីរនាក់ពូកម៉ាកឈ្មោះ ស៊ាន ដដែលបានលួចឡើងទៅសុំខមាទោសពីព្រះពុទ្ធរូបលើព្រះវិហារ ។ ពេលចុះមកវិញ ស៊ានបានយកធ្យូងសរសេរបណ្ដាំលើជញ្ជាំងថ្មខ្ញុំពណ៌សនៃហោត្រ័យមួយកណ្ដាលទីធ្លាវត្ត ទុកឲ្យប្អូនប្រុសគេឈ្មោះ សាំង សួត ដែលបាត់ខ្លួនមកទិសខាងលិចដើមឆ្នាំ១៩៧៧ ។

លុះត្រឡប់មកពីវាយថ្មនៅសៀមរាបវិញ អង្គការដឹកហួសមកទម្លាក់ចោលនៅមន្ទីរស្រុកជីក្រែង ដល់យប់ជ្រៅបន្តិច អង្គការឲ្យរែកចានឆ្នាំង ធ្វើដំណើរទាំងយប់ទៅកាន់សំណង់ទ្វារទឹកបាក់បែកក្បែរវត្តនីន ទំនប់ម្កាក់ ក្នុងឃុំគោកធ្លកលើ ។ មិនទាន់បានដេកផង

អង្គការបានចែកញញួរទម្ងន់៥គីឡូក្រាមម្នាក់មួយ ឲ្យចុះទៅវាយថ្មបេតុង នៅបាតស្ទឹងដែលគេតែងហៅថា ប្រឡាយបញ្ជោត ។ ការងារនៅទីនោះ គឺធ្ងន់ធ្ងរឥតគណនា ។ កម្លាំងទី១ វាយញញួរធំបំបែកបេតុង កម្លាំងទី២ វាយទាញយកដែកសសៃ និងកម្លាំងកូនស្រីវាយញញួរតូចយកថ្មមួយគុណនឹងពីរ ។ ម៉ោងធ្វើការក្រោកពីម៉ោងបួនជិតភ្លឺ ដល់ម៉ោង១១សម្រាក បន្តពីម៉ោង ១រសៀល ដល់ម៉ោង៥ ល្ងាចពីម៉ោង៧យប់ ដល់ម៉ោង១១ យប់ ដូច្នេះ ធ្វើការ ១៥ម៉ោងលើ២៤ម៉ោង បើមានថ្ងៃណាប្រជុំកង ម៉ោងមួយរំលងអាធ្រាត្រទើបបានសម្រាក ។ បាយហូបម្នាក់មួយវែកក្នុងមួយពេល ហើយមួយថ្ងៃហូបតែពីរពេល ម្ល៉ោះហើយកម្លាំងថមថយជាបន្តបន្ទាប់ យើងលួចបេះស្លឹកឈើហូបខ្លះ រួចហើយក៏ដឹកទឹកដេកទៅ ។ នៅទីនោះ ប្រជាជនទាំងអស់ដែលមកពីគ្រប់ទិសទី មានប្រុសស្រី មានចាស់ មានក្មេងប្រហែល៧០នាក់ ជួនកាលអង្គការប្រើឲ្យរែកខ្សាច់ពីបាតស្ទឹងយកមកលើដែលមានជម្រៅកម្ពស់ចុងត្នោត ។

រសៀលថ្ងៃមួយ ប្រធានកងនៅទីនោះ ស្រែកហៅឈ្មោះអ្នកភូមិថ្នល់តាសិតដែលមានប្រពន្ធ កូនទាំងអស់ រួមជាមួយ ស៊ាន ពីបាតស្ទឹងកន្លែងវាយថ្មឲ្យឡើងទៅលើ យើងជាយុវជន ជួយភ័យពីវាសនារបស់អ្នកទាំងនោះ ។ បន្តិចមកទៀត ពួកម៉ាកខ្ញុំ ម្នាក់ឈ្មោះ តុង គូ បានស្រែកហៅឈ្មោះខ្ញុំម្នាក់ទៀតឲ្យឡើងទៅលើដែរ តែខ្ញុំបែរជាទន់ជើងងងឹតរកចង់ដួលមួយរំពេច ខ្ញុំក៏ប្រឹងទប់អារម្មណ៍ ប្រមូលស្មារតីឡើងវិញ ខំប្រឹងឡើងប្រាំងទាំងគ្មានព្រលឹងនៅក្នុងខ្លួនបន្តិចសោះ ។ លុះឡើងមកដល់ខាងលើ ទើបគេប្រាប់ខ្ញុំថា អង្គការរំសាយអ្នកដែលមានប្រពន្ធកូនឲ្យទៅផ្ទះវិញ ហើយមិត្តខ្ញុំឈ្មោះ តុង គូ បានហុចថ្នាំជក់មួយកញ្ចប់មកឲ្យខ្ញុំព្រមទាំងស្រដីថា “សំឡាញ់គ្នាលាឯងហើយ ចូរនៅឲ្យបានសុខចុះ” ។

មានពេលមួយ ក្រោយពេលបញ្ចប់ការងារយប់ជ្រៅម៉ោង ១១យប់ អង្គការបានហៅប្រជុំស្តាប់ការសម្រួលសតិអារម្មណ៍ រវាងមនុស្សពីរនាក់ (អ្នករំសាយពីជួរ) មានទំនាស់គ្នា ក្នុងនោះមិត្តម្នាក់ឈ្មោះ មិត ចំណែកមិត្តម្នាក់ទៀត (មិនចាំឈ្មោះ) ដែលនិយាយបំបះបំបោរ ។ តាមពិតមិត្តទាំងពីរនោះ និយាយឆ្លងឆ្លើយគ្នាតាមតែការយល់សុបិនតែប៉ុណ្ណោះ ។ ដល់ដើមឆ្នាំ១៩៧៩ ខ្ញុំបាននឹកឃើញពីរឿងនេះ ។ យើងនៅទីនោះបានរយៈពេលបីខែ ក៏មានសភាពកាន់តែប្រែប្រួល ព្រោះត្បិតជួនកាលបាត់មនុស្ស៥ - ៦ នាក់ ដែលធ្លាប់ឃើញ ហើយមានមនុស្សមុខប្លែកៗមកជំនួសវិញ ដូច្នេះសេចក្តីភ័យ ខ្លាចកាន់តែខ្លាំងឡើងៗ ។

ថ្ងៃបន្ទាប់មកទៀត ពូម្នាក់ឈ្មោះ អាន (មានដុះពុកមាត់ខ្មៅក្រាស់) គាត់ជាអ្នកវាយតម្រង់ដែក នៅមាត់ផ្លូវចុះទៅធ្វើការ នៅបាតស្ទឹងបានបាត់ខ្លួនទៀត ។ ពេលយប់មកដល់ ខ្ញុំដេកមិនលក់ទេ រវើរវាយ ហើយតែងតែនឹកស្ងើចសសើរមិនដាច់ដល់ឪពុកខ្ញុំដែលពូកែប្រមូលយកព័ត៌មានបានហើយ ធ្វើការវាយតម្លៃច្រើនបានត្រឹមត្រូវទៀត ដូចជា គាត់ដឹងមុនថា ភ្នំពេញត្រូវវាយដាច់ គាត់ចេញពីខេត្តសៀមរាបទៅរកខ្ញុំនៅភ្នំពេញទាំងតក់ក្រហល់ ។ មិនត្រឹមតែប៉ុណ្ណោះ គាត់ដឹកដៃខ្ញុំចេញពីភ្នំពេញនាំមកដល់ស្រុកកំណើតទៀតផង តែបើគ្មានគាត់ដឹកនាំឲ្យចេញទេ ម្ល៉េះសមខ្ញុំត្រូវប្រឈមមុខនឹងការបាត់ខ្លួនដូចមនុស្សមួយចំនួនទៀតពុំខាន ហើយកូនខ្ញុំ ចៅខ្ញុំ ដែលកំពុងអានសៀវភៅនេះ ក៏ពុំបានបដិសន្ធិលើវដ្តសង្សារនេះដែរ ។ ការស្នាក់នៅគីក្រុម ខ្ញុំមានអង្រឹងគ្រប់ដៃដេករួមជាមួយអ្នកដទៃទៀតក្នុងរោងធំប្រក់ស័ង្កសី ជាងរោងផ្សេងទៀតបន្តិច ហើយប្រធានកងតែងលួចស្តាប់យើងនៅតាមរោងជាញឹកញាប់ ។ ប្រធានកងដែលចុះដាប់ការងារ ជាមួយរាល់ថ្ងៃមានឈ្មោះ ជន នៅភូមិព្រៃធំ ឃុំគោកធ្លកលើ អនុប្រធានឈ្មោះ ធី នៅភូមិស្វាយចេក ឃុំពង្រលើ នឹងចំណែកមិត្តអ្នកក្តាប់ធំជាងគេឈ្មោះ ស៊ិន ជាអ្នកភូមិកកោះ ឃុំគោកធ្លក ក្រោមនេះឯង ។

## ១០) ព្រះធម៌ និងព្រះគុណមាតាបិតា

នៅក្នុងគុកឥតជញ្ជាំងនេះ គឺមានវិន័យតឹងតែងណាស់ ហាមដើរចូលភូមិ ហាមដើរហើរសេរី ហាមដុតភ្លើងចម្អិនអាហារ ហាមអង្គុយជជែកគ្នាលេង ដេកពួនឲ្យស្ងាត់ស្ងៀម ។ រាល់យប់ខ្ញុំតែងដេកប្រណម្យដោយស្ងៀមស្ងាត់នៅក្នុងអង្រឹងមិនឲ្យនរណាដឹងឡើយ គឺរំឭកគុណមាតាបិតា ជីដូនជីតា គ្រូអាចារ្យ អ្នកមានរិទ្ធិចេស្តាគ្រប់ទិសទី និងព្រះធម៌ទាំងអប្បាលមាណដែលខ្ញុំនៅចងចាំ (ពេលបួសជាសាមណេរ) សូមជួយខ្ញុំឲ្យបានរស់រានមានជីវិត និងបានទៅជួបអ្នកមានគុណវិញ ។ ដោយបារមីនៃគុណបុណ្យទាំងនេះ ទើបនៅរាល់ហេតុការណ៍ធំៗ ដែលនឹងអាចកើតនៅក្នុងពេលខាងមុខ រមែងតែងតែឲ្យខ្ញុំបានដឹងជាមុន ។ នៅភូមិថ្នល់តាសិតឯណោះវិញ ឪពុក

ម្តាយ បងប្អូនខ្ញុំភ័យណាស់ ពិសេស បងណូ បានគិតគូរដោះស្រាយយកខ្ញុំទៅភូមិវិញ ក្រោមរូបភាពនៃការ «រៀបគ្រួសារ» ដែលមាន បងរ៉ុង ប្រធានភូមិថ្នល់តាសិត ជាពួកម៉ាក បងណូ ទៅទាក់ទងជាមួយនឹង មិត្តសុខ,មិត្ត សន គណៈស្រុកជីក្រែង អ្នកខេត្តតាកែវ ដូចគ្នា ។ ចំណែកពូ យូ ម៉េងគួន រស់នៅភូមិបែកខ្សាច់លើ ឃុំអន្លង់សំណ ដែលជាអ្នកកំពង់ឃ្លាំងដែរនោះ ជួយយកអាសាដោយធ្វើជាអ្នកជ្រើសរើសរកប្រពន្ធអ្នកភូមិជាមួយគាត់ឲ្យ ។

ឱកាសមួយ នៅឯគុកឥតជញ្ជាំងឯណោះ មិត្តស៊ិន បានឲ្យគេមកហៅខ្ញុំថាឲ្យទៅជួបគាត់មួយភ្លែត ខ្ញុំភ័យណាស់ខ្លាចចាប់ខ្លួន ។ ខ្ញុំក៏ប្រញាប់ប្រញាល់ទៅជួបគាត់ លុះទៅជិតដល់ ឃើញ បងណូ សើចដាក់ខ្ញុំពីចម្ងាយ រួចឃើញ បងរ៉ុង ប្រធានភូមិថ្នល់តាសិត និង មិត្ត ស៊ិន ដោយមានកងឈ្លប ទាំងបីនាក់ ដូចការយល់សុបិនរបស់ខ្ញុំ ។ ក្រោយពី មិត្ត ស៊ិន ធ្វើសតិអារម្មណ៍ដល់ខ្ញុំរួច គាត់ក៏អនុញ្ញាតឲ្យខ្ញុំធ្វើដំណើរទៅភូមិវិញ ក្នុងពេលនោះតែម្តង ដោយមិនបានដឹងខ្លួនពីមុនសោះ ។ តាមពិត គឺបងណូ , បងរ៉ុង មកទំនាក់ទំនងលើកមុនម្តងរួចមកហើយៗ មកលើកនេះក៏គ្មានសំបុត្រពីគណៈស្រុកមកដែរ គ្រាន់តែប្រាប់មាត់ទទេ ។ លុះក្រោយ ទើបទទួលដំណឹងថា លោក ម៉ក់ ហ៊ីម ,លោក តុង ហុក និង លោក អេង បានបាត់ខ្លួន ចំណែក លោក ម៉ក់ ដុង ដែលជាបងបង្កើតលោក ម៉ក់ ហ៊ីម ត្រូវខ្មែរក្រហមបាញ់ចំក្បាលស្លាប់ក្រោយផ្ទះនៅភូមិថ្នល់តាសិត ។ ថ្ងៃគងមាត់ព្រៃទៅហើយ បងរ៉ុង ជិះកង់មួយ ចំណែក បងណូ គាត់ជិះឌុបខ្ញុំ តែបើឲ្យខ្ញុំជិះវិញ ក៏ប្រហែលជាឌុបគាត់មិនរួចដែរ ព្រោះគ្មានកម្លាំង ហើយទម្ងន់ខ្ញុំប្រហែលមិនដល់៥០គីឡូក្រាមផង ។ ប្រហែលម៉ោង៨យប់ យើងបានមកដល់ផ្ទះនៅភូមិថ្នល់តាសិត ពេលនោះម្តាយខ្ញុំ ប្អូនស្រីខ្ញុំ នាំគ្នាយំស្វាគមន៍ទទួលខ្ញុំដូចកាលពីយើងជួបគ្នាលើកដំបូងយ៉ាងដូច្នោះ ដោយនាំគ្នាស្ទាបមើលបាតដៃខ្ញុំ ដែលស្បែកគ្រើមជាងបាតជើងទៀត ។ ពេលដំបូង ខ្ញុំហូបបាយអស់មួយចាន ខ្ញុំប្រាប់បងប្អូនថា មិនចាំបាច់មានត្រីសាច់ក៏បាន ព្រោះបាយពិតជាមានរសជាតិផ្អែមពិតៗ គឺខ្ញុំទើបតែដឹងក្នុងពេលនោះឯង ។ មកដល់ពេលនេះ រយៈពេល៨ខែ ទើបបានជួបក្រុមគ្រួសារវិញ ។ ខ្ញុំជាមួយឪពុកម្តាយព្រមទាំងបងប្អូនទាំងអស់ បានចូលរួមធ្វើមីទីងក្នុងពិធីផ្សំផ្គុំគូស្រករថ្មីនៅភូមិបែកខ្សាច់ខាងលើ ឃុំអន្លង់សំណរ សរុបចំនួនពីរគូ ក្រោមការចូលរួមពីគណៈភូមិបែកខ្សាច់លើ គណៈភូមិដង្ហិត និង គណៈភូមិថ្នល់តាសិត នៅថ្ងៃទី ២០កុម្ភៈ ឆ្នាំ១៩៧៨ ត្រូវនឹងថ្ងៃ ១៣កើត ខែមាឃធំ ឆ្នាំម្សាញ់ ។ កាន់តែអស្ចារ្យទៀតនោះ គឺទិដ្ឋភាពនៃផ្ទះប្រពន្ធខ្ញុំនៅភូមិបែកខ្សាច់លើនេះ ក៏ដូចគ្នានឹងការសុបិនរបស់ខ្ញុំទៀត ។ ដូច្នេះហើយ បានជាខ្ញុំតែងតែខិតខំព្យាយាមគោរពប្រណិប័តន៍គុណបុណ្យទាំងនោះ រហូតមកដល់ពេលនេះ នឹងបន្តទៅមុខទៀត លុះដល់ជីវិតចុងក្រោយ ។

## ១១) ការបៀតបៀនជីវិតនៅតែជាបញ្ហា

យើងទាំងពីរគ្រួសារថ្មោងថ្មី អង្គការចាត់តាំងឲ្យទៅលើកទំនប់ស្ពង ឬទំនប់៧៨ (ធ្វើឡើងនៅឆ្នាំ១៩៧៨) ដូចអ្នកដទៃទៀតដែរ ស្ថិតនៅក្នុងស្រុកជីក្រែងទាំងមូល ។ ខ្ញុំលើកចបកាប់ដី គឺស្រាលដូចសំឡី ហើយបន្តសាកល្បងកាប់រហូតដល់ទៅ១០០ចប ក៏អត់មានអីដែរ ព្រោះកាលខ្ញុំនៅវាយថ្ម ខ្ញុំកាន់ញញួរទម្ងន់៥គីឡូក្រាមវាយបំបែកផ្ទាំងថ្មបេតុង ក្នុងមួយថ្ងៃរាប់ម៉ឺន រាប់ពាន់ញញួរ ។ មកដល់ទីនោះ មានការធូរស្រាលណាស់ បាយទឹកហូបចុកឆ្អែតទៀតម៉្លោះហើយ ខ្ញុំមានអារម្មណ៍ដូចបានកើតម្តងទៀត ។

រដូវវស្សាបានចូលមកដល់ អ្នកភូមិខ្សាច់លើ ក៏ត្រូវឡើងមកបន្តការងារបង្កបង្កើនផលស្រូវរដូវវស្សាដូចបណ្តាភូមិដទៃដែរ ។ ការរស់នៅរវាងខ្ញុំ និងម្តាយក្មេក មិនសូវចុះសម្រុងគ្នាទេ តែងបង្កនូវភាពរកាំរកូសមិនចេះមិនចប់ហើយ ។ នៅឆ្នាំនេះទឹកធំណាស់ បណ្តាលឲ្យលិចស្រូវវស្សាអស់ ហើយភូមិបែកខ្សាច់លើ យើងបានឡើងទៅសុំដីអ្នកភូមិសណ្តាន់ និងភូមិដូនសុខ ក្នុងឃុំជីក្រែង ។ ដល់រដូវប្រមូលផលកាត់ អង្គការចាត់តាំងឲ្យដឹកផលស្រូវជាមួយឈ្មោះ ឌី ប្រពន្ធឈ្មោះ ឡាង សរុបចំនួន ពីររទេះ យកមកដាក់ជង្រុកនៅសហករណ៍ភូមិខ្សាច់លើជារៀងរាល់ថ្ងៃ ។ ថ្ងៃមួយ ខ្ញុំកំពុងកាន់ខ្សែគោ ឲ្យគោស៊ីគល់ជញ្ជ្រាំងនៅភូមិសណ្តាន់ ត្រូវបង ម៉ក់ សូម៉ាលី ហៅ ធរ ជាបងជីដូនមួយសាច់ថ្លៃខាងប្រពន្ធខ្ញុំ ដើរមកប្រាប់ខ្ញុំ ដោយគ្មានអាវ ទាំងកណ្តាលថ្ងៃក្តៅថា ឲ្យប្រយ័ត្នខ្លួន ព្រោះលោក យូ ម៉េងគួន គាត់ខឹងខ្លាំងណាស់ជុំវិញ រឿងហេតុដែលខ្ញុំមានទំនាស់ជាមួយនឹងម្តាយក្មេក ។ រំពេចនោះ ស្រាប់តែគាត់ឱនមុខចុះ ដោយបន្តថា គួន គេដើរតម្រង់មកហើយៗ បងក៏លាទៅដែរ ។

មែន គ្រាន់តែពូដើរមកដល់ភ្លាម បានបង្គាប់ឲ្យខ្ញុំរៀបចំ

រទេះនឹងសម្ភារស្នាក់នៅ ទៅដឹកសំណាបនៅវត្តពញាព្រហ្ម ក្នុងឃុំស្ពានត្នោតមួយរយៈ គឺយកតែម្នាក់ទេ ហើយឲ្យទៅល្ងាចនេះកុំខាន ។ គាត់ចេញទៅផុតបន្តិច ខ្ញុំគិតថា ប្រហែលជាគាត់កុំគួនខ្ញុំយូរមកហើយ តែខ្ញុំពុំបានដឹងព្រោះអីកន្លងមក គាត់ជាអ្នកចូលទៅស្ដីដណ្ដឹងប្រពន្ធឲ្យខ្ញុំ ហើយពេលនេះបានប៉ះពាល់ដល់កិត្តិយសគាត់ធ្វើឲ្យគាត់ខកចិត្តយ៉ាងខ្លាំង ។ អំពីអត្តចរិតពូ បើតាមខ្ញុំយល់ជាមនុស្សត្រូវការមុខមាត់ និងឥទ្ធិពល គាត់ជាគ្រូបង្រៀនម្នាក់នៅក្នុងភូមិ ហើយប្រពន្ធគាត់ត្រូវជាប្អូនស្រីបង្កើតរបស់ប្រធានសហករណ៍ភូមិបែកខ្សាច់លើ តែបើនិយាយពីសិទ្ធិអំណាចក្នុងសម័យកាលនោះ គឺស្មើរតែអាចសម្លាប់មនុស្សបាន ។ នៅល្ងាចនេះ ខ្ញុំបានទៅជួបមនុស្ស៧នាក់ ដែលខ្ញុំមិនធ្លាប់ស្គាល់សោះ ។ យប់បន្តិចទៅហើយ នៅវត្តពញាព្រហ្ម គាត់ទាំងអស់គឺជាសហការីរបស់ខ្ញុំ អង្គការឲ្យបន្តទៅសម្រាកនៅភូមិរំដេងឆ្ងាយពីវត្តបន្តិច ។

ការងារនៅទីនោះ គឺអង្គការចាត់តាំងឲ្យដឹកសំណាបស្រូវប្រាំងពីវត្តទៅដាក់នៅទំនប់ស្រែប្រាំងរនាម ក្នុងចម្ងាយផ្លូវប្រមាណ ១០គីឡូម៉ែត ទៅខាងលិចកែងនរាទៀត ។ ក្នុងមួយថ្ងៃ រទេះមួយដឹកពីរជើងដូច្នេះ គោដើរក្នុងមួយថ្ងៃមិនតិចជាង៤០គីឡូម៉ែត្រទេ ។ គោខ្ញុំឈ្មោះ អាខៀវ និងមួយទៀត ឈ្មោះ អាក្រាញ់ ពេលដោះចេញពីនឹមនៅពេលណា គឺលុតជង្គង់នៅពេលនោះដែរ ។ ចំណែកមនុស្សក៏មិនទំនេរដែរ ពេលទៅដល់ត្រូវចុះលុយទឹកអូសសំណាបទៀត នៅទីនោះតែងឃើញខ្មែរក្រហម (គ្មានកាំភ្លើង) ៥-៦នាក់ ដែលធ្វើឲ្យក្រុមខ្ញុំខ្លះវាយតម្លៃថា "ប្រហែលជាកន្លែងកសាងខ្លួនទេដឹង ព្រោះមុននេះវត្តពញាព្រហ្ម គឺជាមន្ទីរឃុំឃាំងមនុស្សដែលមានមិត្តនារីឈ្មោះ វង ជាប្រធានសន្តិសុខ" ។ នឹកទៅដល់នេះភ្លាម ខ្ញុំនឹកភ្នកដល់ចំណាត់ការរបស់ពូ យូ ម៉េងគួន ថាមិនគួរណាគាត់កាត់ទោសខ្ញុំដល់កម្រិតនេះសោះ តើជីវិត និងកិត្តិយសគាត់មួយណាមានតម្លៃជាង? កំពុងតែនឹកស្រមៃគិតពីរឿងនេះស្រាប់តែអ៊ីប្រុសម្នាក់ដែលខ្ញុំទើបនឹងស្គាល់គាត់នោះ បានកេះដៃខ្ញុំ ចំណែកគាត់បានសំឡឹងមើលខ្មែរក្រហមឈរនៅឯនាយ ដោយនិយាយប្រាប់ថា មិត្តអស់នេះថ្ងៃណាមួយគង់តែហុយដីមិនខាន ។ ដល់ពេលនេះ យើងសំលៀងខ្ញុំទុកសម្រាប់ដេញកាប់ ហើយកុំកាប់ត្រង់ណាឲ្យខុសពីសសៃកែងជើងឲ្យសោះ ។

ពេលកងទ័ពវៀតណាមចូលមកដល់ ខ្ញុំបាននឹកឃើញពីរឿងនេះ ។ ទង្វើរបស់លោកពូ យូ ម៉េងគួន ខ្ញុំមិនដែលប្រាប់អ្នកណាទេ ហើយក៏ខ្ញុំមិនខឹងនឹងគាត់ដែរ ។ ខ្ញុំនៅតែគោរពគាត់ដល់សព្វថ្ងៃ គឺគ្រាន់តែតូចចិត្តនឹងវាសនារបស់ខ្លួនតែប៉ុណ្ណោះ ។ យើងនៅទីនោះបាន១០ថ្ងៃប៉ុណ្ណោះ អង្គការរំសាយឲ្យទៅសហករណ៍រៀងៗខ្លួនវិញ ។ ប្រមាណជាមួយខែប៉ុណ្ណោះ កងទ័ពវៀតណាមបានចូលដល់ ។

ក្រោយពេលកងទ័ពវៀតណាមចូលបានបន្តិច ប្អូនស្រីខ្ញុំឈ្មោះ សៀវ សុវុតថា បានបររទេះគោពីភូមិថ្នល់តាសិត ឃុំគោកធ្លកក្រោម មកទទួលខ្ញុំ ប្រពន្ធ និងកូនស្រីច្បងរបស់ខ្ញុំដែលអាយុទើបបានមួយខែ ចាកចេញពីភូមិបែកខ្សាច់លើ ចាប់ពីពេលនោះរៀងរហូតមក ។ **សៀវ សុផុន**

# ដំណឹងស្វែងរកបងប្អូន

ខ្ញុំបាទឈ្មោះ ញ៉ាន ស៊ី ស្នាក់នៅផ្ទះលេខ៤៧៦G សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រកាសស្វែងរកឈ្មោះ អៀវ ទៀងហាវ ភេទប្រុស កើតឆ្នាំ១៩៤៨ នៅភូមិក្រពាំងក្រឡឹង ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ពីមុន ទៀងហាវ ជាសាស្ត្រាចារ្យរូបវិទ្យា-គីមី នៅវិទ្យាល័យអង្គរ ទីរួមខេត្តសៀមរាប ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ទៀងហាវ និងភរិយាឈ្មោះ គួច សាយទៀង ត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិកន្ទួត ឃុំណាំតៅ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ។

នៅខែធ្នូ ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលបញ្ញវន្តនៅតាមភូមិឃុំ ក្នុងស្រុកភ្នំស្រុក ហើយបានបញ្ជូន ទៀងហាវ និងភរិយាទៅនៅភូមិប្រាសាទ ឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ ទៀងហាវ និងភរិយាបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ។

ប្រសិនបើបងប្អូនណាបានឮឬស្គាល់ឈ្មោះដូចខាងលើសូមផ្ដល់ដំណឹងមកខ្ញុំបាទតាមរយៈអាសយដ្ឋានក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ទូរស័ព្ទលេខ ០១២ ៩៥៨ ៥៤៦ ឬ អ៊ីមែល : nhansy04@yahoo.com ។ ***សូមអរគុណ!***

# រឿងដែលខ្ញុំចាំមិនភ្លេច

ខ្ញុំបាទឈ្មោះ ឈុន ឡៃហេង កើតនៅឆ្នាំ១៩៤៥ ក្នុងភូមិព្រែកតាអរ៉ាំ ឃុំបុសលាវ ស្រុកក្រចេះ ខេត្តក្រចេះ ។ ខ្ញុំជាកូនកសិករថ្នាក់ក្រោមម្នាក់ ។

ខ្ញុំបានសិក្សានៅសាលាវិទ្យាល័យព្រះកុសមៈ ខេត្តក្រចេះ ។ ក្រោយពេលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិហើយ ខ្ញុំបានមកស្នាក់នៅផ្ទះឪពុកមា នៅក្រុងភ្នំពេញ ដើម្បីឆ្លៀតឱកាសរកការងារធ្វើ ។ នៅឆ្នាំ១៩៦៥ ខ្ញុំបានប្រឡងជាប់ចូលជានាយទាហានយន្តការីរងអាកាសចរណ៍ ។ ឆ្នាំនោះ ខ្ញុំត្រូវបានឲ្យចូលហ្វឹកហាត់ផ្នែកយោធារយៈពេល៦ខែ ។ នៅពេលហាត់ចប់ អង្គភាពបានបញ្ជូនខ្ញុំឲ្យចូលរៀនផ្នែកចំណេះទូទៅប្រមាណ៣ខែ ។ ខ្ញុំត្រូវបានទទួលឲ្យចូលហ្វឹកហាត់ការងារផ្ទាល់ខាងផ្នែកអគ្គិសនី និងបរិក្ខារយន្តហោះអស់រយៈពេល៦ខែទៀត ហើយក៏ប្រឡងចេញទទួលបានប្រកាសនីយបត្របច្ចេកទេសជាដំបូង “BE” ហើយទទួលឋានន្តរស័ក្តិជាពលបាលត្រី នៅឆ្នាំ១៩៦៦ ។ នៅឆ្នាំ១៩៦៨ ខ្ញុំបានឡើងឋានន្តរស័ក្តិជាពលបាលឯក ។ ឆ្នាំ១៩៧០ ខ្ញុំក៏បានឡើងឋានន្តរស័ក្តិជាព្រិន្ទបាលទោទៀត ។ ក្រោយពេលរដ្ឋប្រហារឆ្នាំ១៩៧០ គឺនៅឆ្នាំ១៩៧១ ខ្ញុំបានឡើងឋានន្តរស័ក្តិជាព្រិន្ទបាលឯក ។ នៅឆ្នាំដដែល អង្គភាពបានបញ្ជូនខ្ញុំឲ្យទៅសិក្សាចំណេះទូទៅ និងទទួលបានប្រកាសនីយបត្រជាន់ខ្ពស់ “BST” ។ ឆ្នាំ១៩៧២-៧៣ ខ្ញុំក៏ឡើងឋានន្តរស័ក្តិជាអនុសេនីយ៍ឯក ។ ខ្ញុំបានទៅហ្វឹកហាត់ជួសជុសយន្តហោះផ្នែកអគ្គិសនីនៅប្រទេសថៃជាច្រើនដង ដើម្បីបំប៉នចំណេះដឹងបន្ថែម និងជួសជុលយន្តហោះថ្មីឈ្មោះ C១២៣ ។ នៅឆ្នាំ១៩៧៣ និង៧៤ អង្គភាពបានដំឡើងឋានន្តរស័ក្តិខ្ញុំ ជាអនុសេនីយ៍ទោ ។ ឆ្នាំ១៩៧៥ ខ្មែរក្រហមក៏បានវាយរំដោះទីក្រុងភ្នំពេញ និងប្រទេសបានទាំងស្រុង ។

ថ្ងៃនោះ ខ្ញុំស្ថិតនៅក្នុងបន្ទាយ ឯប្រពន្ធកូនស្ថិតនៅឯផ្ទះនៅអូរបែកក្អម ។ ខ្ញុំបារម្ភខ្លាំងណាស់ក៏សួរនាំគ្នាលួចឡើងលើរបងផ្ទះដោយទុកចោលទោចក្រយាន និងសម្ភារការងារទាំងអស់នៅក្នុងបន្ទាយ ។ មកដល់ផ្ទះជួបជុំប្រពន្ធកូនរួច ក៏នាំគ្នាមកផ្ទះបងប្រុសប្រពន្ធរបស់ខ្ញុំវិញ ។ នៅពេលល្ងាច កងទ័ពខ្មែរក្រហមបានចូលមកក្នុងទីក្រុងភ្នំពេញហើយ ។ បាត់ពន្លឺថ្ងៃទៅហើយ យោធាខ្មែរក្រហមឈរយាមគ្រប់ច្រកល្ហក ។ ខ្ញុំ និងប្អូនប្រុសរបស់ខ្ញុំបាននាំគ្នាដើរសំដៅទៅរកប្រពន្ធខ្ញុំ កាត់មុខយោធាទាំងនោះ ។ យោធាខ្មែរក្រហមសួរខ្ញុំថា «ទៅណា?» ។ ខ្ញុំឆ្លើយថា «ទៅផ្ទះខ្ញុំ» ហើយក៏អនុញ្ញាតឲ្យយើងទាំងពីរទៅ ។ ខ្ញុំបានទៅដល់មួយសន្ទុះ ក៏មានយោធាខ្មែរក្រហមមកគោះទ្វារប្រាប់ថា ត្រូវនាំគ្នាចាកចេញពីផ្ទះចម្ងាយមួយគីឡូម៉ែត្រសិន ព្រោះខ្លាចយន្តហោះអាមេរិកាំងទម្លាក់គ្រាប់បែក ។ យើងទាំងអស់គ្នា បានរៀបចំសម្លៀកបំពាក់បន្តិចបន្តួចដែលមានជាប់នឹងខ្លួន និងម្ហូបអាហារខ្លះៗដាក់លើរថយន្តម៉ាក Jeep ធ្វើដំណើរសំដៅទៅទិសខាងលិចក្រុងទាំងយប់ ។ ទៅដល់វត្តមួយហៅថាវត្តស្ទឹងមានជ័យ ក៏ចូលសម្រាកសិន ។ ទីធ្លាវត្តមានមនុស្សម្នាច្រើនសន្ធឹកសន្ធាប់ មានទាំងសាកសពដែលគេបោះចោលនៅកណ្តាលវាលផង ។ ព្រឹកឡើងយើងស្មានថា អង្គការអនុញ្ញាតឲ្យវិលត្រឡប់មកផ្ទះវិញ ប៉ុន្តែការពិតគឺគ្មានសោះចំពោះការត្រឡប់ទៅផ្ទះវិញ ។ ពេលនោះ ខ្ញុំឆ្លៀតឱកាសដើរកាត់សំដៅទៅមើលផ្ទះរបស់ខ្ញុំដែលស្ថិតនៅអូរបែកក្អមទាំងភ័យខ្លាច ។ ទៅដល់ផ្ទះ ខ្ញុំដើរទៅបើកទ្រុងមាន់ឲ្យវារកចំណី ។ ខ្ញុំឡើងលើផ្ទះបើកសោមើលឥវ៉ាន់ឃើញនៅដដែល ប៉ុន្តែ ជុំវិញផ្ទះមិនមានឃើញមនុស្សណាម្នាក់ឡើយ គឺស្ងាត់ជ្រងំ ។ ខ្ញុំចាក់សោផ្ទះរួចហើយ ដើរចុះសំដៅមកកាន់វត្តដែលប្រពន្ធខ្ញុំ និងបងខ្ញុំកំពុងរង់ចាំ នៅតាមផ្លូវលំហាក់ដូចជាគ្មានព្រឹត្តិការណ៍អ្វីឲ្យប្លែកទេ គឺឃើញ និងឮសូរសំឡេងរថយន្តយោធាបើកទៅបើកមក ជាមួយនឹងសំឡេងហ៊ោកញ្ជ្រៀវរបស់កងទ័ព និងមនុស្សទាំងនោះ សុទ្ធតែស្លៀកពាក់ពណ៌ខ្មៅដូចសត្វក្អែក ប្រដាប់ដោយអាវុធអាកា៤៧ ជួតក្បាល ឬបង់កក្រមា ។

ខ្ញុំបានមកដល់វត្តជួបប្រពន្ធ និងកូនវិញ ។ នៅរសៀលថ្ងៃនោះ យោធាខ្មែរក្រហម មកបណ្តេញយើងឲ្យធ្វើដំណើរទៅមុខទៀត ដោយនិយាយប្រាប់យើងថា «អង្គការឲ្យទៅមុខទៀត» ។ យើងរុញកូនឡានដែលមានផ្ទុកឥវ៉ាន់បន្តិចបន្តួច ដើម្បីសន្សំសំចៃសាំង ។

នៅត្រង់ផ្លូវលំបាក ខ្ញុំឃើញប្រជាជនជាច្រើន ខ្លះរែក ទូលឥវ៉ាន់ទៅជាមួយគ្នា ចេះតែធ្វើដំណើរទៅមុខរហូតមិនដឹងទៅទីណាច្បាស់លាស់នោះទេ ។ ទន្ទឹមនឹងនោះ ក្រុមអាវខ្មៅបានបណ្ដើរមនុស្សរាប់ខ្សែ ដែលសុទ្ធតែស្លៀកខោខ្លីៗ ដោយរត់ត្រីកៗពីក្រោយ ហើយខ្ញុំឮអ្នកភៀសខ្លួននិយាយថា អ្នកទាំងនោះសុទ្ធតែជាទាហាន លន់ នល់ ដែលត្រូវយកទៅរៀនសូត្រ ។ ពាក្យរៀនសូត្រតាមខ្ញុំដឹង គឺការសិក្សាយកចំណេះដឹង ខ្ញុំក៏មិនបានចាប់ភ្ញាក់អ្វីប្លែកឡើយ ។ យើងធ្វើដំណើរទៅមុខយ៉ាងលំបាក ។ ខ្ញុំមានកូនម្នាក់ទើបមានអាយុប្រហែល៣ខែ ដែលប្រពន្ធខ្ញុំត្រូវបីនៅនឹងដៃជាប់រហូត ។ ឯកូនបងបន្ទាប់អាយុ៣ឆ្នាំនៅបៀមក្បាលដោះកៅស៊ូនៅឡើយ ។ កូនស្រីនេះខ្ញុំពរដៃម្ខាង ហើយដៃម្ខាងទៀតដឹកដៃកូនច្បងដែលមានអាយុ៦ឆ្នាំ និងកូនស្រីច្បងបង្អស់អាយុ១១ឆ្នាំ ដោយដើរតាមពីក្រោយឡានរហូត ។

ដោយការធ្វើដំណើរផ្លូវឆ្ងាយ កូនតូចៗរបស់ខ្ញុំហត់ហើយចុកជើង ក៏យំទារឈប់សម្រាក និងញ៉ាំបាយ ។ ខ្ញុំចាប់ផ្ដើមហូរទឹកភ្នែក ហើយនិយាយលួងកូនៗថា "ទ្រាំទៅជិតដល់ហើយកូន" ។ ពេលនោះ យើងហូរទឹកភ្នែករហាមរៀងៗខ្លួន ។ យប់មកដល់ការធ្វើដំណើរនៅម៉ោងប្រមាណ៧ជាងទៅហើយ ក៏នាំគ្នាទៅឈប់សម្រាកនៅក្បែរអូរមួយ ដោយងងឹតមើលអ្វីមិនយល់មិនឃើញទាល់តែសោះ ។ យើងឥតមានភ្លើងបំភ្លឺទេ នាំគ្នាដងទឹកអូររៀបចំដាំបាយហូប ដោយអស់កម្លាំងខ្លាំងពេក ហូបបាយរួចហើយ ក៏ដេកលក់ជាមួយកូនតូចៗទៅ ។ លុះពេលព្រឹកឡើង អ្វីដែលនឹកស្មានមិនដល់នោះ គឺខ្ញុំឃើញទឹកដែលយកមកប្រើកាលពីយប់នោះ គឺល្អក់មើលមិនបាន និងគួរឲ្យខ្លាច ព្រោះមានឈាម និងសាកសពអណ្ដែតពេញផ្ទៃទឹក ទោះបីចង់ក្អួតក៏ក្អួតលែងចេញ ។ ខ្ញុំមិនស្គាល់ថាជាកន្លែងណាទេ ហើយក៏នាំគ្នាចេញដំណើរទៅទៀត ។ ដើរអស់ជើងអស់ដៃរៀងៗខ្លួន ទើបមកដល់លើផ្លូវលំថ្មីមួយទៀត ។ ការធ្វើដំណើរកាត់តាមផ្លូវលំ ផ្លូវធំ ឆ្លងបឹង ឆ្លងស្ទឹង ឆ្លងអូរ កាត់វាល កាត់ព្រៃ កាត់ភូមិមួយទៅភូមិមួយទៀត ឲ្យតែមានផ្លូវចេះតែដើរទៅមុខ ហាក់បីដូចមនុស្សវង្វេងមិនចេះចប់ ។ ពេលធ្វើដំណើរចូលដល់ព្រៃ ខ្មែរក្រហមបានដកហូតយកឡានរបស់យើង ។ ពេលនោះហើយ ដែលវេទនាទាំងអស់គ្នា ព្រោះត្រូវចែកឥវ៉ាន់គ្នាទូល រែក ហើយពរកូន និងដឹកដៃកូនតូចៗធ្វើដំណើរទៅទាំងត្រដាបត្រដួសលាយឡំទាំងទឹកភ្នែកទាំងអស់គ្នា គ្មានអ្នកណាជួយអ្នកណាបានឡើយ ។ អស់រយៈពេលជាច្រើនថ្ងៃ ដែលខ្ញុំចាំមិនបាន ក៏មកដល់ផ្លូវថ្នល់មួយដែលក្រាលដោយកៅស៊ូហៅថា ថ្នល់ជាតិ អ្នកដំណើរទាំងអស់បានឈប់សម្រាកនៅតាមចិញ្ចើមថ្នល់មួយយប់ទៀត ។ ស្អែកឡើងធ្វើដំណើរទៅដល់ភូមិចាស់មួយ មានមនុស្សកុះករ យប់មកដល់សម្រាកនៅទីនោះទៀត ។ កូនប្រុសពៅរបស់ខ្ញុំមានជំងឺរាករូសស្ទើរបាត់ជីវិត ។ ខ្ញុំ និងប្រពន្ធខ្ញុំមិនបានដេកសោះ ក៏ដាច់ចិត្តទៅសុំថ្នាំគេយកមកឲ្យកូន ទើបយើងបានសម្រាកបន្តិច ។ ពេលសម្រាកនៅទីនោះ ខ្ញុំបានឮពាក្យអ្នកជិតខាងនិយាយថា អង្គការត្រូវការអ្នករាជការចាស់យកទៅធ្វើការងារវិញ អ្នកណាធ្វើការងារអី អង្គការឲ្យធ្វើការដដែលវិញ ។ អ្នកណាពាក់ស័ក្ដិប៉ុន្មាន អង្គការឲ្យពាក់ស័ក្ដិដូចដើម ។ អង្គការនឹងឲ្យធ្វើការកន្លែងរៀងៗខ្លួនវិញ ។ នៅពេលនោះ ខ្ញុំពិចារណាឃើញថាសភាពការណ៍មិនស្រួលឡើយ ព្រោះបើដូចពាក្យដែលអង្គការថាមែន ហេតុអ្វីបានជាត្រូវដេញប្រជាជនចេញពីទីក្រុងទាំងអស់ ។ ហេតុតែអាយុរបស់ខ្ញុំថ្លៃ ខ្ញុំគ្មាននឹកនាដល់រឿងដែលខ្មែរក្រហមបានប្រកាសឡើយ ។ ប៉ុន្តែ មានមនុស្សមួយចំនួនលោភលន់ អំណាចបុណ្យស័ក្តិ ក៏នាំគ្នាទៅចុះឈ្មោះតាមការប្រកាស ។ ក្រោយមក អ្នកដែលបានចុះឈ្មោះទាំងប៉ុន្មាន ត្រូវអង្គការយកទៅសម្លាប់ទាំងអស់ ។ ចំណែកខ្ញុំនឹកព្រួយ និងអាណិតកូនតែប៉ុណ្ណោះ លែងគិតពីអ្វីទៀតហើយ ។ យើងនាំគ្នាធ្វើដំណើរជារៀងរាល់ថ្ងៃយប់ ដល់ត្រង់ណាសម្រាកត្រង់នោះ ។ មានថ្ងៃខ្លះយើងដាំបាយ និងផឹកទឹកថ្កុកក្របីដេកក៏មាន ដែលទឹកនោះមើលទៅគួរឲ្យខ្ពើម ប៉ុន្តែដោយការស្រេកឃ្លាន គឺយើងទ្រាំដើម្បីរស់ ។ ថ្ងៃមួយ ខ្មែរក្រហមបានហៅអ្នកដំណើរមួយចំនួន រួមទាំងគ្រួសារខ្ញុំដែរ ឡើងជិះកាណូតពីដីឥដ្ឋឆ្ពោះទៅកាន់ព្រែកពោធិ៍ ហើយសម្រាកនៅទីនោះមួយយប់ ។ ពេលទៅដល់ដំបូង ខ្មែរក្រហមបាននាំបងថ្លៃប្រុសរបស់ខ្ញុំទៅ ដោយប្រាប់យើងថា "យកទៅរៀនសូត្រ" ។ ខ្មែរក្រហមបានប្រាប់ទៀតថា អង្គការបានតាមដានយើងតាំងពីភ្នំពេញមកម្ល៉េះ ។ បងថ្លៃខ្ញុំជាទាហានពាក់ស័ក្ដិ៥ ទ័ពជើងគោក នៅកំពង់ស្ពឺ ។ លុះព្រឹកឡើង មិនឃើញបងថ្លៃខ្ញុំមកសោះ ក្នុងចំណោមយើងបាត់តែគាត់ម្នាក់ទេ ។ បន្ទាប់មកទៀត ខ្មែរក្រហមបានបញ្ជូនយើងឲ្យឡើងជិះកាណូតឆ្ពោះទៅកាន់ទន្លេបិទ ។ ពេលនោះ ខ្ញុំសង្ស័យ និងភ័យខ្លាច ដោយអស់សង្ឃឹម

ជាខ្លាំងចំពោះរឿងបងថ្លៃខ្ញុំ ។ ពេលមកដល់ទន្លេបិទ ស្នាក់នៅមួយយប់ទៀត ហើយព្រឹកឡើង ទើបអង្គការយករទេះសេះមកដឹកយើងទៅកាន់ស្លួង ចូលក្នុងចម្ការកៅស៊ូ ឆ្ពោះទៅកាន់ភូមិចាមមួយឈ្មោះថា ភូមិថ្មី ក្នុងភូមិរកាប្រាំ ដែលមានខ្ទមតូចៗ នៅក្នុងព្រៃបណ្តោះអាសន្ន ។ ក្រោយមក ទើបអង្គការឲ្យចូលមកនៅក្នុងភូមិធំជាភូមិរបស់ចាម ក្នុងភូមិរកាប្រាំ ស្ថិតនៅក្រោមផ្ទះអ្នកមូលដ្ឋាន ។ នៅទីនោះ អង្គការបានចាត់តាំងខ្ញុំទៅឃ្វាលគោក្របីរាប់សិបក្បាលតែម្នាក់ឯង ឯប្រពន្ធ និងប្អូនរបស់ខ្ញុំ ត្រូវចាត់ឲ្យទៅធ្វើការងារផ្សេងពីគ្នា ។ ព្រះអើយ! ក្របីរាប់សិបក្បាលឲ្យខ្ញុំឃ្វាលតែម្នាក់ឯង ហើយភូមិសាស្ត្រមិនធ្លាប់ស្គាល់ផងណាមួយខ្ញុំមិនចំណាំក្របីទៀត ព្រោះសត្វក្របីមិនដូចគោទេ គឺវាខ្មៅទាំងអស់ ។ ដូច្នេះតាំងពីព្រឹក ទល់ល្ងាច ខ្ញុំដើរតាមហ្វូងក្របីជាប់រហូត មិនបានសម្រាកទេ ។ នេះជារឿងមួយ ដែលខ្ញុំមិនធ្លាប់ជួបប្រទះតាំងពីក្មេងមក ។ ពេលមកវិញខ្ញុំរាប់ក្របីយ៉ាងណាឲ្យតែគ្រប់ចំនួន មិនដឹងថាជារបស់អ្នកណាៗខ្លះទេ ។ បានព្រះជួយយើង ភូមិនោះជាភូមិសម្បូរស្រូវ ទោះយ៉ាងណាខ្ញុំបានបាយហូបខ្លះដែរ តែពីព្រឹកទល់ល្ងាចមកវិញហូបបាយឯផ្ទះ ដោយអង្គការចែករបបស្រូវឲ្យមកកិនហូប បើខ្វះត្រូវដោះស្រាយខ្លួនឯង ។ គ្រួសារខ្ញុំត្រូវដាំបាយហូបផង និងដាំបបរហូបផងនៅពេលដែលខ្វះអង្ករ ។ ប្រពន្ធខ្ញុំបានយករបស់របរ ដូចជា សារុងខោ អាវ ទៅដោះដូរយកអង្ករនៅពេលអត់អាហារ ។ ជួនកាល អង្គការឲ្យទៅដកសំណាបមួយថ្ងៃៗទល់ល្ងាច ។ ដោយខ្ញុំមិនធ្លាប់ធ្វើការងារធ្ងន់ ខ្ញុំឈឺអស់ខ្លួនប្រាណ ។ អង្គុយឬដេកមិនចង់កើតទេ ។ នៅពេលល្ងាច ឬយប់ និងថ្ងៃ ពេលកំពុងធ្វើការ មានឈ្លបតាមដានជាប់ជានិច្ច ។ ក្រោយពីការងាររចប់ម្នាក់ៗដេកឈឺខ្លួនប្រាណ បាយមិនបានស្រួល ដេកមិនបានស្រួល ខ្ញុំមានជំងឺគ្រុនចាញ់ តែគ្មានថ្នាំព្យាបាលទេ ។ ខ្ញុំដើរសួរអ្នកភូមិពីវិធីព្យាបាល អ្នកភូមិឲ្យបេះស្លឹកឈើ បុសឈើយកមកស្ងោរផឹក ។ ទោះបីជាខ្ញុំមានជំងឺ ក៏ត្រូវធ្វើការងារទាំងឈឺដែរ ព្រោះខ្លាចអង្គការយកទៅសម្លាប់ ។ ពេលដេក ពេលដើរ គ្មានស្រដីអ្វីទាំងអស់ ។ ជួនកាលខ្ញុំនឹកដល់ម្តាយ និងបងប្អូននៅឯស្រុក មិនដឹងជាបានសុខទុក្ខយ៉ាងណា ហើយគិតទៅមុខទៀត មិនដឹងវាសនាយើងទាំងអស់គ្នាទៅជាយ៉ាងណាទេ ។ ខ្ញុំបន់ស្រន់ដល់ព្រះជាម្ចាស់ដល់អ្នកដ៏មានគុណទាំងឡាយ សូមជួយថែរក្សាក្រុមគ្រួសារខ្ញុំឲ្យបានសុខ គ្រប់ពេលវេលា ។ ពេលធ្វើការ ពេលឃ្វាលក្របី ទោះបីឃ្លានយ៉ាងណា ក៏ទ្រាំអត់សង្កត់ចិត្ត មិនស្រដី មានតែផឹកទឹកឲ្យតឹងពោះជំនួសបាយ ។ អង្គការបានធ្វើប្រវត្តិរូបជាញឹកញាប់ ដើម្បីបញ្ជាក់អំពីអតីតការងាររបស់យើង ។ រាល់ពេលដែលអង្គការសួរ ប្រពន្ធខ្ញុំ និងខ្ញុំបានកុហកថា ខ្ញុំជាកម្មករស៊ីឈ្នួលគេ ប្រពន្ធខ្ញុំនៅផ្ទះមើលកូននៅឯក្រុងភ្នំពេញ ដោយឡែកតែប្រវត្តិរូបរបស់បងប្អូន ម៉ែឪរបស់ខ្ញុំទេ ដែលខ្ញុំប្រាប់ពិត ។ នៅទីនោះការហៅប្រជាជនជម្លៀសឲ្យទៅរៀនសូត្រកើតមានសឹងរាល់ថ្ងៃ ទៅបាត់ៗ មិនឃើញត្រឡប់មកវិញឡើយ គួរឲ្យឆ្ងល់ និងខ្លាចថែមទៀត ។

អង្គការបានជម្លៀសប្រជាជនពីភូមិ ទៅកាន់ទីផ្សេងទៀត តែគ្រួសារខ្ញុំគ្មានឈ្មោះទៅនឹងគេទេ ។ ខ្ញុំឆ្ងល់ និងខ្លាចណាស់ ម្យ៉ាងទៀត ខ្លាចអង្គការដឹងរឿងពិត ខ្ញុំក៏ស្នើអង្គការទៅដែរ អង្គការក៏យល់ព្រម ។ ការធ្វើដំណើរដោយរទេះក្របីតាំងពីព្រឹកទល់ល្ងាចទើបមកដល់ទន្លេបិទ ។ អង្គការឲ្យជិះកាណូត មកកាន់កំពង់ចាមទាំងយប់អធ្រាត្រគ្មានទាំងបាយហូបផង ។ ឡានមួយចំនួនបានមកដឹកយើងទាំងយប់ ដើម្បីបន្តដំណើរ ។ នៅលើឡានមួយៗ គឺចង្អៀតណែនគ្មានកន្លែងអង្គុយទេ ត្រូវឈរទាំងអស់គ្នាពេញមួយយប់ ។ លុះជិតភ្លឺ ទើបយើងទៅដល់កំពង់ថ្ម ហើយសំដៅចូលទៅភូមិមួយឈ្មោះថា ភូមិចើងដើង ស្ថិតនៅក្នុងខេត្តកំពង់ធំ ។ យើងចុះពីឡានអង្គុយរង់ចាំមេឃភ្លឺទាំងអត់ងងុយ ណាមួយអត់បាយតាំងពីម្សិលមិញផង ។ ពេលព្រះអាទិត្យរះឡើង ទើបមេក្រុមមកបែងចែកប្រជាជនយកទៅកន្លែងរៀងៗខ្លួន ។ គ្រួសារខ្ញុំ អង្គការចែកកូនខ្ទមតូចមួយឲ្យស្នាក់នៅ តែពុំទាន់សាងសង់រួចនៅឡើយ ។ អង្គការឲ្យយើងចូលព្រៃកាប់កូនឈើដើម្បីធ្វើរនាប ។ ចាប់ផ្តើមសង់បានកូនខ្ទមដ៏កម្សត់មួយដែលឥតមានជំបូល និងជញ្ជាំងមានតែរនាបកូនឈើរដិបរដុប ។ ប្រពន្ធខ្ញុំឆ្លៀតដើររកប្រូតស្រូវយកមកគាបចងជាដំបូលព្រមទាំងបាំងជញ្ជាំងយ៉ាងស្តើង ។ យើងទាំងអស់គ្នារស់នៅក្នុងខ្ទមយ៉ាងលំបាកវេទនា ។ នៅក្នុងភូមិនោះ អ្នកស្រុកដែលមានដើមកំណើតនៅក្នុងភូមិហៅថា ប្រជាជនចាស់ ។ អ្នកជម្លៀសគេហៅថាប្រជាជនថ្មី ឬពួក១៧មេសា ។ អង្គការប្រើឲ្យយើងធ្វើពលកម្មសង្គមរួមទាំងយប់ទាំងថ្ងៃគ្មានពេលទំនេរទេ ។ ប្អូនប្រុសរបស់ខ្ញុំអង្គការចាត់ឲ្យចូលកងចល័ត រីឯកូនស្រីច្បងរបស់ខ្ញុំ ដែលមាន

អាយុទើបតែ១១ឆ្នាំ ក៏ត្រូវបង្ខំឲ្យចូលកងចល័តនារីដែរ ។ អង្គការប្រើក្មេងៗតាមអំពើចិត្តរបស់គេ ។ ចំណែកប្រពន្ធខ្ញុំ ក៏ត្រូវបែកគ្នាដែរ ឯខ្ញុំអង្គការចាត់ឲ្យទៅឆ្ងាយ ។ យើងខ្ញុំបែកគ្នាអស់ហើយ ។ អង្គការប្រើឲ្យដកស្ទូងភ្ជួររាស់ ឲ្យឃ្វាលគោឲ្យក្រុមសាមគ្គី ។ ប្រជាជនទាំងនោះលួចតាមដានប្រជាជនថ្មីរាល់ថ្ងៃ ។ ចំពោះជនណាអង្គការសង្ស័យ គឺត្រូវយកទៅសម្លាប់ចោលបណ្តើរៗ ។ នៅទីនោះ អង្គការចាប់ផ្តើមធ្វើប្រវត្តិរូបថ្មីទៀត ។ គ្រួសារខ្ញុំ ក៏ផ្លាស់ប្រវត្តិរូបថ្មីដែរ ដោយដាក់ថា កើតនៅភ្នំពេញ ម៉ែឪស្លាប់អស់ហើយ ឥតមានបងប្អូនទេ ។ រីឯកូនតូចៗដែលដឹងរឿង ខ្ញុំបានហាមដាច់ខាតឲ្យឆ្លើយថា មិនដឹង នៅពេលមាននរណាម្នាក់មកសួរអំពីគ្រួសាររបស់យើង ។ ការហូបចុកវិញ គឺមហាលំបាក ។ ចំពោះអ្នកជម្លៀស គឺហូបមិនបានឆ្អែតទេ ។ ពេលថ្ងៃ អង្គការឲ្យធ្វើពលកម្មធម្មតាសម្រាប់កសិករ ។ នៅពេលយប់ អង្គការដាក់ទិសឲ្យជីកស្រះ រែកដី គ្មានពេលសម្រាកទេ ។ នៅពេលឈប់សម្រាក យើងគ្មានសិទ្ធិនៅអង្គុយជុំគ្នាបានទេ និយាយរកគ្នាក៏មិនបានដែរ ។ បើស្រី និង ប្រុស និយាយគ្នាត្រូវមានទោស ដោយចោទថា ខុសសីលធម៌ ។

នៅឆ្នាំ១៩៧៧-៧៨ ជាឆ្នាំមហាវិនាសកម្ម ។ អង្គការបានបញ្ជូនប្រជាជនជម្លៀស ឬហៅថា អ្នក១៧មេសា ទាំងរទេះៗយកទៅសម្លាប់ចោលដោយគ្មានធម៌មេត្តាឡើយ ។ ពេលហៅប្រជាជនទៅប្រជុំក្នុងភូមិ មេភូមិបានប្រកាសថា អង្គការខ្វះស្បៀង ដូច្នេះត្រូវបញ្ជូនប្រជាជនថ្មីឲ្យទៅស្រុកកំណើតដើមវិញខ្លះ និងបន្ថយរបបបាយ ដើម្បីសន្សំសំចៃស្បៀងអាហារ ។ ម្នាក់ៗសប្បាយត្រេកអរដោយបានឮថា អង្គការពិតជាឲ្យទៅស្រុកកំណើតវិញ ។ ចាប់តាំងពីពេលនោះមក អង្គការបានដឹកមនុស្សចេញពីភូមិស្ទើររាល់ថ្ងៃរាល់យប់ ។ អ្នកដែលអង្គការយកទៅ ម្នាក់ៗទៅទាំងទឹកមុខញញឹមរីករាយ ដោយមិនបានដឹងថា ជាការបញ្ឆោតយកទៅសម្លាប់ចោលឡើយ ។ ចំណែកគ្រួសារ ខ្ញុំជារៀងរាល់ថ្ងៃត្រូវទៅធ្វើការបែកគ្នា ។ នៅមុនពេលចេញពីផ្ទះ ខ្ញុំតែងប្រាប់កូនជានិច្ចថា បើមានអ្នកណាសួរថា ឪពុកម្តាយធ្វើការអីនៅភ្នំពេញ ត្រូវឆ្លើយថា ពុកជាកម្មករធាក់ស៊ីក្លូ ម៉ែនៅផ្ទះ ។ ជារៀងរាល់យប់ អង្គការតែងតែយកប្រជាជនថ្មីទៅដោយស្ងាត់ៗ សូម្បីតែផ្ទះនៅជិតគ្នា ក៏ខ្ញុំមិនដឹងដែរ ។ ដល់ពេលព្រឹកឡើង ខ្ញុំឃើញផ្ទះនោះ មានសភាពស្ងប់ស្ងាត់គ្មានមនុស្សនៅ ។ ខ្ញុំសួរអ្នកនៅជិតខាងថា តើអ្នកផ្ទះទៅណាអស់? អ្នកជិតខាងឆ្លើយថា អង្គការយកទៅស្រុកយប់មិញអស់ហើយ ។ រាល់ថ្ងៃខ្ញុំគិតតែខំធ្វើការតាមបញ្ជាអង្គការ មិនហ៊ាននិយាយស្តីអ្វីទេ ។ នៅពេលយប់ ដេកព្រួយដោយភ័យខ្លាច មិនដឹងជាយប់ណាដល់វេនគ្រួសារខ្ញុំនោះទេ ។ បើមួយថ្ងៃផុតទៅគឺដឹងរស់បានមួយថ្ងៃ ហើយតែងតែគិតថា តើយប់នេះ ឬថ្ងៃស្អែកបានរស់ដូចថ្ងៃនេះទេ? អង្គការបានឲ្យយើងស្លៀកសម្លៀកបំពាក់ខ្មៅ ដែលអង្គការចែកឲ្យម្នាក់មួយសម្រាប់ និងស្បែកជើងកង់ឡាន ។ អ្នកខ្លះបាន អ្នកខ្លះអត់បាន ត្រូវដើរទាំងជើងទទេ ។ ពេលធ្វើការ ពេលដើរ ពេលដេក មានតែខោអាវមួយកំប្លេ ឆ្អេះ ស្អុយ ញើសជាប់ខ្លួន គ្មានអ្វីផ្លាស់ប្តូរទេ ទម្រាំអង្គការចែកឲ្យម្តងទៀត ទម្រាំតែអាចាស់រហែកដូចត្រីងៀត ទើបអង្គការចែកឲ្យម្តងទៀត ។ ចំណែកការហូបចុកវិញ គឺមានតែបបរលាយដំឡូង ឬក្តួច និងមានតែអង្ករមួយគ្រាប់ៗប៉ុណ្ណោះ ។ យើងទាំងអស់គ្នាវេទនាណាស់ ហូបមិនឆ្អែត ធ្វើការងារទាំងថ្ងៃទាំងយប់គ្មានពេលឈប់សម្រាក ។

នៅពេលមួយ អង្គការបានចាត់តាំងប្រពន្ធខ្ញុំឲ្យដាំបន្លែនៅឆ្ងាយពីភូមិប្រហែល១០គីឡូម៉ែត្រ ចំណែកខ្ញុំ ក៏ត្រូវចាត់តាំងឲ្យលើកទំនប់ឆ្ងាយពីភូមិប្រហែលជាង២០គីឡូម៉ែត្រដែរ ។ ខ្ញុំត្រូវឃ្លាតឆ្ងាយពីប្រពន្ធ និងកូនតូចដែលត្រូវទុកចោលនៅផ្ទះ ។ នៅទីនោះ ខ្ញុំត្រូវអង្គការឲ្យរែកដីចាប់តាំងពីព្រឹកព្រលឹម ទល់ព្រលប់ ហើយឲ្យហូបបបរមួយពេលមួយកូនចានប៉ុណ្ណោះ ។ នៅពេលយប់ដេកផ្ទាល់ដីគ្មានអ្វីក្រាល និងដណ្តប់ទេ ។ ខ្ញុំនឿយហត់ស្ទើរស្លាប់ស្ទើររស់ ដោយធ្វើការគ្មានពេលសម្រាក ណាមួយហូបមិនឆ្អែត ។ ពេលយប់ ដេកមិនលក់ដោយសារមូសខាំ ទៅជាមានជំងឺ ប៉ុន្តែទ្រាំប្រឹងទៅធ្វើការទាំងឈឺ និងលួចបេះត្រួយឈើស៊ីដើម្បីព្យាបាលជំងឺ ។

រាងកាយខ្ញុំស្គម ក្បាលជង្គង់ត្រមោង ។ រាល់ថ្ងៃខ្ញុំត្រូវប្រឹងធ្វើការទាំងត្រដរ ព្រោះខ្លាចអង្គការយកទៅសម្លាប់ ។ ពេលយប់ ខ្ញុំដេកបង្ហូរទឹកភ្នែក ដោយនឹកកូនដែលនៅផ្ទះ មិនដឹងយ៉ាងណា និងព្រួយបារម្ភដល់ប្រពន្ធមិនដឹងសុខទុក្ខយ៉ាងណាដែរ ព្រោះប្រពន្ធខ្ញុំកំពុងមានផ្ទៃពោះ ។

ជាច្រើនខែកន្លងទៅ ទំនប់បានធ្វើជិតរួច ។ គ្រួសារខ្ញុំរស់នៅបែកគ្នានៅឡើយ ។ ខ្ញុំមិនទាន់បានត្រឡប់មកផ្ទះវិញទេ ។ រីឯប្រពន្ធ

របស់ខ្ញុំ អង្គការចាត់តាំងឲ្យរែកទឹកស្រោចបន្លែជារៀងរាល់ថ្ងៃ រហូតដល់ថ្ងៃត្រូវសម្រាលកូន ទើបឲ្យឈប់ធ្វើការ ។ ប្រហែលជាមួយខែក្រោយមក ទំនប់បានធ្វើរួច ហើយអង្គការបានបញ្ជូនខ្ញុំឲ្យមកផ្ទះវិញ ។ ខ្ញុំបានមកជួបប្រពន្ធ និងកូនវិញ ។ នៅពេលយើងជួបគ្នា គ្មានពាក្យនិយាយរកគ្នាទេ មានតែបង្ហូរទឹកភ្នែកដាក់គ្នា ដោយមិនឲ្យនរណាឃើញឡើយ ។

បន្ទាប់មក អង្គការចាត់តាំងខ្ញុំឲ្យឃ្វាលគោ និងដឹកខសដាក់រោងបាយ ចំណែកប្រពន្ធខ្ញុំមានកូនខ្ចី ក៏ត្រូវចាត់តាំងឲ្យក្រងស្បូវដែរ ។ កូនតូចៗរបស់ខ្ញុំ អង្គការឲ្យសែងអាចម៍គោដាក់ស្រែ ។ រីឯប្អូនប្រុស និងកូនស្រីច្បងរបស់ខ្ញុំវិញ គឺបាត់ដំណឹងឈឹង មិនដឹងជាសុខទុក្ខយ៉ាងណាទេ ព្រោះចាប់តាំងពីអ្នកទាំងពីរចេញទៅធ្វើការនៅកងចល័តមក មិនដឹងទៅទីណាឡើយ ។ រាល់ថ្ងៃ ខ្ញុំទៅឃ្វាលនៅក្នុងព្រៃ ខ្ញុំឃើញខ្មែរក្រហមបណ្តើរមនុស្សចូលជារៀងរាល់ថ្ងៃ ។ ការពិតគឺនាំមនុស្សយកទៅសម្លាប់សោះ ។ នៅក្នុងភូមិ ខ្ញុំឮមេក្រុម មេភូមិនិយាយគ្នាថា សាច់អ្នកនេះឆ្ងាញ់ ថ្លើមអ្នកនោះឆ្ងាញ់ ។ ពេលឮពាក្យទាំងនោះគួរឲ្យភ័យខ្លាចណាស់ ។ ខ្មែរក្រហមទាំងអស់នេះពិតជាសាហាវព្រៃផ្សៃណាស់ មិនត្រឹមតែសម្លាប់មនុស្ស ថែមទាំងយកសាច់មកស៊ីថែមទៀត ។ យើងទាំងអស់គ្នា ជាប្រជាជនថ្មី ត្រូវអង្គការប្រើឲ្យធ្វើការដូចជាសត្វពាហនៈ ទាំងយប់ ទាំងថ្ងៃ ។ ខោអាវរហែករយ៉ៃដូចគេច្រៀក រងទុក្ខវេទនា គ្មានថ្ងៃស្បើយឡើយ ។ ចំណែក កម្មាភិបាលខ្មែរក្រហមវិញ មានប្រដាប់ប្រដាប្រើមិនអស់ ស៊ីឆ្ងាញ់ ដេកស្រួល ។ មួយថ្ងៃៗ អង្គុយចាំតែចាប់កំហុសយើង បើដឹងថា មានបុរស ឬនារីណាមានការទាក់ទងគ្នា គឺនាំយកទៅសម្លាប់ចោលភ្លាម ។ ចំណែក កម្មាភិបាលខ្មែរក្រហម បើត្រូវការនារីណាម្នាក់ គឺយកនារីនោះទៅនៅជាមួយលុះដល់មានផ្ទៃពោះ ទើបបញ្ជាឲ្យផ្សំផ្គុំនារីនោះជាមួយបុរសថ្មីទៀត បើមិនព្រមទេ នឹងយកទៅសម្លាប់ចោលដូចឆ្កែ ដូចឆ្មាអ៊ីចឹង ។ ខ្មែរក្រហមបញ្ជូនប្តីគេឲ្យទៅឆ្ងាយរាប់ខែ វាទៅដេកជាមួយប្រពន្ធគេនោះ ដោយនាងខ្លាចស្លាប់ ចេះតែទ្រាំទាំងទឹកភ្នែក ។

នៅឆ្នាំ១៩៧៨-៧៩ កងទ័ពវៀតណាមបានលុកលុយប្រទេសកម្ពុជា ដេញកម្ចាត់ខ្មែរក្រហម ពេលនោះប្រជាជនខ្មែរត្រូវរងគ្រោះបន្ថែមទៀត គឺត្រូវខ្មែរក្រហមសម្លាប់ផង ហើយស្លាប់ដោយសង្គ្រាមថែមទៀត ។

នៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ជាពេលមួយដែលយើងរួចផុតពីការសម្លាប់ ហើយជាពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ និងជារបបមួយដែលធ្វើបាបមនុស្សដូចគ្នា ដូចជា បំបែកបំបាក់មនោសញ្ចេតនាគ្រួសារទាំងមូល និងបង្ខំឲ្យធ្វើពលកម្មជាទម្ងន់ មិនមានអាហារបរិភោគគ្រប់គ្រាន់ កាប់សម្លាប់ និងបរិភោគសាច់មនុស្សដូចគ្នាត្រូវផុតរលត់ទៅ ។ ពេលនោះគ្រួសារខ្ញុំត្រូវដើររកគ្នា ។ ប្អូនប្រុស និងកូនស្រីខ្ញុំបានវិលត្រឡប់មកផ្ទះជួបជុំគ្នាវិញ ។

យើងនាំគ្នាចេញពីខេត្តកំពង់ធំ ត្រឡប់មកខេត្តក្រចេះវិញ ព្រោះទីនោះជាស្រុកកំណើតរបស់ខ្ញុំ ដើម្បីជួបជុំឪពុកម្តាយបងប្អូន ។ ពេលនោះប្រទេសជាតិបានរំដោះជាស្ថាពរ ។ ប្រជាជនខ្មែរបានរួចចាកផុតពីភាពទុក្ខសោកទាំងឡាយ ។ បើនិយាយជារួម គឺប្រជាជនខ្មែរបានចេញពីប្រទេសមួយ ដែលគ្មានច្បាប់ទម្លាប់ ដែលអ្វីៗទាំងអស់ពោរពេញដោយភាពងងឹត អយុត្តិធម៌ និងការឈឺចាប់គ្រប់បែបយ៉ាង ដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនខ្មែរគ្រប់រូប ។

នេះជាប្រវត្តិរឿងរ៉ាវដែលខ្ញុំជួបប្រទះនៅក្នុងជីវិតរបស់ខ្ញុំ ដែលមិនអាចបំភ្លេចបាននៅក្នុងមួយជីវិតនេះ ខ្ញុំក៏សម្រេចចិត្តយកមកសរសេរសេផ្ញើឡើងវិញ ។ ចាប់ពីពេលនេះតទៅមុខទៀត ខ្ញុំសូមអង្វរអ្នកមានឫទ្ធិអំណាច មេត្តាធ្វើយ៉ាងណាកុំឲ្យមានរឿងដ៏អាក្រក់បែបនេះកើតឡើងជាថ្មីម្តងទៀត ដូចកាលនៅក្នុងសម័យនោះ ។ ត្រូវមានចិត្តមេត្តា ករុណា អធ្យាស្រ័យគ្នា សណ្តោសគ្នាទៅវិញទៅមក ចេះស្រឡាញ់ពូជសាសន៍ ការពារគ្នា ការពារបូរណភាពទឹកដីខ្មែរឲ្យគង់វង្សជារៀងរហូត ដូចពាក្យស្លោកពោលថា “សាមគ្គីជាកម្លាំង បែកបាក់នាំមកនូវក្តីអន្តរាយ” ។

ជាទីបញ្ចប់ ខ្ញុំសូមសំណូមពរមួយ គឺសុំឲ្យចងក្រងរឿងរ៉ាវដែលកើតមាននៅជំនាន់ប្រល័យពូជសាសន៍ទាំងអស់ជាឯកសារទុកសម្រាប់កូនចៅខ្មែរបានដឹងរឿងផង ព្រោះក្មេងជំនាន់នេះពេលខ្ញុំនិយាយពីរឿងឈឺចាប់នៅសម័យនោះ អ្នកទាំងនោះមិនជឿទាំងអស់ទេ ឬអាចជឿតែពាក់កណ្តាលទេ ខ្លះជឿបានប្រហែល ៧០ភាគរយប៉ុណ្ណោះ ។ បច្ចុប្បន្ន ខ្ញុំជាគ្រូបង្រៀននៅអនុវិទ្យាល័យហ៊ុន សែន ស្នួល ស្រុកស្នួល ខេត្តក្រចេះ ។ **ឈុន ឡៃហេង**

# ម្ដាយមីងរបស់ខ្ញុំ នាង គី : អាហារគឺជាជីវិត


នាង គី

ដើម្បីបានចូលសិក្សានៅសាលាល្អៗ បងប្អូនខ្ញុំទាំងប្រាំពីរនាក់ត្រូវមកស្នាក់នៅ និងសិក្សានៅភ្នំពេញ ដោយទទួលនូវជំនួយផ្នែកហិរញ្ញវត្ថុពីម្ដាយឪពុកដែលរស់នៅឯជនបទ ។ រស់នៅឆ្ងាយពីម្ដាយឪពុកយើងស្ថិតនៅក្រោមការមើលថែរក្សារបស់ម្ដាយមីង ។ គាត់ជាអ្នកធ្វើការងារផ្ទះទាំងអស់ មិនតែប៉ុណ្ណោះ គាត់បានបង្ហាត់យើងឲ្យចេះដឹងគុណ លើកទឹកចិត្តយើងឲ្យខិតខំសិក្សា ព្រមទាំងជះឥទ្ធិពលដល់ការរស់នៅប្រចាំថ្ងៃរបស់យើងទៀតផង ។ យើងបានទម្លាប់ញ៉ាំអាហារឲ្យអស់ពីចាន គឺមិនឲ្យសល់ សូម្បីតែបាយមួយគ្រាប់ឡើយ ។ ម្ដាយមីងរបស់ខ្ញុំ បានអប់រំថា «អាហារគឺជាជីវិត យើងមិនត្រូវខ្ជះខ្ជាយនោះទេ ។» ដើម្បីគាំទ្រដល់ការអះអាងនេះ គាត់បាននិយាយប្រាប់យើងនូវបទពិសោធរបស់គាត់កាលពីជំនាន់ខ្មែរក្រហម ។ នៅពេលដែលគាត់ប្រាប់លើកដំបូង ខ្ញុំនៅក្មេង ហើយពុំបានដឹងនូវប្រវត្តិសាស្ត្ររបស់ប្រទេសឡើយ ។ ហេតុនេះខ្ញុំមិនជឿថា ហេតុការណ៍ដ៏អាក្រក់នេះធ្លាប់កើតមាននោះឡើយ ហើយគិតថា អ្វីដែលគាត់និយាយ គឺគ្រាន់តែជារឿងប្រឌិតដើម្បីកុំឲ្យយើងខ្ជះខ្ជាយអាហារតែប៉ុណ្ណោះ ។ យ៉ាងណាមិញ ក្រោយពីបានចូលបម្រើការនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា និងតាមរយៈការសិក្សាប្រវត្តិសាស្ត្រស្ដីពីរបបខ្មែរក្រហម ទើបខ្ញុំដឹងនូវគ្រប់ម៉ាត់ដែលម្ដាយមីងរបស់ខ្ញុំបានលើកឡើង គឺសុទ្ធសឹងតែជាការពិតទាំងអស់ ។

នៅឆ្នាំ១៩៧២ ខ្មែរក្រហមបានកាន់កាប់ស្រុកកណ្ដាលស្ទឹង ដែលជាហេតុបង្ខំឲ្យម្ដាយមីងរបស់ខ្ញុំ ម្ដាយជរា ប្អូនស្រីគាត់ និងម្ដាយរបស់ខ្ញុំភៀសខ្លួនទៅកាន់ទីក្រុងភ្នំពេញ ។ នៅពេលដែលចាកចេញពីស្រុកកំណើត គាត់ទាំងអស់គ្នា បានបាត់បង់នូវទ្រព្យសម្បត្តិទាំងអស់ ហើយត្រូវចាប់ផ្ដើមនូវជីវិតថ្មីដោយបាតដៃទទេ ។ ដោយសារតែគ្មានសាច់ញាតិនៅភ្នំពេញ អ្នកទាំងអស់គ្នា បានជួលទីវាលប្រមាណ២០ម៉ែត្រការ៉េ ដើម្បីសាងសង់ខ្ទមតូចមួយ ក្នុងគោលបំណងស្នាក់នៅ និងចាប់ផ្ដើមអាជីវកម្មតូចមួយ ។ គាត់លក់ថ្នាំជក់ ដើម្បីទ្រទ្រង់ការរស់នៅ ហើយចំណូលពីរបរនេះគឺបានត្រឹមតែផ្គត់ផ្គង់ដល់ចំណាយលើម្ហូបអាហារប្រចាំថ្ងៃប៉ុណ្ណោះ ។ បីឆ្នាំកន្លងផុតទៅ អាជីវកម្មរបស់គាត់មានភាពលូតលាស់ ហើយជីវភាពរបស់គាត់ក៏មានភាពប្រសើរជាងមុន ។ ជាអកុសល ពេលវេលារីករាយនេះពុំស្ថិតស្ថេរបានយូរឡើយ ។ ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលទីក្រុងភ្នំពេញ ។ ដូចគ្នាទៅនឹងប្រជាជនដទៃដែរ គ្រួសាររបស់ម្ដាយខ្ញុំ ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញចំនួនបីថ្ងៃ ។ ម្ដាយមីងខ្ញុំ ម្ដាយរបស់គាត់ ប្អូនស្រីរបស់គាត់ និង ម្ដាយខ្ញុំ ម្ដីម្នាវេចខ្ចប់ ហើយចូលរួមជាមួយហ្វូងមនុស្សភៀសខ្លួនចេញពីក្រុងភ្នំពេញ ។ គាត់ទាំងអស់ មានពេលសម្រាប់តែវេចខ្ចប់នូវអង្ករមួយបង្ខេច ចានឆ្នាំង ប្រាក់កាស និងសម្លៀកបំពាក់តែប៉ុន្មានសម្រាប់ប៉ុណ្ណោះ ។

នៅតាមផ្លូវ គាត់ឃើញសាកសពរបស់ទាហាន លន់ នល់ជាច្រើន ។ មនុស្សម្នានាំគ្នាតម្រង់ទៅជាយក្រុង ។ ពុំមាននរណាម្នាក់ហ៊ានបែរត្រឡប់មកភ្នំពេញវិញឡើយ ព្រោះខ្មែរក្រហមបានគំរាមសម្លាប់ ប្រសិនមាននរណាម្នាក់ហ៊ានធ្វើដូច្នោះ ។ ម្នាក់ៗធ្វើដំណើរនៅពេលថ្ងៃហើយ ឈប់សម្រាកនៅពេលយប់ ។ អ្នកជម្លៀសត្រូវសម្រាកនៅគ្រប់ទីកន្លែងតាមដងផ្លូវ ពេលខ្លះគឺស្ថិតនៅក្បែរសាកសពទៀតផង ។ ចំណែកឯម្ដាយមីងរបស់ខ្ញុំ ដែលធ្លាប់តែខ្វាចខ្មោច ក៏បានប្រែក្លាយទៅជាក្លាហាន ។ ការកង្វះអាហារកើតមានឡើង ។ ចំពោះអ្នកដែលបានយកអាហារមកតាមខ្លួនច្រើន ចាប់ផ្ដើមលក់អាហារទាំងនោះ ក្នុងតម្លៃខ្ពស់ ដែលជាហេតុ

បណ្ដាលឲ្យមនុស្សភាគច្រើនពុំមានលទ្ធភាពទិញ ។ ពុំមានវិធីក្នុង ការទិញអាហារ គ្រួសាររបស់ខ្ញុំត្រូវប្រឈមនឹងភាពអត់ឃ្លាន ។ បន្ទាប់ពីដំណើរដ៏លំបាកលំបិន ដែលមានរយៈពេលប្រមាណជាមួយ សប្ដាហ៍ នៅទីបំផុត ម្ដាយមីង និងសាច់ញាតិបីរូបផ្សេងទៀតរបស់ គាត់ បានមកដល់ភូមិទ្រាត្រស់ ដែលស្ថិតនៅក្នុងខេត្តកណ្ដាល ។

គ្រួសាររបស់មីងខ្ញុំត្រូវសាងសង់ខ្ទមនៅក្នុងភូមិនេះ ហើយ គាត់ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅតាមវាលស្រែ លើកលែង តែលោកយាយរបស់ខ្ញុំដែលត្រូវបានឲ្យនៅផ្ទះ និងបំពេញការងារ ស្រាលមួយចំនួន ។ ពីរឬបីខែក្រោយមក អង្គការបានមកកត់ឈ្មោះ អ្នកទាំងឡាយណាដែលចង់វិលត្រឡប់ទៅស្រុកកំណើតវិញ ។ គ្រួសាររបស់មីងខ្ញុំ ក៏បានធ្វើការចុះឈ្មោះ ។ ខ្មែរក្រហមបានបញ្ជូន រថយន្តធំ ដោយមានផ្ទុកនូវមនុស្សដ៏ច្រើនកុះករ និងមានសភាព ក្ដៅជាខ្លាំង ។ ដោយសារតែកង្វះអាហារ ម្ដាយមីងរបស់ខ្ញុំ និង សាច់ញាតិរបស់គាត់ស្ទើរតែនឹងសន្ទប់ ។ មានអ្នកខ្លះបានស្ម័គ្រចិត្ត ទៅកាន់តំបន់ណាមួយជាក់លាក់ ឯអ្នកខ្លះទៀត ដូចជា ម្ដាយមីងខ្ញុំ និងគ្រួសារគាត់ យល់ព្រមទៅកាន់ទីតាំងណាដែលអង្គការចាត់ ចែង ។ អ្នកទាំងអស់គ្នាត្រូវអង្គការបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់ មុនពេលដែលត្រូវបានបង្ខំឲ្យជិះរថភ្លើងទៅកាន់ភ្នំធិបតី នៅឯខេត្ត បាត់ដំបង ។

អ្នកទាំងអស់គ្នាត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅឯជើងភ្នំ ដែលជាទីកន្លែងដែលគាត់ទាំងអស់ត្រូវចាត់តាំងឲ្យធ្វើស្រែ ។ យាយរបស់ខ្ញុំត្រូវអនុញ្ញាតឲ្យនៅផ្ទះ និងដាំបន្លែនៅជុំវិញផ្ទះ ។ អង្គការបានចែកអង្ករ ឲ្យគាត់ម្នាក់មួយកញ្ចប់តូច ។ របបដែល គាត់ទាំងអស់គ្នាទទួលកាន់តែតិចទៅៗ ។ ក្រោយមក សមាជិក គ្រួសាររបស់មីងខ្ញុំ ទទួលបានត្រឹមតែបបររាវដែលមានអង្ករតែពីរ ទៅបីគ្រាប់មួយចានប៉ុណ្ណោះ ។ វាហាក់ដូចជាផឹកទឹកសុទ្ធសាធ ។ ការកង្វះអាហារនេះ បានបណ្ដាលឲ្យយាយរបស់ខ្ញុំធ្លាក់ខ្លួនឈឺ ។ ដោយពុំមានថ្នាំ និងមន្ទីរពេទ្យសម្រាប់ព្យាបាល គាត់ក៏បាត់បង់ ជីវិតទៅ ។ បន្ទាប់មក ម្ដាយមីងខ្ញុំក៏បានស្នើឲ្យប្រជាជនថ្មីដទៃទៀត ជួយដល់គាត់ក្នុងការកប់ម្ដាយគាត់នៅក្នុងព្រៃនៅឯជើងភ្នំ ។

ម្ដាយមីងខ្ញុំ ប្អូនស្រីរបស់គាត់ និងម្ដាយខ្ញុំត្រូវអង្គការបញ្ជូន ទៅកាន់កងនារី ដែលនៅទីនោះ គាត់ទាំងបីហូប និងសម្រាករួមគ្នា ។ ដំបូង គាត់ទាំងបីបានទទួលនូវបាយហូប តែក្រោយមក គឺទទួលបាន ត្រឹមទឹកបបរដូចកាលពីមុន ។ អ្នកទាំងបីត្រូវលើកភ្លឺស្រែ និងធ្វើ ការងារធ្ងន់ធ្ងរដទៃទៀត ។ ការធ្វើការហួសកម្លាំង លក្ខខណ្ឌការងារ ហួសហេតុ និងកង្វះអាហារ បណ្ដាលឲ្យប្អូនស្រីរបស់ម្ដាយមីងខ្ញុំ មានជំងឺ ។ អង្គការបានបញ្ជូនគាត់ទៅកាន់មន្ទីរពេទ្យ ដោយមិន អនុញ្ញាតឲ្យម្ដាយមីង និងម្ដាយខ្ញុំទៅជាមួយឡើយ ។ ម្ដាយមីងខ្ញុំ ដែលបានបញ្ជូនទៅកាន់មន្ទីរពេទ្យពុំបានត្រឡប់មកវិញឡើយ ។ អង្គការក៏ដូចជាមន្ទីរពេទ្យ មិនបាននាំនូវដំណឹងអ្វីសោះ ។ មួយរយៈ ក្រោយមកទើបដឹងថា ម្ដាយមីងខ្ញុំម្នាក់នោះ បានបាត់បង់ជីវិតទៅ ហើយ ។

ក្រោយពីមរណភាពរបស់យាយ និងមីងខ្ញុំម្នាក់ទៀត ម្ដាយ មីង និងម្ដាយខ្ញុំត្រូវអង្គការបញ្ជូនទៅធ្វើការនៅកងដទៃទៀត ។ បន្ទាប់មក គាត់ទាំងពីរក៏ចាប់ផ្ដើមរស់នៅបែកពីគ្នា ។ ម្ដាយខ្ញុំត្រូវ អង្គការបញ្ជូនទៅកាន់សមរភូមិបន្ទាប់ ឯម្ដាយមីងខ្ញុំនៅឯព្រៃនៅ ទួលម្ទេស ។ នៅឯតំបន់ព្រៃនោះពុំមានអាហារគ្រប់គ្រាន់ឡើយ មានអ្នកខ្លះអត់ឃ្លានរហូតដល់ស្លាប់ ។ នៅទួលម្ទេសនេះ តួនាទី របស់ម្ដាយមីងខ្ញុំគឺកាប់ឆ្ការព្រៃ ។ ដើម្បីបញ្ចៀសនូវភាពអត់ឃ្លាន គាត់ក៏សម្រេចដើរស្វែងរកជីកដំឡូងហូប ។ គាត់ត្រូវឈ្លបតាម ទាន់ និងចាប់ខ្លួនបញ្ជូនទៅមន្ទីរកសាង ដែលនៅទីនោះ កម្មាភិបាល ខ្មែរក្រហម ដាក់ខ្នោះជើងគាត់ និងចាក់សោជាប់ទៅនឹងជញ្ជាំង ។ ម្ដាយមីងខ្ញុំប្រាកដថា គាត់នឹងត្រូវយកទៅសម្លាប់នៅពេលព្រឹក ដូចនេះ គាត់ក៏ព្យាយាមដើម្បីរត់គេច ។ គាត់រំដោះខ្លួនបានសម្រេច ហើយរត់ទៅកាន់កន្លែងគេងវិញ ប៉ុន្តែ ជើងនិងដៃរបស់គាត់នៅ ជាប់ខ្នោះនៅឡើយ ។ នៅពេលដែលគាត់កំពុងរិះរកមធ្យោបាយ យកខ្នោះទាំងនោះចេញ ម្ដាយខ្ញុំក៏បានមកសាកសួរសុខទុក្ខគាត់ ។ បន្ទាប់ពីបានគិតគូរគ្នារួចស្រេច ម្ដាយខ្ញុំក៏ទៅកាន់ផ្ទះរបស់កម្មាភិបាល ដើម្បីខ្ចីពូថៅពីរ ដោយកុហកថាយកវាទៅកាប់ឧស ។ ក្រោយពី កម្មាភិបាលឲ្យខ្ចីពូថៅ គាត់យកពូថៅនោះមកកាត់ខ្នោះទាំងនោះ ចេញ ។ ម្ដាយនិងម្ដាយមីងខ្ញុំជឿថា ប្រសិនបើគាត់ទាំងពីរបន្តនៅ ទីនោះទៀត ច្បាស់ជានឹងត្រូវអង្គការសម្លាប់មិនខាន ។ គាត់ទាំងពីរ បានក្លែងសំបុត្រមួយច្បាប់ដែលបង្ហាញថា គាត់អាចចូលក្នុងតំបន់ ដទៃ ដើម្បីស្វែងរកសាច់ញាតិ ។ ក្លែងសំបុត្រ គឺជាអំពើមួយដែល

មានគ្រោះថ្នាក់ ប៉ុន្តែគាត់ទាំងពីរពុំមានជម្រើសឡើយ ។ គាត់បានរត់ចេញទាំងយប់ ដោយឆ្លងទន្លេ និងជួបប្រទះនឹងបញ្ហាផ្សេងៗទៀតជាច្រើន ។ ទីបំផុត នៅពេលព្រលឹមស្រាងៗ គាត់ទាំងពីរបានមកដល់បរវេល ។

នៅពេលដែលគាត់មកដល់ភ្លាម កម្មាភិបាលតំបន់ បានសួរថា ប្រសិនណាបើម្តាយ និងម្តាយមីងរបស់ខ្ញុំនៅតែពុំអាចរកសាច់ញាតិឃើញ គាត់នឹងនៅតែបន្តស្វែងរកទៀតឬទេ? គាត់ទាំងពីរបានឆ្លើយថា គាត់ពុំមានសង្ឃឹមក្នុងការស្វែងរកទៀតនោះទេ ហើយក៏អង្វរកម្មាភិបាលខ្មែរក្រហមសុំជ្រកកោននៅទីនោះ ។ កម្មាភិបាលរូបនោះក៏យល់ព្រម ។ ស្ថានភាពរស់នៅ នៅបរវិលមានលក្ខណៈល្អប្រសើរជាងនៅតំបន់ដទៃ ។ នេះដោយសារតែមានកងកសិកម្មធំមួយនៅទីនោះ ។ លើសពីនេះទៀត កុក សុន ដែលជាប្រធាននៅទីនោះមានចិត្តទូលាយផងដែរ ។ អ្នកនៅក្នុងតំបន់នោះទទួលបានអាហារហូបចុកគ្រប់គ្រាន់ ។ អំពើសប្បុរសនេះ បានញាំងឲ្យកម្មាភិបាលតំបន់មួយរូបនេះ ត្រូវអង្គការយកទៅសម្លាប់ ហើយជំនួសមកវិញនូវកម្មាភិបាលភាគពាយ័ព្យ ។ ម្តាយមីងខ្ញុំ ម្តាយខ្ញុំ ព្រមទាំងអ្នកដទៃទៀតត្រូវទទួលរងនូវភាពអត់ឃ្លានម្តងទៀត ។ ភាពសោកសង្រេងនេះបានបន្តរហូតដល់ការដួលរលំនៃរបបខ្មែរក្រហមនាឆ្នាំ ១៩៧៩ ។ ដោយសារតែបទពិសោធដ៏ឈឺចាប់ ព្រមទាំងភាពដែលស៊ើរស្លាប់ជាច្រើនដង ម្តាយមីងខ្ញុំ តែងរំឭកបងប្អូនទាំងប្រាំពីរកុំឲ្យខ្ជះខ្ជាយសូម្បីតែអង្ករមួយគ្រាប់ ។ គាត់ចង់ឲ្យរបបនេះ កប់ជ្រៅនៅក្រោមដី និងកុំលេចឡើងជាថ្មី ។ ការឈឺចាប់នៃការបាត់បង់សាច់ញាតិនឹងដក់ជាប់ក្នុងចិត្តគាត់ជានិច្ច ។ ដោយបានដឹងថា យុវជនជំនាន់ក្រោយ ត្រូវបានអប់រំពីអំពើប្រល័យពូជសាសន៍ គាត់មានភាពសោមនស្សរីករាយជាខ្លាំង ។ គាត់ជឿជាក់ថា តាមរយៈការអប់រំ កូនចៅនៃជនរងគ្រោះក្នុងរបបខ្មែរក្រហមនឹងយល់ដឹង ហើយរួបរួមគ្នាទប់ស្កាត់នូវរបបដ៏ឃោរឃៅនេះ កុំឲ្យកើតឡើងជាថ្មី ។

**សុភ័ក្រ្ត ភាណា**

# ដំណឹងប្រកាសរកពូ



ខ្ញុំបាទឈ្មោះ សាំង សុធា មានស្រុកកំណើតនៅឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង សព្វថ្ងៃរស់នៅសង្កាត់ទំនប់ទឹក ខណ្ឌចំការមន ក្រុងភ្នំពេញ សូមប្រកាសរកពូឈ្មោះ ប៊ុន អាង (បច្ចុប្បន្នមានអាយុជាង៧០ឆ្នាំ) ។ ប៊ុន អាង ជាគ្រូបង្រៀន មានស្រុកកំណើតនៅឃុំព្រៃកពោធិ៍ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ គាត់បានចេញទៅបង្រៀននៅខេត្តស្វាយរៀង ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់គាត់ឃុំឃាំង នៅវត្តឫស្សី ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។ ក្រោយមក ខ្មែរក្រហមបានដោះលែងគាត់ ហើយឲ្យមករស់នៅជាមួយគ្រួសារខ្ញុំនៅភូមិព្រះទន្លេ ស្រុកស្វាយជ្រំ ។

មកដល់ចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានជម្លៀស គ្រួសារខ្ញុំទៅរស់នៅខេត្តពោធិ៍សាត់ ហើយចាប់តាំងពីពេលនោះមកខ្ញុំបានបែកពីគាត់រហូត ។ នៅពេលថ្មីៗនេះ ខ្ញុំទើបឮដំណឹងថា គាត់រស់នៅសហរដ្ឋអាមេរិក និងបានមកសាកសួររកប្អូនរបស់គាត់នៅព្រៃកពោធិ៍ ។

ប្រសិនបើពូបានឃើញការប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈលេខទូរស័ព្ទ ០១២ ២៨២ ២២២ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ រាជធានីភ្នំពេញ ឬលេខទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

# ឪពុករបស់ខ្ញុំ គ្មានឱកាសធ្វើនូវអ្វីដែលគាត់និយាយ

ឪពុករបស់ខ្ញុំឈ្មោះ លី ហាំងង៉ូវ កើតនៅស្រុកស្អាង ខេត្តកណ្តាល ដែលមានឪពុកម្តាយជាជនជាតិចិន ។ យាយតាខ្ញុំបានភៀសខ្លួនមកកម្ពុជាក្នុងទសវត្សរ៍១៩៤០ នៅពេលដែលប្រទេសចិនកំពុងតែជួបប្រទះនូវសង្រ្គាមស៊ីវិល ។ នៅពេលដែលឪពុកខ្ញុំមានអាយុ១២ឆ្នាំ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីអំណាច ។ ប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងភ្លើងសង្រ្គាម ហើយស្ថានការណ៍នោះបានធ្វើឲ្យយាយតាខ្ញុំរត់ភៀសខ្លួនម្តងទៀត ។ អស្ថិរភាពនយោបាយ និងការប្រយុទ្ធគ្នា បានធ្វើឲ្យគ្រួសាររបស់ឪពុកខ្ញុំផ្លាស់ពីភ្នំពេញទៅនៅតាខ្មៅ ។ ដោយសារតែការផ្លាស់ប្តូរទីលំនៅ និងជីវភាពគ្រួសារមានភាពយ៉ាប់យឺន ។ ដូច្នេះឱកាសចូលសាលារៀនរបស់ឪពុកខ្ញុំ ត្រូវបានបាត់បង់ ហើយគាត់ត្រូវតែចេញក្រៅស្វែងរកប្រាក់ចំណូលបន្ថែមដោយដើរលក់ការ៉េម ដើម្បីទ្រទ្រង់ជីវភាពគ្រួសារ ។

នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសារឪពុករបស់ខ្ញុំបានចេញទៅស្វាគមន៍កងទ័ពខ្មែរក្រហម ។ គ្រួសារខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ ហើយថែមទាំងគិតថា សន្តិភាពនឹងត្រឡប់មកវិញ ។ ប៉ុន្តែក្តីសង្ឃឹមនោះ បានប្រែទៅជាសុបិនអាក្រក់ នៅពេលដែលខ្មែរក្រហមបានបញ្ជាឲ្យគ្រួសាររបស់ឪពុកខ្ញុំចាកខ្ញុំចេញពីផ្ទះយ៉ាងប្រញាប់ ។ ខ្មែរក្រហមប្រាប់ថា អ្នកទាំងអស់ត្រូវតែគេចខ្លួន ពីព្រោះអាមេរិកនឹងទម្លាក់គ្រាប់បែកនៅក្នុងទីក្រុង ហើយអ្វីៗនឹងប្រែក្លាយមកជាធម្មតាវិញក្នុងរយៈពេលពីរទៅបីថ្ងៃទៀត ។



ឪពុករបស់ លី ហួតផេង (រូបអង្គុយខាងស្តាំ ជួរខាងមុខ) ថតនៅក្នុងពិធីមង្គលការកូនស្រី

គ្រួសាររបស់ឪពុកខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ) ។ នៅពេលដែលប្រជាជនកំពុងធ្វើដំណើរទៅកាន់គោលដៅរបស់ខ្លួន អ្នកខ្លះបានយកមកជាមួយនូវស្បៀងអាហារ ចាន ឆ្នាំង សម្រាប់ធ្វើម្ហូបនៅតាមផ្លូវ ។ គ្រួសាររបស់ឪពុកខ្ញុំ មិនយកអ្វីមកជាមួយទេ ក្រៅពីលុយកាក់បន្តិចបន្តួច ដែលគាត់យកទៅទិញស្បៀងអាហារពីអ្នកដទៃ ។ ឪពុកខ្ញុំនិយាយថា "អំឡុងពេលនោះអ្នកខ្លះឆ្លៀតឱកាសលក់ដូររបស់របរ ដោយជឿលើការឃោសនាថា ខ្មែរក្រហមនឹងបើកឲ្យចាយលុយនៅពេលឆាប់ៗខាងមុខ" ។ ក្នុងអំឡុងពេលជម្លៀស គ្រួសារឪពុកខ្ញុំបានសម្រាន្តនៅលើដី និងដោយគ្មានអ្វីបិទបាំង ។ គាត់បានឃើញមនុស្សជាច្រើនដើរស្វែងរកសមាជិកគ្រួសាររបស់ខ្លួន ។ ក្មេងៗស្រែកយំរកឪពុកម្តាយ ចំណែកអ្នកខ្លះដួលស្លាប់ដោយសារអាកាសធាតុក្តៅ ។

នៅពេលទៅដល់ស្រុកព្រះនេត្រព្រះ អង្គការបានបែងចែកសមាជិកគ្រួសារនីមួយៗ ឲ្យទៅធ្វើការនៅកន្លែងខុសៗគ្នាទៅតាមអាយុរៀងៗខ្លួន ។ ឪពុកខ្ញុំត្រូវបានចាត់ឲ្យទៅធ្វើការក្នុងកងយុវជននៅភូមិផ្សេង ។ ពេលដែលឪពុកខ្ញុំរៀបចេញដំណើរ គាត់បានប្រាប់យាយតាខ្ញុំថា "ប៉ា! ម៉ាក់! ខ្ញុំនឹងមកជួបអ្នកទាំងពីរនៅពេលឆាប់នេះ" ។ នេះគឺជាព្រឹត្តការណ៍ឈឺចាប់ក្នុងជីវិតរបស់គាត់ ព្រោះនេះគឺជាលើកចុងក្រោយដែលគាត់បានជួបឪពុកម្តាយ និងបងប្អូនរបស់គាត់ ។

ឪពុកខ្ញុំត្រូវបានខ្មែរក្រហមចាត់ឲ្យទៅលើកទំនប់ និងជីកប្រឡាយ ។ គាត់ត្រូវធ្វើការពីព្រលឹមរហូតដល់ដល់ម៉ោង៨យប់ ជួនកាលទៅដល់ម៉ោង១០យប់ទៀត ។ នៅរដូវប្រាំងចូលមកដល់ សមាជិកក្នុងអង្គភាពរបស់គាត់បានដួលស្លាប់ដោយសារតែមិនអាចទ្រាំទ្រនឹងការងារធ្ងន់ធ្ងរ ។ ឪពុកខ្ញុំបានប្រាប់ថា កាលនោះគាត់ធ្វើការដូចទាសករ ដើម្បីដូរយកបបរដើម្បីរស់ដោយសង្ឃឹមថា ថ្ងៃណាមួយនឹងអាចត្រឡប់ទៅជួបជុំក្រុមគ្រួសារវិញ ។

ថ្ងៃមួយ មេក្រុមនៅក្នុងភូមិបានប្រកាសថា ប្រទេសកម្ពុជាត្រូវបានរំដោះចេញពីរបបខ្មែរក្រហមហើយ ។ កងទ័ពវៀតណាម និងរណសិរ្សរំដោះជាតិ នឹងមកដល់តំបន់របស់គាត់ ។ ស្ថានការណ៍ពេលនោះមានភាពជ្រួលច្របល់ ម្នាក់ៗព្យាយាមរត់ទៅរកកន្លែងលាក់ខ្លួនពីខ្មែរក្រហម និងការប្រយុទ្ធគ្នា ។ ប៉ុន្តែខ្មែរក្រហមបានរត់ចេញពីភូមិមុន ដោយគ្មាននរណាម្នាក់ដឹងថា ខ្មែរក្រហមទាំងអស់នោះទៅទីណាឡើយ ។

ឪពុកខ្ញុំប្រញាប់ប្រញាល់ទៅរកយាយតាខ្ញុំនៅឯកន្លែងដែលខ្មែរក្រហមជម្លៀសគាត់ទៅ ។ ប៉ុន្តែ ឪពុកខ្ញុំមិនឃើញយាយតាខ្ញុំនៅទីនោះទេ ។ មានអ្នកភូមិប្រាប់ឪពុកខ្ញុំថា ឃើញប្រជាជនជាច្រើនកំពុងតែធ្វើដំណើរឆ្ពោះទៅស្រុកកំណើតរៀងៗខ្លួន ។ បន្ទាប់ពីការស្វែងរកនៅក្នុងស្រុកព្រះនេត្រព្រះមិនឃើញ ឪពុកខ្ញុំនិងអ៊ំប្រុសរបស់ខ្ញុំបានដើរធ្វើដំណើរ ដោយថ្មើរជើងទៅស្រុកស្អាង ដើម្បីស្វែងរកក្រុមគ្រួសាររបស់គាត់បន្តទៀត ។ នៅពេលទៅដល់ស្អាង ប្រជាជនសុទ្ធតែជាមនុស្សចំណូលថ្មី គាត់ពុំស្គាល់នរណាម្នាក់ទេ ។ ប៉ុន្តែគាត់មិនអស់សង្ឃឹមនោះទេ គាត់នៅតែរង់ចាំគ្រួសាររបស់គាត់ត្រឡប់មកវិញ ។ ចុងក្រោយ មានអ្នកជិតខាងម្នាក់មកដល់ស្អាង ហើយប្រាប់ឪពុកខ្ញុំថា ឪពុកម្តាយ និងបងប្អូនរបស់គាត់ បានស្លាប់ដោយសារការអត់ឃ្លាន និងជំងឺអស់ហើយ ។

ឪពុកខ្ញុំ និងបងប្រុសគាត់ចាប់ផ្តើមជីវិតថ្មីដោយដៃទទេ និងការឈឺចាប់ ។ ការឈឺចាប់បានកើតឡើងម្តងទៀត នៅពេលដែលបងប្រុសតែម្នាក់របស់គាត់បានស្លាប់ នៅឆ្នាំ១៩៨៥ ។ ឪពុករបស់ខ្ញុំមិនដែលប្រាប់ខ្ញុំថា ជីវិតរបស់គាត់គ្មានន័យនោះទេ ។ អ្វីដែលគាត់ប្រាប់ខ្ញុំ គឺឲ្យខ្ញុំត្រូវចេះគិតអំពីគ្រួសារ និងព្យាយាមធ្វើឲ្យគ្រួសារសប្បាយរីករាយ ។ ឪពុកខ្ញុំប្រាប់ខ្ញុំថា "គាត់គ្មានឱកាសធ្វើនូវអ្វីដែលគាត់និយាយជាមួយឪពុកម្តាយគាត់ថា ប៉ា! ម៉ាក់! ខ្ញុំនឹងមកជួបអ្នកទាំងពីរនៅពេលឆាប់ៗនេះ" ទេ ។

មានមនុស្សតិចណាស់ដែលដឹងពីការឈឺចាប់របស់ឪពុកខ្ញុំ សូម្បីតែកូនៗរបស់គាត់ ។ ខ្ញុំបានព្យាយាមសួរគាត់ច្រើនដង រហូតគាត់អាចប្រាប់ខ្ញុំអំពីបទពិសោធរបស់គាត់ក្នុងរបបខ្មែរក្រហម ។ ខ្ញុំដឹងថា គាត់នឹងឈឺចាប់នៅពេលរំឭករឿងរ៉ាវទាំងឡាយដែលគាត់ជួបប្រទះក្នុងរបបខ្មែរក្រហម ប៉ុន្តែវាជាការល្អដែលឲ្យកូនៗរបស់គាត់ដឹងអំពីប្រវត្តិរបស់គាត់ ដើម្បីឲ្យកូនៗរបស់គាត់ស្វែងយល់ពីគាត់បន្ថែម ។ ពីមុនខ្ញុំខឹងឪពុកខ្ញុំ ហេតុអ្វីបានជាគាត់បារម្ភពីខ្ញុំជ្រុលនូវអ្វីដែលខ្ញុំអាចធ្វើបាន ។ ឥឡូវខ្ញុំចាប់ផ្តើមយល់អំពីមូលហេតុដែលធ្វើឲ្យគាត់មានការគិតបែបនេះ ។ **លី ហួតផេង**

# ខ្មែរក្រហមសម្លាប់បងប្រុសខ្ញុំ

ហង្ស ថាវី មានអាយុ៤៤ឆ្នាំ មានស្រុកកំណើតនៅភូមិកោះរះក្រោម ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្ដាល ។ គាត់មានឪពុកឈ្មោះ សូ ហុង (ស្លាប់) និងម្ដាយ ឃី ហៀង (ស្លាប់) ។ ថាវី មានបងប្អូនចំនួនប្រាំមួយនាក់ ប្រុសពីរនាក់ ស្រីបួននាក់ ។ គាត់គឺជាជនរងគ្រោះមួយរូប ក្នុងចំណោមជនរងគ្រោះជាច្រើនដែលរួចរស់ជីវិតពីរបបខ្មែរក្រហម ។ នៅក្នុងរបបខ្មែរក្រហម ថាវី គ្រាន់តែជាក្មេងស្រីតូចម្នាក់ប៉ុណ្ណោះ ។ ទោះបីជា ស្ថិតក្នុងវ័យក្មេងខ្ចីក៏ដោយ ក៏គាត់នៅចងចាំរឿងរ៉ាវដែលបានកើតឡើងចំពោះខ្លួនគាត់ និងគ្រួសាររបស់ខ្លួន ដែលធ្លាប់រងទុកវេទនាក្រោមរបបខ្មែរក្រហម ។

នៅមុនឆ្នាំ១៩៧៥ ពេលដែលកំពុងរត់លេងជាមួយក្មេងៗដទៃទៀតនៅក្នុងភូមិ ស្រាប់តែមានយោធាច្រើនណាស់ចូលមកភូមិរបស់ ថាវី ។ គាត់មិនដឹងថា យោធាទាំងនោះជានរណា ឬកងកម្លាំងខាងណានោះទេ ។ អ្នកភូមិ ក៏ដូចជាគ្រួសាររបស់គាត់ បាននាំគ្នាភៀសខ្លួនចេញពីភូមិ ដើម្បីគេចចេញពីការប្រយុទ្ធគ្នារបស់យោធាទាំងនោះ ។ អ្នកទាំងអស់គ្នា បានរត់មកដល់ភូមិកោះប្រាក់ដែលជាទីមួយមានសុវត្ថិភាព ។ មិនយូរប៉ុន្មាន ទើប ថាវី ដឹងថា ការប្រយុទ្ធគ្នានោះ គឺជាការប្រយុទ្ធគ្នា រវាងយោធាខ្មែរក្រហម និងកងទ័ព លន់ នល់ ។ ក្រោយមក ខ្មែរក្រហមបានវាយដណ្ដើមកាន់កាប់ តំបន់ទាំងមូល សូម្បីតែនៅខាងកោះប្រាក់ ក៏ខ្មែរក្រហមគ្រប់គ្រងបានដែរ ។ ខ្មែរក្រហម បានជម្លៀសប្រជាជនទាំងអស់ ដែលបានរត់ចេញពីភូមិកោះរះទាំងប៉ុន្មាន ឲ្យត្រឡប់ទៅភូមិវិញ ។

បន្ទាប់ពីទទួលជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្ដើមប្រមូលទ្រព្យសម្បត្តិ ប្រជាជនទាំងអស់ដាក់ជាទ្រព្យសម្បត្តិរួមរបស់សមូហភាព ក៏ដូចជាអង្គការ ។ ខ្មែរក្រហមចាប់ផ្ដើមឲ្យមានហូបបាយរួម និងធ្វើការងាររួមគ្នា ។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានជម្លៀសប្រជាជនដែលរស់នៅភូមិកោះរះនេះ ទៅកាន់ខេត្តបាត់ដំបង ។ គ្រួសារ ថាវី មិនត្រូវបានជម្លៀសនោះទេ ដោយសារតែឪពុករបស់គាត់ឈឺធ្ងន់ ហេតុនេះ អង្គការសម្រេចឲ្យទុកនៅក្នុងភូមិសិន ។ មុននឹងធ្វើការជម្លៀសប្រជាជន ខ្មែរក្រហមបានធ្វើការសាកសួរពីប្រវត្តិគ្រួសារនីមួយៗ ដើម្បីស្វែងរកអ្នកដែលមាននិន្នាការ ជាទាហាន លន់ នល់ អ្នករដ្ឋការ គ្រូបង្រៀនជាដើម ។ អ្នកដែលមានជាប់និន្នាការ គឺខ្មែរក្រហមនាំយកទៅ ដោយគ្រាន់តែប្រាប់ថា យកទៅរៀនសូត្រ តែមិនដឹងថា វាសនារបស់អ្នកទាំងនោះទៅជាយ៉ាងណានោះទេ ។ អំឡុងពេលនោះ ថាវី ក៏បានបាត់បង់បងប្រុសម្នាក់ដែរ ក្រោយពេលដែលខ្មែរក្រហម ស៊ើបដឹងថា បងប្រុសរបស់គាត់ជាគ្រូបង្រៀន ។ ដោយសារ ថាវី នៅក្មេងសេចក្ដីមិនដឹងថា ពាក្យយកទៅរៀនសូត្រនោះមានន័យយ៉ាងណានោះទេ គាត់ចាំបងប្រុស ចាំបាត់ៗមិនឃើញត្រឡប់មកវិញ ក៏សួរទៅម្ដាយរកបងប្រុស ។ ម្ដាយរបស់គាត់ប្រាប់ថា ពាក្យថាយកទៅរៀនសូត្រនោះ គឺមានន័យថា យកទៅសម្លាប់ហើយ ដូច្នេះ បងប្រុសឯងប្រហែលជាខ្មែរក្រហមយកទៅសម្លាប់ហើយ ។ ថាវី ឈឺចិត្តយ៉ាងខ្លាំង នឹកស្រណោះដល់ប្រុស ។ បន្ទាប់ពីចាត់តាំងឲ្យហូបបាយរួម និងធ្វើការងាររួម អង្គការចាប់ផ្ដើមបំបែកគ្រួសារចេញពីគ្នា ។ មិនខុសពីកុមារដទៃទៀតដែរ ថាវី ត្រូវអង្គការយកទៅធ្វើការនៅកងកុមារ ។ នៅសម័យខ្មែរក្រហម មិនថា ចាស់ ក្មេង ទេ គឺត្រូវធ្វើការទាំងអស់ ។ អ្នកដែលខ្ជិលធ្វើការ ត្រូវចាត់ទុកថា ខ្មាំងបំផ្លាញ និងធ្វើឲ្យរាំងស្ទះដល់បដិវត្តន៍ ហេតុនេះ ត្រូវតែកម្ទេចក្រោមពាក្យស្លោកមួយថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត" ។

មិនយូរប៉ុន្មាន ក៏មានប្រជាជនមួយចំនួន ត្រូវខ្មែរក្រហមជម្លៀសមកដល់ភូមិរបស់ ថាវី ។ អ្នកទាំងនោះភាគច្រើនមកពីខាងកៀនឃ្លាំង ដែលខ្មែរក្រហមចាត់ទុកប្រជាជនទាំងនោះជាជនជាប់និន្នាការ និងអាចជាខ្មាំង សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ។ អង្គការបានចាត់តាំងឈ្លបឲ្យទៅរស់នៅ និងតាមដានគ្រួសារទាំងនោះ ម្នាក់មួយគ្រួសារ ដើម្បីស៊ើបឲ្យដឹងថា តើអ្នកទាំងអស់នោះមានបំណងក្បត់នឹងអង្គការ ឬយ៉ាងណា? អ្នកដែលរកឃើញថា មានបំណង

ឬកំហុសនោះ ត្រូវអង្គការយកទៅកម្ទេចភ្លាមៗ ដោយគ្មានការលើកលែងទេ ។ អង្គការបានលើកថា “សុខចិត្តសម្លាប់១០ខុស ប្រសើរជាងដោះលែងខុសម្នាក់” ។ ដោយសារតែហូបមិនគ្រប់គ្រាន់ បានធ្វើឲ្យម្ដាយ ផាវី ធ្លាក់ខ្លួនឈឺ ចុះស្គមនៅសល់តែស្បែកដណ្ដប់ឆ្អឹង ។ ផាវី ក៏ដូចជាបងប្អូនមួយចំនួនបានស្នើសុំអង្គការនៅមើលម្ដាយគាត់នៅឯមន្ទីរពេទ្យ តែត្រូវអង្គការបដិសេធ និងស្ដីឲ្យថា “បើនាំគ្នាទៅមើលនោះវាជា មិនបាច់ឈឺមិនបាច់ទៅមន្ទីរពេទ្យទេ យកទៅមើលខ្លួនឯងទៅ បើចេះជាងគ្រូពេទ្យនោះ” ។ ទុក្ខមួយមិនទាន់ផុតផងទុក្ខមួយទៀតក៏មកដល់ ឪពុក ផាវី ក៏បានធ្លាក់ខ្លួនឈឺម្ដងទៀត បន្ទាប់ពីគាត់ឃ្លានពេក ហើយដើរហូបអ្វីផ្ដេសផ្ដាស ក៏ធ្វើឲ្យពុល ចុករាកយ៉ាងខ្លាំង ។ មិនយូរប៉ុន្មាន ឪពុករបស់គាត់ក៏បានស្លាប់ទៅនៅឆ្នាំ១៩៧៦ ដោយសារតែគ្មានថ្នាំព្យាបាល ។ បន្ទាប់ពីឪពុកស្លាប់ទៅ ផាវី នៅសល់តែម្ដាយម្នាក់ប៉ុណ្ណោះ ។ រាល់ថ្ងៃ នៅកងកុមារ គាត់ត្រូវអង្គការចាត់តាំងឲ្យឃ្វាលគោ និងរើសអាចម៍គោ ហើយសល់ពេលបន្តិចបន្តួចក្រៅពីធ្វើការងារ អង្គការប្រមូលក្មេងៗទាំងអស់ឲ្យទៅរៀនសូត្រ ។ គ្មានទេ សាលារៀននាពេលនោះ ការរៀនសូត្រ គឺរៀននៅក្រោមម្លប់ឈើ គ្មានសៀវភៅ ខ្មៅដៃ ឬប៊ិចនោះទេ ។ ការរៀនសូត្រនៅពេលនោះ គឺមិនដូចជាអ្វីដែលក្មេងៗគ្រប់គ្នាបានរៀននៅក្នុងថ្នាក់រៀននោះទេ អង្គការបង្រៀនផ្ដោតសំខាន់លើតែការដាំដុះស្រូវ ឲ្យចេះស្រឡាញ់ និងស្មោះត្រង់ចំពោះអង្គការឲ្យចេះរាយការណ៍ដល់អង្គការ ប្រសិនបើនរណាម្នាក់ធ្វើខុស មិនថា អ្នកដទៃ បងប្អូនសាច់ញាតិ ឬឪពុកម្ដាយឡើយ ។ អង្គការបាន ប្រាប់ថា ឪពុកម្ដាយ គ្រាន់តែជាអ្នកបង្កើតតែប៉ុណ្ណោះ តែអង្គការទើបជាអ្នកមានគុណក្នុងការបង្ហាត់បង្រៀន និង ចិញ្ចឹមបីបាច់ថែរក្សា ។

ក្នុងរបបខ្មែរក្រហម ទោះបីជា កុមារ ឬមនុស្សធំ ក៏ដោយ របបអាហារ គឺទទួលបានស្មើគ្នា ។ ម្នាក់ៗត្រូវធ្វើការជាទម្ងន់ដើម្បីប្ដូរនូវរបបអាហារដែលមានតែបបរពីរ បីវែក ប៉ុណ្ណោះ ។ ហេតុនេះហើយ រាល់ពេលដែល ផាវី ទៅឃ្វាលគោតែងតែប្រថុយជីវិតលួចបូតក្ដួរស្រូវយកមកហូប ទោះបីជាដឹងថា ប្រសិនបើអង្គការចាប់បាន នោះនឹងទទួលរងទារុណកម្ម ឬយកទៅសម្លាប់ក៏ដោយ តែភាពស្រេកឃ្លាន វាមានទំហំធំជាង ។ ពេញមួយរបបគាត់ធ្វើនៅកងកុមារ ជាអ្នកឃ្វាលគោ និងកើបរើសអាចម៍គោប៉ុណ្ណោះ ។ គ្មាននរណាម្នាក់ហ៊ានប្រឆាំងនឹងបញ្ជារបស់អង្គការឡើយ ។ អ្នកដែលហ៊ានប្រឆាំងតវ៉ា លទ្ធផល គឺមានតែមួយគត់ គឺអង្គការយកទៅរៀនសូត្រ ។ ផាវី តែងតែចងចាំនូវបណ្ដាំ របស់ម្ដាយគាត់ប្រាប់ជានិច្ចថា ត្រូវតែធ្វើអ្វីតាមដែលអង្គការចាត់តាំងដាច់ខាត ប្រសិនបើចង់រស់ មិនត្រូវហ៊ានតវ៉ាប្រឆាំងអង្គការឡើយទោះបីជាការងារនោះលំបាកប៉ុណ្ណាក៏ដោយ ។

រហូតមកឆ្នាំ១៩៧៩ ទើបក្ដីសង្ឃឹមថ្មីកើតមានចំពោះ ផាវី ព្រោះតែមានកងទ័ពវៀតណាមចូលមកជួយរំដោះប្រទេសជាតិចេញពីរបបដ៏យង់ឃ្នងមួយនេះ ។ ក្រោយពីបានរួចផុតពីសម័យខ្មែរក្រហម គ្រួសាររបស់គាត់បានរស់នៅក្នុងភូមិស្រុកដដែល ។ ប្រជាជនមួយចំនួនមានសេចក្ដីសប្បាយរីករាយដែលបានជួបជុំគ្រួសារវិញ តែគ្រួសារមួយចំនួនផ្សេងទៀត ក៏គ្មានវាសនាជួបបងប្អូន ញាតិមិត្ត ឪពុកម្ដាយដែរ ព្រោះអ្នកទាំងនោះបានស្លាប់ និងបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ ផាវី គ្មានភាពរីករាយដូចគ្រួសារដទៃទេ ព្រោះគាត់បានបាត់បង់ឪពុក និងបងប្រុសជាទីស្រឡាញ់របស់ខ្លួន ។ ផាវី ពិតជាសោកស្ដាយ និងឈឺចាប់ណាស់ចំពោះការបាត់បង់នេះ ព្រោះអ្នកទាំងពីរ គ្មានកំហុសដែលគួរនឹងស្លាប់នោះទេ ។ ឪពុកស្លាប់ព្រោះមានជំងឺ គ្មានថ្នាំព្យាបាល ឯបងប្រុសត្រូវខ្មែរក្រហមសម្លាប់ ព្រោះតែជាអតីតគ្រូបង្រៀន ។ ចម្ងល់ទាំងនេះ នៅតែដក់ជាប់ក្នុងចិត្ត ផាវី ជានិច្ចថា ហេតុអ្វីបានជាខ្មែរក្រហមយកអ្នកមានចំណេះដឹងទៅសម្លាប់ដើម្បីអ្វី ប្រសិនបើការកសាងប្រទេសត្រូវការអ្នកដែលមានចំណេះដឹង?

តែទោះជាយ៉ាងនេះក្ដី ផាវី នៅតែមានជំនឿចិត្តក្នុងការរស់នៅបន្ត ព្រោះតែមានម្ដាយជួយគាំទ្រ លើកទឹកចិត្តដល់គាត់ ។ ផាវី បានចាប់ផ្ដើមចូលរៀន ហើយសាលារៀននៅពេលនោះ ពុំទាន់មានបន្ទប់រៀនត្រឹមត្រូវទេ គឺគាត់ត្រូវដើររៀននៅតាមវត្តអារាម ។ រៀនដល់ត្រឹមថ្នាក់ទី៨ គ្រូបានឲ្យ ផាវី ប្រឡងផ្លោះទៅរៀនជាមួយនឹងថ្នាក់អនុវិទ្យាល័យ (កម្រិតសិក្សាទីពី) ។ ឆ្នាំ១៩៨៦ ផាវី ប្រឡងជាប់ថ្នាក់ឌីប្លូម ។ បន្ទាប់ពីប្រឡងជាប់ គាត់បានបន្តប្រឡងធ្វើជាគ្រូបង្រៀននៅវិទ្យាល័យ ហ៊ុន សែន ពាមខកញ៉ាអុងផ្នែកភូមិវិទ្យា រហូតមកដល់ពេលបច្ចុប្បន្ន ។ **អៀង ណារី**

# ការបាត់បង់របស់ឪពុកខ្ញុំ បានត្រឹមតែចងចាំ

ឪពុករបស់ខ្ញុំមានទីកំណើតនៅភូមិត្រាំខ្នារ ឃុំសុភីខេត្តតាកែវ ។ គាត់រស់នៅក្នុងគ្រួសារជាអ្នកជំនួញ ។ ចាប់តាំងពីពេលដែលគាត់កើតរហូតដល់ឆ្នាំ១៩៧០ ឪពុករបស់ខ្ញុំរស់ក្នុងជីវភាពដ៏សុខដុមជាមួយមុខរបរជំនួញរបស់គាត់ប៉ុន្តែបន្ទាប់ពីរដ្ឋប្រហាររបស់សេនាប្រមុខ លន់ នល់ ក្រុមគ្រួសារគាត់បានផ្លាស់ទីលំនៅមកទីក្រុងភ្នំពេញវិញដើម្បីចាប់ផ្តើមមុខជំនួញថ្មីមួយ ។ ដោយសារតែស្ថានភាពនយោបាយមានភាពវឹកវរ ជំនួញរបស់គាត់ក៏មិនមានភាពល្អប្រសើរដែរ ហេតុនេះយាយតាខ្ញុំត្រូវបង្ខំចិត្តខ្ចីលុយពីអ្នកជិតខាងដើម្បីដោះស្រាយបញ្ហា ។ តា និងឪពុករបស់ខ្ញុំតែងតែស្តាប់វិទ្យុរបស់ខ្មែរក្រហមជាប្រចាំ ។ ក្រោយពីគាត់បានដឹងថាខ្មែរក្រហមនឹងបញ្ឈប់ការប្រើប្រាស់ក្រដាសប្រាក់នៅពេលខ្លួនកាន់អំណាចតារបស់ខ្ញុំបានលក់ទ្រព្យសម្បត្តិរបស់គាត់ដើម្បីសងបំណុលគេ ។ ទោះជាយ៉ាងនេះក្តី ក្រុមគ្រួសាររបស់គាត់នៅតែមានភាពរីករាយ ។

ប៉ុន្តែទិដ្ឋភាពទាំងនោះ ត្រូវបានប្រែប្រួលចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលថ្ងៃនោះ គឺជាថ្ងៃ ដែលឪពុករបស់ខ្ញុំ និងសមាជិកគ្រួសារដប់ពីរនាក់ផ្សេងទៀតត្រូវបានអង្គការជម្លៀសចេញពីទីក្រុងភ្នំពេញទៅរស់នៅស្រុកកំណើតរបស់គាត់នៅឯខេត្តតាកែវ ។ នៅម៉ោង៥ល្ងាចគាត់បានចាកចេញពីទីក្រុងភ្នំពេញហើយបានសម្រាកមួយយប់នៅឯពោធិ៍ចិនតុង ។ ពេលធ្វើដំណើរគាត់មានត្រឹមតែសម្លៀកបំពាក់ចាស់ៗប៉ុន្មានសម្រាប់អង្ករបន្តិចបន្តួច កង់ និងនាឡិកាដៃមួយប៉ុណ្ណោះ ។ ខ្មែរក្រហមតែងតែមកស្នើសុំកង់ម៉ូតូ និងសម្ភារប្រើប្រាស់ពីប្រជាជន ។ ដោយខ្លាចខ្មែរក្រហមស្នើកង់ឪពុករបស់ខ្ញុំបានបន្ទួរកង់ ដូច្នេះនៅពេលដែលខ្មែរក្រហមដើរមកឃើញក៏មិនបានសួរនាំដែរ ។ នៅព្រឹកថ្ងៃបន្ទាប់វេលាម៉ោងប្រហែល៧ព្រឹក គាត់បានបន្តដំណើរទៅមុខទៀត ។ ជារៀងរាល់ថ្ងៃ គ្រួសារឪពុកខ្ញុំត្រូវដើរលើចមាយផ្លូវច្រើនគីឡូម៉ែត្រដែល នៅតាមផ្លូវឪពុករបស់ខ្ញុំបានឃើញសាកសពជាច្រើនមានទាំងទាហាន និងប្រជាជនស៊ីវិល ។

ក្រោយពីធ្វើដំណើរបានមួយរយៈគ្រួសាររបស់គាត់បានសម្រេចចិត្តទៅរស់នៅឯខេត្តកំពង់ស្ពឺវិញ ។ ដំបូងឡើយ ជីវភាពរស់នៅនៅទីនោះមិនសូវជាលំបាកប៉ុន្មានទេ ប៉ុន្តែក្រោយមកខ្មែរក្រហមចាប់ផ្តើមឃ្លាំមើលគ្រួសារឪពុកខ្ញុំ និងផ្តល់អាហារឲ្យតិចតួចហើយបង្ខំគាត់ឲ្យធ្វើការធ្ងន់ធ្ងរគ្មានពេលសម្រាក ។ ពេលនោះឪពុករបស់ខ្ញុំមានអាយុតិចនៅឡើយជីវភាពកុមារដែលគួរតែទទួលបាននូវភាពរីករាយត្រូវបានបំផ្លាញក្នុងរយៈពេលដ៏ខ្លី ។ ខ្មែរក្រហមបានលុបបំបាត់ជីវភាពសុខដុមរបស់ក្រុមគ្រួសារឪពុកខ្ញុំអ្វីៗដែលមានពីមុនមកត្រូវរលាយបាត់ ។អ្វីដែលអាចធ្វើបានគឺអនុវត្តតាមបញ្ជារបស់ខ្មែរក្រហម ។

ប្រហែលនៅខែសីហា ឬកញ្ញា គ្រួសារឪពុកខ្ញុំត្រូវបានអង្គការបញ្ជូនឲ្យទៅនៅភូមិពន្លៃ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ នេះគឺជាការធ្វើដំណើរដ៏វែងឆ្ងាយម្តងទៀត ក្រោយពីការធ្វើការគ្មានពេលឈប់ឈរនៅខេត្តកំពង់ស្ពឺ ។ ពេលទៅដល់ទីនោះ គ្រួសារឪពុកខ្ញុំត្រូវបានបំបែក និងបង្ខំឲ្យទៅរស់នៅឯសហករណ៍វិញ ។ ឪពុករបស់ខ្ញុំបានប្រាប់ខ្ញុំថានៅក្នុងសម័យនោះគាត់គ្មានអ្វីហូបទេក្រៅពីដើររកស្លឹកឈើ ឬសឈើហូប មានពេលខ្លះគាត់រកបានតែស្លឹកឈើដែលមានជាតិពុល ។ ដោយគ្មានជម្រើសអ្វីផ្សេង គាត់ត្រូវយកស្លឹកឈើនោះទៅលាងទឹកដើម្បីកាត់បន្ថយជាតិពុលហើយបរិភោគ ។ គាត់ប្រថុយហូបវាទាំងមានជាតិពុល ព្រោះវាប្រសើរជាងស្លាប់ដោយអត់អាហារ ។ សំណាងល្អដែលជាតិពុលទាំងនោះមិនបានយកជីវិតគាត់ ប៉ុន្តែជាសំណាងអាក្រក់ដែលត្រូវបន្តដំណើរជីវិតដ៏លំបាកព្រោះមិនអាចទាយបានថាពេលណានឹងបញ្ចប់ ។នៅក្នុងភូមិដែលគាត់រស់នៅគ្មានថ្នាំសង្កូវ និងការព្យាបាលត្រឹមត្រូវទេ ។ មនុស្សជាច្រើនបានស្លាប់ដោយសារជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត ។

ថ្ងៃមួយ ខ្មែរក្រហមបានប្រកាសថា សម្តេចព្រះ នរោត្តម



កងចល័តស្ទូងស្រូវនៅវាលស្រែ ក្នុងរបបខ្មែរក្រហម

សីហនុ បានវិលត្រឡប់មកមាតុប្រទេសវិញហើយ ហើយបានអំពាវនាវឲ្យប្រជាជនដែលស្មោះស្ម័គ្រនឹងព្រះអង្គទៅទទួលដំណើរទ្រង់ ។ ប្រជាជនជាច្រើនដែលជឿជាក់លើពាក្យសម្ដីទាំងនេះបានធ្វើតាមការអំពាវនាវរបស់ខ្មែរក្រហមចេញទៅទទួលស្វាគមន៍ទ្រង់ តែត្រូវបានសម្លាប់យ៉ាងអណោចអធ័ម ។ មានថ្ងៃមួយ ឪពុករបស់ខ្ញុំបានឃើញយោធាខ្មែរក្រហមសម្លាប់មនុស្សជាច្រើនហើយបានវះពោះគាត់យកថ្លើមរបស់គេទៅចម្អិន ។ វាពិតជាព្រឹត្តិការណ៍មួយដែលពិបាកនឹងបំភ្លេចណាស់សម្រាប់ឪពុកខ្ញុំ ។

ក្រោយពីរស់នៅខេត្តបាត់ដំបងប្រមាណជាមួយឆ្នាំ ឪពុករបស់ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនម្ដងទៀតទៅភូមិខ្មោចចាមដើម្បីទៅបម្រើការនៅកងចល័ត ។នៅទីនោះខ្មែរក្រហមបានផ្ដល់អាហារត្រឹមតែបួនទៅប្រាំកំប៉ុងក្នុងមួយថ្ងៃប៉ុណ្ណោះសម្រាប់ប្រជាជនមួយភូមិ ដែលមានចំនួនរហូតដល់ទៅជាងមួយរយនាក់ ។ ឪពុករបស់ខ្ញុំ និងអ្នកឯទៀតដែលមានវ័យស្របាលគាត់ តែងតែលួចទៅរកសណ្ដែកដី ដែលប្រជាជនដាំនៅជិតរោងបាយរួម ។ ពេលដែលអ្នករកសណ្ដែកត្រូវខ្មែរក្រហមចាប់បាន អ្នកទាំងនោះត្រូវបានបង្ខំឲ្យជីករណ្ដៅធំមួយ ។ ពេលរណ្ដៅនោះធំល្មមហើយ ខ្មែរក្រហមបានប្រាប់ទៅអ្នកទាំងនោះឲ្យចុះទៅវាស់រណ្ដៅ រួចហើយខ្មែរក្រហមបានយកដីកប់ទាំងរស់តែម្ដង ។ នៅខណៈនោះខ្មែរក្រហមបានបង្ខំឲ្យឪពុកខ្ញុំនិងអ្នកឯទៀតឈរមើលហើយហាមមិនឲ្យនិយាយអ្វី ឬយំអាណិតអ្នកទាំងនោះទេ បើមិនដូច្នេះនឹងត្រូវស្លាប់ដូចអ្នកទាំងនោះដែរ ។ នេះជាទណ្ឌកម្មមួយសម្រាប់អ្នកទាំងឡាយដែលលួចយកអាហារដោយគ្មានការអនុញ្ញាត ។ ឪពុករបស់ខ្ញុំតែងតែរស់នៅក្នុងភាពភ័យខ្លាចដោយគាត់មិនចង់ស្លាប់ក្នុងសភាពដូចជាជនរងគ្រោះទាំងនោះទេ ។ ខណៈដែលគាត់រស់នៅទីនោះ តារបស់ខ្ញុំបានស្លាប់ដោយអត់អាហារ និងជំងឺ ។ ពេលនោះ ឪពុកខ្ញុំមិនអាចបញ្ចុះសពឪពុករបស់គាត់ទេហើយក៏មិនអាចយំដើម្បីសម្ដែងក្ដីឈឺចាប់ និងការនឹករឭករបស់គាត់បានទេ ។ គាត់បានប្រើពេលវេលាដែលនៅសល់របស់គាត់ចងចាំមុខមាត់ និងបន់ស្រន់ជូនគាត់ ។ មិនបានប៉ុន្មានខែ ព្រឹត្តិការណ៍នេះបានកើតឡើងម្ដងទៀតលើបងស្រីជាទីស្រឡាញ់របស់គាត់ ។ ពេលនោះ ឪពុករបស់ខ្ញុំមានការឈឺចាប់យ៉ាងខ្លាំងព្រោះគាត់មិនអាចចែករំលែកក្ដីសប្បាយរីករាយជាមួយគាត់ឡើងវិញបានទេ ។

ក្រោយមកគាត់បានសុំខ្មែរក្រហមទៅធ្វើការនៅភ្នំតុំវិញដើម្បីប្ដូរនឹងបាយបីស្លាបព្រាក្នុងមួយថ្ងៃ ។ នៅម៉ោង៤ ឬ ៥ព្រឹកគាត់ត្រូវដើរចម្ងាយ៧គីឡូម៉ែត្រទៅការដ្ឋាន ហើយត្រូវដើរត្រឡប់មកវិញនៅម៉ោង៦ល្ងាច ។ ពេលគាត់ទៅទីនោះ ឪពុករបស់ខ្ញុំបានរងរបួសយ៉ាងខ្លាំងនៅលើជើង ។ ជើងរបស់គាត់មានអាការៈហើមយ៉ាងខ្លាំងរហូតដល់មិនអាចដើរបាន ។ មានមនុស្សជាច្រើនបាននិយាយថា ឪពុកខ្ញុំនឹងស្លាប់ ប៉ុន្តែគាត់បានសម្រេចចិត្តថា បើគាត់ស្លាប់ គឺស្លាប់ក្នុងភូមិ ដូច្នេះគាត់ខិតខំដើរបន្តទៀត តែគាត់មិនអាចបន្តដំណើរមកដល់ភូមិនៅពេលដែលជើងរបស់គាត់មិនទាន់ជាសះស្បើយ ។ គាត់ត្រូវបានខ្មែរក្រហមស្នើឲ្យទៅជីកប្រឡាយនៅភ្នំធិបតី និងភ្នំប្រហូត ។ គាត់ទៅធ្វើការតាំងពីព្រលឹមទល់ព្រលប់ ។ ពេលខ្លះគាត់ទទួលបានបាយតែមួយស្លាបព្រាប៉ុណ្ណោះក្នុងមួយថ្ងៃ និងមានពេលខ្លះគាត់អត់បាយជាច្រើនថ្ងៃហើយជួនកាលកន្លះខែក៏មាន ។ ប្រជាជននៅទីនោះត្រូវដើរទៅស្វែងរកស្លឹកឈើបរិភោគ ។ ឪពុករបស់ខ្ញុំហូបគ្រប់យ៉ាងដែលអាចរកបាន ។ ឪពុកខ្ញុំបាននិយាយថា ក្នុងពេលនោះគាត់មិនសង្ឃឹមថា អាចមានជីវិតមកដល់សព្វថ្ងៃនេះទេ ។ អ្វីដែលគាត់គិតមានត្រឹមតែម៉្យាងប៉ុណ្ណោះ គឺពេលណាគាត់ស្លាប់ ហើយគាត់ស្លាប់ដោយរបៀបណា ។

ថ្ងៃមួយពេលដែលឪពុករបស់ខ្ញុំ និងក្មេងៗឯទៀតទៅលួច

រកអាហារហូបក្នុងវាលស្រែគាត់ត្រូវយោធាខ្មែរក្រហមចាប់ខ្លួន បាន ។ គាត់បម្រុងនឹងរត់ប៉ុន្តែដោយសារតែក្នុងដៃរបស់ខ្មែរក្រហម មានកាំភ្លើង ។ គាត់មានការតក់ស្លុតដោយខ្លាចខ្មែរក្រហមបាញ់ ។ ខ្មែរក្រហមបានបណ្តើរគាត់ទៅភូមិមួយទៀត ប៉ុន្តែបានដោះលែង គាត់វិញនៅពេលល្ងាច ។ មានយោធាម្នាក់បានឲ្យបាយទៅឪពុក របស់ខ្ញុំដោយលួចលាក់ពីព្រោះទាហាននោះស្គាល់អ៊ំរបស់ខ្ញុំ ។ ក្រោយមកគាត់ត្រូវបានខ្មែរក្រហមបញ្ជូនមកភូមិខ្មោចចាមវិញ ហើយបានបន្តជីវភាពដ៏លំបាករបស់គាត់នៅទីនោះរហូតដល់ថ្ងៃ រំដោះ ។

ឪពុករបស់ខ្ញុំបាននិយាយថាគាត់នឹងមិនអាចបំភ្លេចបទ ពិសោធដែលគាត់ និងប្រជាជនជាច្រើនបានឆ្លងកាត់នោះទេ ។ គាត់បានបន្ថែមថា គ្រប់រឿងរ៉ាវទាំងអស់គាត់មិនអាចបំភ្លេចបាន ទេព្រោះវាដូចជាស្រមោលមួយដែលលួចយកសុភមង្គលរបស់ គាត់ ជាពិសេស មនុស្សជាទីស្រឡាញ់ក្នុងជីវិត គឺ ឪពុក និងបងស្រី របស់គាត់ ។នេះប្រហែលជាមូលហេតុមួយដែលគាត់តែងតែអប់រំ ទូន្មានសមាជិកក្នុងគ្រួសារខ្ញុំឲ្យចេះជួយអ្នកដទៃតាមលទ្ធភាពដែល យើងមាន ហើយត្រូវចេះប្រើប្រាស់ពេលវេលាឲ្យមានតម្លៃ ។ ជា រៀងរាល់ពេល ដែលគាត់រំឭកពីអតីតកាលដ៏ជូរចត់នេះ ទឹកភ្នែក របស់គាត់តែងតែស្រក់ចុះដោយមិនអាចទប់បាន ។ គាត់សង្ឃឹមថា នឹងមានយុត្តិធម៌នៅថ្ងៃណាមួយ ហើយចង់ឲ្យក្មេងៗជំនាន់ក្រោយ យល់ដឹងពីអ្វីដែលកើតមានក្នុងសង្គមខ្មែរ ។ ក្តីសង្ឃឹមមួយដែល គាត់រំពឹងគឺតុលាការខ្មែរក្រហមនឹងនាំមកនូវយុត្តិធម៌ជូនប្រជាជន គ្រប់រូប ។អ្នកដឹកនាំនៅក្នុងសម័យខ្មែរក្រហម ត្រូវតែទទួលខុស ត្រូវរាល់ទង្វើឧក្រិដ្ឋទាំងឡាយដែលខ្លួនបានបង្កឡើងរួមទាំងទទួល ស្គាល់កំហុសរបស់ខ្លួន ។

**អេង សុជាតា**

# ខ្សែភាពយន្តឯកសាររឿង «ក្បួនទឹកទន្លេ»

“ក្បួនទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បួនទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បួនទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និង ប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល ៖ *truthfatily.s@dccam.org* គេហទំព័រ ៖ *www.ariverchangescourse.com*







# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានឈានទៅរកការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 174, 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.